ក

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រម

២០-៧-២០០៧ -ព្រះរាជក្រម នស/រកម/០៧០៧/០២១ ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលកម្ពុជាឱ្យ (១)-ក្រុមហ៊ុននាយណា យូណាន ខបផរសិន ហ្វរ អ៊ីនធើណេសិនណល តិចណូ-អេកូណូមិច ខូអុបភើរេហ្សិន និង (២)-ក្រុមហ៊ុនយូណានសោអ៊ីស-អេស៊ា អេកូណូមី អ៊ែន តិចណូឡូជី អ៊ីនវេសមេន អ៊ីនជាសស្ត្រាល ៥៧៩៧

២-ព្រះរាជក្រឹត្យ

១៧-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/២៨៩ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **គីម ជុនយ៉ុង** (KIM JUNE YOUNG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅសាធារណរដ្ឋកូរ៉េ ៥៨៣២

១៧-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/២៩០ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ហាន ឈីនឆាង** (HAN QING CHANG) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្ត Shandong ប្រទេសចិន ៥៨៣៣

២០-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/២៩៤ ស្តីពីការតែងតាំងឯកឧត្តម **ជាំ សិទ្ធិ** ជាជំនួយការឯកឧត្តម **យឹម សុវណ្ណ** ប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងមុខងារសាធារណៈ មានឋានៈស្មើ អគ្គនាយក ៥៨៣៤

២៣-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣០៤ ស្តីពីការកំណត់ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងផែនការ ៥៨៣៥

២៧-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣០៨ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ហូ ស៊ីវឈឿន** (HO SIU CHEUNG) ជនជាតិចិន សញ្ជាតិចិន កើតនៅក្រុងហុងកុង ប្រទេសចិន ៥៨៤៤

២៧-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣០៩ ស្តីពីការត្រូវបានតាំងស៊ប់លោក **នួន ពុទ្ធារ៉ា** ក្នុងឋានន្តរស័ក្តិអនុមន្ត្រីថ្នាក់លេខ ១៤ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ គិតចាប់ពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៦ តទៅ ៥៨៤៥

២៧-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣១០ ស្តីពីប្រាក់បំណាច់ស្រាវជ្រាវរបស់សមាជិកបណ្ឌិតសភា និង មន្ត្រីស្រាវជ្រាវ នៃរាជបណ្ឌិតសភាកម្ពុជា ៥៨៤៦

២៨-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣១១ ស្តីពីការប្រោសព្រះរាជទាន ថ្វាយគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី និងសម្តេចព្រះសង្ឃ ចំនួន ០៨ ព្រះអង្គ ៥៨៤៩

២៨-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣១២ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និងលោកជំទាវ ចំនួន ០៥ រូប ៥៨៥០

២៨-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣១៣ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម អ្នកអង្គម្ចាស់ និងលោកជំទាវ ចំនួន ១២ រូប ៥៨៥១

២៨-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣១៤ ស្តីពីការប្រោសព្រះរាជទាន ចំពោះឯកឧត្តម **ហាស់ សារ៉េត** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ធិបឌិន្ទ ៥៨៥២

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

២៧-៧-២០០៧ -អនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពីការតម្លើងឋានៈ និង ប្តូរឈ្មោះមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបាត់ដំបង ទៅជាវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង ៥៨៥៣

២៧-៧-២០០៧ -អនុក្រឹត្យលេខ ៨៨ អនក្រ.បក ស្តីពីការប្រែក្លាយសាលាភូមិន្ទនគរបាល ទៅជាបណ្ឌិតសភានគរបាលកម្ពុជា ៥៨៥៦

២៣-៧-២០០៧ -អនុក្រឹត្យលេខ ៥៧៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥៨៦០

២៣-៧-២០០៧ -អនុក្រឹត្យលេខ ៥៧៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៨៦៨

២៣-៧-២០០៧ -អនុក្រឹត្យលេខ ៥៧៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៨៦៩

២៣-៧-២០០៧ -អនុក្រឹត្យលេខ ៥៧៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៨៧០

២៣-៧-២០០៧	-អនុក្រឹត្យលេខ ៥៧៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី	៥៨៧១
២៣-៧-២០០៧	-អនុក្រឹត្យលេខ ៥៨០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៧២
២៣-៧-២០០៧	-អនុក្រឹត្យលេខ ៥៨១ អនក្រ.តត ស្តីពីការជូនមេដាយការងារ	៥៨៧៣
២៣-៧-២០០៧	-អនុក្រឹត្យលេខ ៥៨២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៧៤
២៣-៧-២០០៧	-អនុក្រឹត្យលេខ ៥៨៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៧៥
២៣-៧-២០០៧	-អនុក្រឹត្យលេខ ៥៨៤ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៥៨៧៨
២៣-៧-២០០៧	-អនុក្រឹត្យលេខ ៥៨៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៧៩
២៤-៧-២០០៧	-អនុក្រឹត្យលេខ ៥៨៦ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៥៨៨១
២៤-៧-២០០៧	-អនុក្រឹត្យលេខ ៥៨៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៨២
២៤-៧-២០០៧	-អនុក្រឹត្យលេខ ៥៨៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៨៣
២៤-៧-២០០៧	-អនុក្រឹត្យលេខ ៥៨៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៨៤
២៤-៧-២០០៧	-អនុក្រឹត្យលេខ ៥៩០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៨៥
២៤-៧-២០០៧	-អនុក្រឹត្យលេខ ៥៩១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៨៦
២៤-៧-២០០៧	-អនុក្រឹត្យលេខ ៥៩២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៨៧
២៥-៧-២០០៧	-អនុក្រឹត្យលេខ ៥៩៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៨៨
២៥-៧-២០០៧	-អនុក្រឹត្យលេខ ៥៩៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៨៩
២៥-៧-២០០៧	-អនុក្រឹត្យលេខ ៥៩៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៩០
២៥-៧-២០០៧	-អនុក្រឹត្យលេខ ៥៩៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៩២
២៥-៧-២០០៧	-អនុក្រឹត្យលេខ ៥៩៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៩៣
២៥-៧-២០០៧	-អនុក្រឹត្យលេខ ៥៩៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៩៤
២៥-៧-២០០៧	-អនុក្រឹត្យលេខ ៥៩៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៩៥
២៥-៧-២០០៧	-អនុក្រឹត្យលេខ ៦០០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៨៩៦

២-សេចក្តីសំរេច

២៨-៧-២០០៧	-សេចក្តីសំរេចលេខ ៣៨ សសរ ស្តីពីការបង្កើតប្រតិភូចុះពិនិត្យជាក់ស្តែង លើសកម្មភាពចាក់ដីលុបអាងទឹកតាមោក និងសកម្មភាពអសកម្មនានា ដែលមាននៅក្នុងអាងទឹកតាមោក	៥៨៩៧

៣១-៧-២០០៧	-សេចក្តីសំរេចលេខ ៣៩ សសរ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីទ្រទ្រង់ដល់ការរៀបចំព្រឹត្តិការណ៍ "ការប្រកួតកីឡាវាយកូនគោលអាស៊ី លក្ខណៈអន្តរជាតិ Johnnie Walker Cambodia Open 2007 " នៅខេត្តសៀមរាប ចាប់ពីថ្ងៃទី ២៩ ខែវិច្ឆិកា ដល់ថ្ងៃទី ០២ ខែធ្នូ ឆ្នាំ ២០០៧	៥៨៩៩

៣. សារាចរ

២៦-២-២០០៧	-សារាចរលេខ ០២ សរ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់	៥៩០២

៤. សារាចរណែនាំ

០៣-៥-២០០៧	-សារាចរណែនាំលេខ ០៣ សរ.ណន ស្តីពីការរៀបចំខួបលើកទី ៥៨ "ទិវាកុមារអន្តរជាតិ ១ មិថុនា " និងខួបលើកទី ៦ "ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា " ឆ្នាំ ២០០៧	៥៩១០

III. ការងារបណ្តាក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

១២-៦-២០០៧	-ប្រកាសលេខ ៤៦៥ សហវ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជា ឆ្នាំ ២០០៧ *(ត មកពីរាជកិច្ច លេខ ៤៩...ដល់...៥៦)*	៥៩១២
២៦-៧-២០០៧	-ប្រកាសលេខ ៦៤៣ សហវ.ប្រក ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុ ឱ្យធ្វើសវនកម្មគណនេយ្យសហគ្រាស	៥៩៤១
២៦-៧-២០០៧	-ប្រកាសអន្តរក្រសួងលេខ ៦៤៧ សហវ.ប្រក ស្តីពីការកំណត់តម្លៃអាជ្ញាប័ណ្ណភាពយន្ត និង វីដេអូ	៥៩៤៤
២៦-៧-២០០៧	-ប្រកាសអន្តរក្រសួងលេខ ៦៤៨ សហវ.ប្រក ស្តីពីការកំណត់តម្លៃសំបុត្រចូលទស្សនាសារមន្ទីរជាតិ	៥៩៤៥
២៦-៧-២០០៧	-ប្រកាសអន្តរក្រសួងលេខ ៦៤៩ សហវ.ប្រក ស្តីពីការកំណត់តម្លៃសុំសិទ្ធិបង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្មលើស្នាដៃអ្នកនិពន្ធអក្សរសាស្ត្រ សិល្បៈ និងតន្ត្រី ដែលគ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍	៥៩៥២

ព្រះរាជក្រម

នស/រកម/០៧០៧/០២១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលកម្ពុជាឱ្យ (១)-ក្រុមហ៊ុន ឆាយណា យូណាន ខបផរេសិន ហ្វរ អ៊ិនធើណេសិនណល តិចណូ-អេកូណូមិច ខូអុបភើរេហ្សិន និង (២)-ក្រុមហ៊ុន យូណាន សោអ៊ីស-អេសា អេកូណូមីអែន តិចណូឡូជី អ៊ិនវេសមេន អ៊ិនដាសស្ទ្រាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់

ស្តីពី

ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលកម្ពុជាឱ្យ (១)-ក្រុមហ៊ុនឆាយណា យូណាន ខបផរេសិន ហ្វរ អ៊ីនធើណេសិនណល តិចណូ-អេកូណូមិច ខូអុបភើរេហ្សិន និង (២)-ក្រុមហ៊ុនយូណានសោអ៊ីស-អេស៊ា អេកូណូមី អ៊ែន តិចណូឡូជី អ៊ីនវេសមេន អ៊ីនដាសស្ទ្រាល

មាត្រា ១.-

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុនអគ្គិសនីកម្ពុជា ឱ្យ :

១-ក្រុមហ៊ុន ឆាយណា យូណាន ខបផរេសិន ហ្វរ អ៊ីនធើណេសិនណល តិច-ណូ-អេកូណូមិច ខូអុបភើរេហ្សិន ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាងរាជ-រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន ឆាយណា យូណាន ខបផរេសិន ហ្វរ អ៊ីនធើណេសិនណល តិចណូ-អេកូណូមិច ខូអុបភើរេហ្សិន និងកិច្ចព្រមព្រៀងទិញលក់អគ្គិសនីរវាងក្រុមហ៊ុនអគ្គិសនីកម្ពុជា និងក្រុមហ៊ុនឆាយណា យូណាន ខបផរេសិន ហ្វរ អ៊ីនធើណេសិនណល តិចណូ-អេកូណូមិច ខូអុបភើរេហ្សិន ដែលបានចុះហត្ថលេខានៅរាជ-ធានីភ្នំពេញ នាថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ។

២-ក្រុមហ៊ុន យូណាន សោអ៊ីស-អេស៊ា អេកូណូមិច អ៊ែន តិចណូឡូជី អ៊ីនវេស-មេន អ៊ីនដាសស្ត្រាល ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាងរាជរដ្ឋាភិបាលនៃ

ព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន យូណាន សោអ៊ីស-អេស៊ា អេកូណូមិច អែន តិចណូឡូជី អ៊ីនវេសមេន អ៊ីនដាសស្ទ្រាល និងកិច្ចព្រមព្រៀងបញ្ចូនអគ្គិសនីរវាងក្រុមហ៊ុនអគ្គិសនីកម្ពុជា និងក្រុមហ៊ុន យូណាន សោអ៊ីស-អេស៊ា អេកូណូមិច អែន តិចណូឡូជី អ៊ីនវេសមេន អ៊ីនដាសស្ទ្រាល ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ នាថ្ងៃទី ១៦ ខែ កុម្ភៈឆ្នាំ ២០០៧ ។

ការធានានេះមានអត្ថបទទាំងស្រុង ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៧ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលកម្ពុជាភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលិខិតធានាទូទាត់នេះ ។

មាត្រា ៣.-

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣/ល.០៧/០៧.៣១៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ ៣០៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនគេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥ . សប្រក

សេចក្តីសម្រេច

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០៧

-បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣

-បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាព ជូនឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀង IMPLEMENTATION AGREEMENT (IA) លើកិច្ចព្រមព្រៀង LEASE AGREEMENT (LA) និង លើលិខិតធានាទូទាត់ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា (FORM OF GOVERNMENT GUARANTEE OF PAYMENT) ដោយក្រុមហ៊ុនអគ្គិសនីកម្ពុជា (EDC) ទៅអោយក្រុមហ៊ុន CHINA YUNNAN CORPORATION FOR INTERNATIONAL TECHNO-ECONOMIC CO-OPERATION សំរាប់គំរោងវារីអគ្គិសនី ១២០ MW នៅស្ទឹងអាតៃ ខេត្តពោធិសាត់ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

Kingdom of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

រាជរដ្ឋាភិបាល

Royal Government

N° 45.D.F.P

DELEGATION OF FULL POWERS

- Seen the Constitution of the Kingdom of Cambodia
- Seen the Royal Decree NS/RKT/0704/124 dated 15 of July 2004 on the nomination of the Royal Government of Cambodia
- Seen the Royal Kram 02/NS/94 dated 20 of July 1994 promulgating the Law on the Organization and Functioning of the Council of Ministers
- Seen the Royal Kram NS/RKM/1206/035 dated 29 of December 2006 promulgating the Law on Finance for Management of Fiscal Year 2007
- Seen the Royal Kram 03/NS/94 dated 05 of August 1994 promulgating the Law on Investment of Kingdom of Cambodia and the Law on Amendment of Law on Investment of Kingdom of Cambodia promulgated by the Royal Kram NS/RKM/0303/009 dated 24 of March 2003
- Seen Sub-decree 111 អនក្រ.បក dated 27 of September 2005 on Implementation of the Law on Amendment of Law on Investment of Kingdom of Cambodia

The Royal Government

Delegates herewith to H.E. Mr. KEAT CHHON, Senior Minister, Minister of Economy and Finance, full power to sign the Implementation Agreement (IA), Lease Agreement (LA), and the Form of Government Guarantee of Payment by the EDC to CHINA YUNNAN CORPORATION FOR INTERNATIONAL TECHNO-ECONOMIC CO-OPERATION, for the Development of Stung Atay Hydro-electric BOT Project.

In witness whereof the undersigned, the Prime Minister of the Kingdom of Cambodia with full powers duly entrusted to him, has signed this delegation of full powers.

Phnom Penh, February 16, 2007

Prime Minister

HUN SEN

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧ [illegible]

សិទ្ធិប្រទាន

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០៧

-បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣

-បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាព ជូនឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀង IMPLEMENTATION AGREEMENT (IA) និង លើលិខិតធានាការទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា (FORM OF GOVERNMENT GUARANTEE OF PAYMENT) ដោយក្រុមហ៊ុនអគ្គិសនីកម្ពុជា (EDC) ទៅអោយក្រុមហ៊ុន YUNNAN SOUTHEAST-ASIA ECONOMY AND TECHNOLOGY INVESTMENT INDUSTRIAL CO., LTD. សំរាប់គំរោងខ្សែបញ្ជូនអគ្គិសនី ២៣០ គីឡូវ៉ុល តភ្ជាប់ពីភ្នំពេញ-កំពង់ឆ្នាំង-ពោធិសាត់-បាត់ដំបង និង អនុស្ថានីយ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

រាជរដ្ឋាភិបាល
Royal Government
ГГ= 16.D.F.P

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

DELEGATION OF FULL POWERS

- Seen the Constitution of the Kingdom of Cambodia
- Seen the Royal Decree NS/RKT/0704/124 dated 15 of July 2004 on the nomination of the Royal Government of Cambodia
- Seen the Royal Kram 02/NS/94 dated 20 of July 1994 promulgating the Law on the Organization and Functioning of the Council of Ministers
- Seen the Royal Kram NS/RKM/1206/035 dated 29 of December 2006 promulgating the Law on Finance for Management of Fiscal Year 2007
- Seen the Royal Kram 03/NS/94 dated 05 Of August 1994 promulgating the Law on Investment of Kingdom of Cambodia and the Law on Amendment of Law on Investment of Kingdom of Cambodia promulgated by the Royal Kram NS/RKM/0303/009 dated 24 of March 2003
- Seen Sub-decree 111 អនក្រ.បក dated 27 of September 2005 on Implementation of the Law on Amendment of Law on Investment of Kingdom of Cambodia

The Royal Government

Delegates herewith to H.E. Mr. KEAT CHHON, Senior Minister, Minister of Economy and Finance, full power to sign the Implementation Agreement (IA), and the Form of Government Guarantee of Payment by the EDC to YUNNAN SOUTHEAST-ASIA ECONOMY AND TECHNOLOGY INVESTMENT INDUSTRIAL CO., LTD., for the Development of Phnom Penh-Battambang Transmission System BOT Project.

In witness whereof the undersigned, the Prime Minister of the Kingdom of Cambodia with full powers duly entrusted to him, has signed this delegation of full powers.

Phnom Penh, February 16 , 2007

Prime Minister

HUN SEN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០០១....សហវ....

ភ្នំពេញ.ថ្ងៃទី១៦ ខែ ខែ្ឆ ឆ្នាំ ២០០៧

លិខិតធានារបស់រាជរដ្ឋាភិបាលលើការធានាត់

ជូនចំពោះ : លោកប្រធានក្រុមហ៊ុន YUNNAN SOUTHEAST-ASIA ECONOMY AND TECHNOLOGY INVESTMEN INDUSTRIAL CO LTD
ផ្ទះលេខ ១០ ផ្លូវ Ling Guang ទីក្រុង Kunming ខេត្ត Yunnan
សាធារណរដ្ឋប្រជាមានិតចិន

យោង :

(ក) សិទ្ធិប្រទាន លេខ ១៦ សប្រទ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ដោយសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា (ភ្ជាប់ជាមួយនូវលិខិតសិទ្ធិប្រទានក្នុងឧបសម្ព័ន្ធ១)។

(ខ) **កិច្ចព្រមព្រៀងអនុវត្តគំរោង** (IA) ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ដែលបានចុះហត្ថលេខារវាង រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ **រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** «ក្រ ឧ រ៉ែ ថ» និង **ក្រុមហ៊ុន** YUNNAN SOUTHEAST-ASIA ECONOMY AND TECHNOLOGY INVESTMENT INDUSTRIAL CO LTD «**ក្រុមហ៊ុន**» ។

(គ) **អគ្គិសនីកម្ពុជា** «**អក**» ជាសហគ្រាសរដ្ឋ ដែលមានការទទួលខុសត្រូវមានកំណត់បានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ជស/តក/០៣៩៦/១០ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៦ មានការិយាល័យធំរបស់ខ្លួនតាំងនៅផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នកបន្តវេន និងអ្នកដែលបានអនុញ្ញាតអោយទទួលសិទ្ធិ «**អក**» ដែលបានចុះកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី (PTA) ជាមួយ **ក្រុមហ៊ុន** YUNNAN SOUTHEAST-ASIA ECONOMY AND TECHNOLOGY INVESTMENT INDUSTRIAL CO LTD «**ក្រុមហ៊ុន**» ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

(ឃ) **រាជរដ្ឋាភិបាលកម្ពុជា** យល់ព្រមផ្តល់ : (១)-ការធានាការទូទាត់ថ្លៃប្រើប្រាស់ខ្សែបញ្ជូនអគ្គិសនី ១០០% នៃគំរោង ក្នុងករណីដែល **អគ្គិសនីកម្ពុជា** មិនធ្វើការទូទាត់ និង (២)-ការធានាទិញមធ្យោបាយគំរោង ដោយបញ្ចប់កិច្ចព្រមព្រៀង ស្របតាម **កិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី** និង/ឬ **កិច្ចព្រមព្រៀងអនុវត្តគំរោង** និងក្នុងករណីដែល «**ក្រុមហ៊ុន**» មិនអាចដំណើរការមធ្យោបាយខ្សែបញ្ជូនរបស់ខ្លួនបាន ដោយកើតចេញពីព្រឹត្តិការណ៍ប្រធានសក្តិ ផ្នែកនយោបាយ។

(ង) តាមការតម្រូវក្នុងផ្នែក ៤.៣ នៃកិច្ចព្រមព្រៀងអនុវត្តគំរោង **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ជំនួសមុខអោយរាជរដ្ឋាភិបាលកម្ពុជា (**អ្នកធានា**) បានយល់ព្រមចុះហត្ថលេខាលើលិខិតធានាការទូទាត់របស់ «អក» / «ក្រុ ខ្ញុំ ២» ស្របតាមកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី និងកិច្ចព្រមព្រៀងអនុវត្តគំរោង។

ដូច្នេះយើងខ្ញុំសូមធានា ថា:

១. **អ្នកធានា** ធានានិងសន្យាដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធទូទាត់អោយ «**ក្រុមហ៊ុន**» នូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ដែលត្រូវបង់ និងជំពាក់ដោយ «អក» / «ក្រុ ខ្ញុំ ២» អោយ «**ក្រុមហ៊ុន**» ស្របតាមកិច្ចព្រមព្រៀងអនុវត្តគំរោង ឬកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី ដែល «ក្រុ ខ្ញុំ ២» ឬ «អក» ខកខានពុំបានទូទាត់ អនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងអនុវត្តគំរោង ឬកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី។

២. លិខិតធានានេះត្រូវជាការធានាថា បន្តរហូត និងអោយបានសមស្រប និងត្រូវទូទាត់តុល្យការទឹកប្រាក់ ដែលត្រូវបង់អោយ «**ក្រុមហ៊ុន**» គ្រប់ពេលដោយ «ក្រុ ខ្ញុំ ២» ឬ «អក» ស្របតាមកិច្ចព្រមព្រៀងអនុវត្តគំរោង ឬកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី ទោះជាមានលិខិតជូនដំណឹងណាមួយពីការបញ្ចប់កិច្ចព្រមព្រៀង ការរំលាយ ឬអសមត្ថភាព ឬការផ្លាស់ប្តូរណាមួយក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង «ក្រុ ខ្ញុំ ២» ឬ «អក» ឬក្នុងនាម ឬរបៀប ឬការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ។

៣. មុនពេលឈានដល់អនុវត្តលិខិតធានានេះ និងតម្រូវការការទូទាត់ពី **អ្នកធានា** «**ក្រុមហ៊ុន**» ត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរសំរាប់ការទូទាត់ពី «ក្រុ ខ្ញុំ ២» ឬ «អក»។ ក្រោយទទួលវិក្កយប័ត្រ ៦០ (ហុកសិប) ថ្ងៃ ដូចមានចែងក្នុងផ្នែកទី ១១.១ នៃកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី ឬសំណើទូទាត់ណាមួយពី «**ក្រុមហ៊ុន**» ទៅ «ក្រុ ខ្ញុំ ២» ឬ «អក» «**ក្រុមហ៊ុន**»អាចជូនដំណឹងទៅ **អ្នកធានា** ជា

ទំព័រទី ២ នៃ ៨

លាយលក្ខណ៍អក្សរថា ការទូទាត់ដោយ «**ក្រុ ខ្ញុំ រ៉ ៥**» ឬ «**អក**» បានហួសកាលកំណត់ និងលើកសំណើទូទាត់ពី **អ្នកធានា** ស្របតាមលិខិតធានានេះ ហើយ **អ្នកធានា** ត្រូវធ្វើការទូទាត់ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ។ ការយឺតយ៉ាវក្នុងការទូទាត់របស់ **អ្នកធានា** ក្រោមកិច្ចព្រមព្រៀងនេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ប្រចាំឆ្នាំ LIBOR បូកនឹង ៣% (បីភាគរយ)។ ហើយពុំមានសំណើណាដែលបានធ្វើឡើងដោយ «**ក្រុមហ៊ុន**» ស្របតាមកិច្ចព្រមព្រៀងនេះ ដែលប៉ះពាល់ ឬជំទាស់សិទ្ធិរបស់ «**ក្រុមហ៊ុន**» ក្នុងករណីសំណើបន្ថែម ឬផ្សេងទៀត ចំពោះវិក្កយប័ត្រមិនបានទូទាត់ផ្សេងទៀត។ ទឹកប្រាក់ទាំងអស់ដែល **អ្នកធានា** ត្រូវទូទាត់អោយ តាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែល «**ក្រុមហ៊ុន**» បានកំណត់ជាដុល្លាអាមេរិកអោយ «**ក្រុមហ៊ុន**»។

៤. រាល់ការធ្វើសំណើទូទាត់ណាមួយដោយអនុលោមតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នកផ្ញើសំបុត្រ ឬតាមរយៈបុគ្គលដែលជាមន្ត្រីទទួលបានការអនុញ្ញាតស្របច្បាប់របស់ «**ក្រុមហ៊ុន**» នៅការិយាល័យរបស់ **អ្នកធានា** និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រីដែលបានទទួលការអនុញ្ញាតស្របច្បាប់របស់ «**ក្រុមហ៊ុន**» ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀតដោយបញ្ជាក់ថា : (ភ្ជាប់ជាមួយនូវគំរូលិខិតសំណើទូទាត់ពីអ្នកធានាក្នុងឧបសម្ព័ន្ធ ២)។

៥. **អ្នកធានាសូមអះអាង និង ធានា** នៅថ្ងៃនេះថា :

អ្នកធានា មានសិទ្ធិអំណាច និងការអនុញ្ញាតស្របច្បាប់ ដើម្បីអនុវត្ត និងប្រគល់ ព្រមទាំងប្រតិបត្តិតាមលក្ខខណ្ឌនៃលិខិតធានានេះ។

លិខិតធានានេះ ជាកាតព្វកិច្ចស្របច្បាប់មានសុពលភាព និងប្រសិទ្ធភាព និងជាឯកសារចំណងដែល **អ្នកធានា** ត្រូវអនុវត្តអនុលោមតាមលក្ខខណ្ឌរបស់វា។

រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការអនុវត្តន៍ត្រូវបានទទួល ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការអនុវត្តន៍ ការផ្គត់ផ្គង់ និងការប្រតិបត្តិ លិខិតធានានេះ។

កាតព្វកិច្ច និងកិច្ចព្រមព្រៀងនានារបស់ **អ្នកធានា** ក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានលក្ខខណ្ឌរបស់ **អ្នកធានា** ដើម្បីអនុវត្តកាតព្វកិច្ចទាំងនេះ សំរាប់ផ្តល់ការជឿទុកចិត្ត និងកិត្តិយសរបស់ **អ្នកធានា**។

អ្នកធានា បានយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធថា ការអនុវត្តន៍ និងការផ្តល់ជូនដោយ **អ្នកធានា** តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពជាសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ ជាកាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ។

ប្រសិនបើមានបណ្តឹងណាមួយចំពោះ **អ្នកធានា** ឬចំពោះទ្រព្យសម្បត្តិរបស់គេ ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងកិច្ចព្រមព្រៀងនេះ មិនមានអភ័យឯកសិទ្ធិណាពីបណ្តឹងត្រូវបានទាមទារដោយ ឬតាងនាមរបស់ខ្លួនឬទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់គេដែលមានបច្ចុប្បន្ន ឬអាចទទួលបាននាពេលអនាគត។

៦. លិខិតធានានេះត្រូវមានសុពលភាព និង ប្រសិទ្ធភាពចាប់ពីថ្ងៃចាប់ផ្តើមដំណើរការសាងសង់ រហូតដល់បញ្ចប់អាណត្តិនៃកិច្ចព្រមព្រៀងអនុវត្តគំរោង ឬកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី និងបន្តពេលយូរតទៅទៀត តាមចំនួនទឹកប្រាក់ជំពាក់ណាមួយដែល «អអក» ជំពាក់ «ក្រុមហ៊ុន» ទាក់ទងនឹងលក្ខខណ្ឌ ឬនៅពុំទាន់សង។ ប៉ុន្តែទោះបីយ៉ាងណា ក្នុងករណីនៃការធានាការទូទាត់ថ្លៃប្រើប្រាស់ខ្សែបញ្ជូនអគ្គិសនី ក្នុងករណីដែលអគ្គិសនីកម្ពុជាពុំបានទូទាត់លិខិតធានានេះ ត្រូវបានប្រសិទ្ធភាពចាប់ពីថ្ងៃដំណើរការអាជីវកម្មនៃគំរោង (ដូចដែលបានកំណត់នៅក្នុងទំព័រទី ៦៤ ក្នុងកម្មវិធីទី១ នៃ PTA)។

៧. មិនយកការខកខាន ឬ ការយឺតយ៉ាវណាឡើយដោយ «ក្រុមហ៊ុន» ក្នុងការអនុវត្តន៍សិទ្ធិ ឬការដោះស្រាយណាមួយក្រោមការធានានេះជាការបដិសេធ ឬដោះស្រាយឡើយ។ គ្មានការអនុវត្តន៍សិទ្ធិ ឬការដោះស្រាយដោយភាគីមួយ ឬការអនុវត្តន៍សិទ្ធិមួយផ្នែក ច្រានចោលការអនុវត្តន៍បន្ថែមផ្សេងទៀត ឬការអនុវត្តន៍សិទ្ធិ ឬការដោះស្រាយណាមួយផ្សេងទៀត។ ការបដិសេធរបស់ «ក្រុមហ៊ុន» មានប្រសិទ្ធភាពលុះត្រាតែការបដិសេធធ្វើឡើងជាលាយលក្ខណ៍អក្សរ។

សិទ្ធិ និងការដោះស្រាយនានា បានផ្តល់ឱ្យរបស់ «ក្រុមហ៊ុន» ដោយការធានានេះ គឺជាការផ្តល់បន្ថែម និងមិនលើកលែងសិទ្ធិ និងការដោះស្រាយណាមួយ ដែលបានផ្តល់ដោយច្បាប់។

៨. រាល់លិខិតជូនដំណឹង ឬលិខិតឆ្លងឆ្លើយផ្សេងៗទៀត (ដែលបន្ទាប់ពីនេះទៅត្រូវហៅរួមគ្នាថា «**លិខិតជូនដំណឹង**») ដែលត្រូវផ្តល់ឬធ្វើឡើង ក្នុងកិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរនិងត្រូវបញ្ជូនទៅបុគ្គលដូចខាងក្រោម ដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមប្រៃសណីយ៍។ រាល់លិខិតជូនដំណឹងត្រូវបានចាត់ទុកថាបានប្រគល់:

(ក) ពេលប្រគល់ផ្ទាល់ដៃ ឬ

(ខ) នៅពេលប្រគល់មានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួលដោយអ្នកផ្ញើឯកសារអន្តរជាតិ ដែលមានការទទួលស្គាល់បញ្ជូនទៅភាគីដែលបានទទួលទៅអាសយដ្ឋាន ដូចខាងក្រោម (ឬក៏អាសយដ្ឋានដទៃទៀតដូចជាភាគីនោះ អាចកំណត់ដោយលិខិតជូនដំណឹងឱ្យទៅភាគីប្រគល់លិខិតតាមអាសយដ្ឋាន ឬលេខទូរសារថែងខាងក្រោម)៖

អាសយដ្ឋានសំរាប់ផ្ញើលិខិតជូនដំណឹងគឺ៖

សំរាប់ **អ្នកធានា** :

ជូនចំពោះ : **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អាសយដ្ឋាន : ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរសារលេខ : ៨៥៥-២៣-៤២៧ ៧៩៨

សំរាប់ **ក្រុមហ៊ុន** YUNNAN SOUTHEAST-ASIA ECONOMY AND TECHNOLOGY INVESTMENT INDUSTRIAL CO LTD:

ជូនចំពោះ : **លោកប្រធានក្រុមហ៊ុន** YUNNAN SOUTHEAST-ASIA ECONOMY AND TECHNOLOGY INVESTMENT INDUSTRIAL CO LTD

អាសយដ្ឋាន : ផ្ទះលេខ ១០ ផ្លូវ Ling Guang ទីក្រុង Kunming ខេត្ត Yunnan សាធារណរដ្ឋប្រជាមានិតចិន

ទូរសារលេខ : ៨៦- ៨៧១- ៥១២ ២៣៣៧

ឬក៏អាសយដ្ឋានផ្សេងទៀតដូចដែលភាគីណាមួយអាចជូនដំណឹងឱ្យភាគីណាមួយ។

៩. **អ្នកធានា** មិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬភាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ ដោយគ្មានការអនុញ្ញាតជាមុនពី «**ក្រុមហ៊ុន**» ឡើយ ហើយ «**ក្រុមហ៊ុន**» មិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬភាតព្វកិច្ចទាំងអស់ ឬ មួយផ្នែករបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងនេះ ដោយគ្មានការអនុញ្ញាតជាមុនពី **អ្នកធានា** ឡើយ។ ថ្វីបើមានបញ្ញត្តិក្នុងវាក្យខណ្ឌមុននេះសំរាប់គោលបំណងអភិវឌ្ឍន៍ឬផ្តល់ហិរញ្ញប្បទានជាអចិន្ត្រៃយ៍របស់គំរោង «**ក្រុមហ៊ុន**» ត្រូវប្រគល់ ឬបង្កើតការធានាផលប្រយោជន៍ចំពោះសិទ្ធិផលប្រយោជន៍របស់ខ្លួន និងសំរាប់អ្នកឱ្យខ្ចីប្រាក់។

លិខិតធានានេះត្រូវជាចំណងផ្លូវច្បាប់ និងមានអត្ថប្រយោជន៍ដល់ **អ្នកធានា** និង **«ក្រុមហ៊ុន»** ព្រមទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិស្របច្បាប់របស់ភាគីមួយៗ។

១០. សិទ្ធិ និងកាតព្វកិច្ចរបស់ **អ្នកធានា** និង **«ក្រុមហ៊ុន»** អនុលោមតាមលិខិតធានានេះ ត្រូវបានគ្រប់គ្រង និងបកស្រាយតាមច្បាប់ប្រទេសអង់គ្លេស ដែលនឹងត្រូវជាច្បាប់គ្រប់គ្រងនីតិវិធីមជ្ឈត្តវិនិច្ឆ័យផង។

ប្រសិនបើមានវិវាទ ឬ ការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធទៅនឹងលិខិតធានានេះ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីភាគីមួយបានទទួលសេចក្តីជូនដំណឹងពីភាគីមួយទៀត ស្តីពីការកើតឡើងនៃវិវាទ **អ្នកធានា** និង **«ក្រុមហ៊ុន»** ត្រូវសាកល្បងដោះស្រាយវិវាទនោះ តាមរយៈការពិភាក្សាជាមិត្តភាព។ ប្រសិនបើមិនអាច ដោះស្រាយបានតាមរយៈការពិភាក្សាជាមិត្តភាពទេ គេត្រូវដាក់វិវាទនោះទៅមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ ដើម្បីដោះស្រាយស្របទៅតាមវិធាននៃមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ។ ប្រសិនបើមានភាពមិនស្របគ្នាដោយអន្លើ រវាងមាត្រានេះ និងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ មាត្រានេះត្រូវ មានប្រសិទ្ធភាព។ សេចក្តីសំរេចត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយគឺជាសេចក្តីសំរេចស្ថាពរ និងមានប្រសិទ្ធភាពទៅលើ **អ្នកធានា** និង **«ក្រុមហ៊ុន»** និងអាចយកមកអនុវត្តនៅក្នុងតុលាការកម្ពុជាណាមួយ ដែលមានយុត្តាធិការធ្វើឱ្យសេចក្តីសំរេចនេះអនុវត្តបាន។ ភាគីទាំងនោះត្រូវអនុវត្តសេចក្តីសំរេចនេះ ហើយភាគីនីមួយៗមិនអាចបដិសេធដោយកែប្រែកែកបាននូវសិទ្ធិណាមួយដែលគេមាន ដើម្បីតវ៉ាអំពីសុពលភាពនៃសេចក្តីសំរេចនេះ ឬយុត្តាធិការនៃតុលាការមជ្ឈត្តវិនិច្ឆ័យ ដើម្បីធ្វើសច្ចការឯកសារយោងណាមួយទៅមជ្ឈត្តវិនិច្ឆ័យ ដែលបានលិខិតធានានេះ។ ការទូទាត់តាមសេចក្តីសំរេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវធ្វើជា **ដុល្លារអាមេរិក**។ ចំណាយលើមជ្ឈត្តវិនិច្ឆ័យ ត្រូវទូទាត់ដោយភាគីដែលចាញ់ក្តី លើកលែងតែមានកំណត់ផ្សេងពីនេះ ដោយតុលាការមជ្ឈត្តវិនិច្ឆ័យនោះ។ ភាគីដែលទទួលខុសត្រូវការទូទាត់សេចក្តីសំរេច របស់មជ្ឈត្តវិនិច្ឆ័យ ត្រូវបង់ការប្រាក់តាមអាត្រា LIBOR បូក ៣% (បីភាគរយ) ទៅឱ្យភាគីម្ខាងទៀត នៅពេលទទួលសេចក្តីសំរេចពីមជ្ឈត្តវិនិច្ឆ័យនោះ ក្នុងកាលបរិច្ឆេទសមស្រប រហូតដល់ថ្ងៃទូទាត់រួច។

១១. ពាក្យសរសេរជាអក្សរធំដែលប្រើ ប៉ុន្តែពុំមានកំណត់ក្នុងលិខិតធានានេះ ត្រូវមានន័យដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងបញ្ចូនអគ្គិសនី។ ប្រសិនបើបញ្ញត្តិមួយ ឬច្រើន ដែលមានក្នុងលិខិតធានានេះ ត្រូវបានរកឃើញថាគ្មានសុពលភាព ខុសច្បាប់ ឬ គ្មានតម្លៃតាមផ្លូវច្បាប់ ត្រូវផ្តល់សុពលភាពដល់បញ្ញត្តិតាមផ្លូវច្បាប់ ហើយអសុពលភាព ភាពខុសច្បាប់ ឬភាពគ្មានតម្លៃតាមផ្លូវច្បាប់ នៃបញ្ញត្តិនោះ ពុំមានឥទ្ធិពលដល់សុពលភាពនៃបញ្ញត្តិសេសសល់ផ្សេងទៀត នៃលិខិតធានានេះ។

តាមការឯកភាពគ្នាទៅវិញទៅមក គ្មានការទូទាត់ ការប្តឹងទាមទារ ការបន្ទុរបន្ទុយ ឬការបន្ថយកាតព្វកិច្ចណាមួយដែល អ្នកធានា មាន ឬអាចមានចំពោះ «ក្រុមហ៊ុន» ត្រូវតែមានសំរាប់ អ្នកធានា ចំពោះ «ក្រុមហ៊ុន» ទាក់ទងនឹងកាតព្វកិច្ចណាមួយ របស់អ្នកធានា ចំពោះ «ក្រុមហ៊ុន» ស្របតាមលិខិតធានានេះ។

១២ លិខិតធានានេះ ត្រូវផុតកំណត់នៅពេលបញ្ចប់កិច្ចព្រមព្រៀងអនុវត្តគំរោង និងកិច្ចព្រមព្រៀងបញ្ចូនអគ្គិសនីដែរ ប្រសិនបើគ្មានការតវ៉ា ហើយនៅរក្សាការធានាតាមនេះឲដែល ហេតុដូច្នេះ យើងខ្ញុំត្រូវតែទទួលបានមុនពេលផុតកំណត់នេះ នូវការស្នើសុំជាលាយលក្ខណ៍អក្សរណាមួយ ពីលោកមកយើងខ្ញុំពីបញ្ហានេះ។

១៣. លិខិតធានានេះ នឹងចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្តទៅបាន បន្ទាប់ពីទទួលបានការអនុម័តពីស្ថាប័ននីតិបញ្ញត្តិ។

សូមលោកមេត្តាទទួលនូវការស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

នេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ជូសមុខ និងកាងនាមរាជរដ្ឋាភិបាលកម្ពុជា

គាត ឈន់

ចម្លងជូន:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក)
-ក្រុមហ៊ុនអគ្គិសនីកម្ពុជា (អ.ក)
-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ២

គំរូលិខិតសំណើទូទាត់ពីអ្នកធានា

យើងខ្ញុំសូមបញ្ជាក់ថា :

(១) ក្រុមហ៊ុន «ក្រុមហ៊ុន»បានធ្វើសំណើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ «អ្នកធានា» ក្នុងចំនួនទឹកប្រាក់ .... {បញ្ចូលចំនួនទឹកប្រាក់} ជាដុល្លាអាមេរិក ស្របតាមលិខិតធានា របស់រាជរដ្ឋាភិបាលលើការទូទាត់ ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ២០០៧ រវាង «អ្នកធានា» និង «ក្រុមហ៊ុន»។

(២) ចំនួនទឹកប្រាក់កំណត់ខាងលើ គឺដល់ពេលត្រូវទូទាត់ដោយ «ក្រុមហ៊ុនអគ្គិសនីកម្ពុជា» ឬ «អអក» ស្របតាមកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី/កិច្ចព្រមព្រៀងអនុវត្តគំរោងរវាង «ក្រុមហ៊ុន» និង «ក្រុមហ៊ុនអគ្គិសនីកម្ពុជា» ឬ «អអក» និងពុំមានផ្នែកណានៃចំនួនទឹកប្រាក់ដែលបានបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃជម្លោះរវាង «ក្រុមហ៊ុនអគ្គិសនីកម្ពុជា» / «អអក» និង «ក្រុមហ៊ុន»។

(៣) សំណើទូទាត់ពី «ក្រុមហ៊ុនអគ្គិសនីកម្ពុជា» / «អអក» ជាលាយលក្ខណ៍អក្សរ បានធ្វើជាស្រេចហើយ។

(៤) ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ «ក្រុមហ៊ុនអគ្គិសនីកម្ពុជា» / «អអក» រហូតដល់ថ្ងៃនេះ។

ហត្ថលេខា

តំណាង «ក្រុមហ៊ុន»

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

№ 001 MEF/..............

GOVERNMENT GUARANTEE OF PAYMENTS

MR. CHAIRMAN
YUNNAN SOUTHEAST-ASIA ECONOMY AND
TECHNOLOGY INVESTMENT INDUSTRIAL CO., LTD
No: 10, St. Ling Guang,
Kunming, Yunnan Province
People's Republic of China

Phnom Penh, March 16. 2007

Dear Sir.

We refer to:

(A) Delegation of Full Power No. 16 DFP dated 16 February 2007 by Samdech Hun Sen, Prime Minister of the Royal Government of Cambodia (RGC). (**Please see attachment 1)**

(B) The Implementation Agreement ("IA") dated 16 February 2007, entered between the Royal Government of Cambodia ("RGC") represented by Minister of Ministry of Industry, Mines and Energy ("MIME") and YUNNAN SOUTHEAST-ASIA ECONOMY AND TECHNOLOGY INVESTMENT INDUSTRIAL CO., LTD (the "Company").

(C) ELECTRICITÉ DU CAMBODGE, a wholly state-owned limited liability enterprise incorporated by Royal Decree No. CHS/RD/0396/10 of the RGC dated 9 March 1996, with its principal office located at Street 19, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, in the Kingdom of Cambodia, including its successors and permitted assignees ("EDC") has entered into a Power Transmission Agreement ("PTA") with the Company dated 16 February 2007.

(D) The Royal Government of Cambodia agreed to provide: (i) guarantee on the payment for PTA charges for use of 100% of the Project in the event of non-payment by EDC; and (ii) guarantee on the payment on the termination in accordance with PTA and/or IA in the event that the Company is unable to operate the Project arising from the Political Force Majeure Events.

(E) It is a requirement of the Implementation Agreement in accordance with Section 4.3 of the IA, the Minister of Economy and Finance ("MEF") on behalf of Royal Government of Cambodia (the "Guarantor") has agreed to enter into this Guarantee of the payment obligations of EDC/MIME under the PTA and IA.

We hereby guarantee that:

1. The Guarantor hereby irrevocably and unconditionally guarantees and promises to pay to the Company any and every sum of money which is due and owed by MIME or EDC to the Company under the IA or PTA that MIME or EDC has failed to pay in accordance with the terms of the IA or PTA.

2. This Guarantee shall be a continuing security and accordingly, shall extend to cover the balance due to the Company at any time from MIME or EDC under the IA or PTA, notwithstanding any notice of termination or the liquidation or other incapacity or any change in Royal Decree concerning MIME or EDC or in the name or style thereof or any settlement of account or other matter whatsoever.

3. Before taking steps to enforce this Guarantee and demand payment from the Guarantor, the Company shall be obliged only to make demand in writing for payment from MIME or EDC. After sixty (60) Days from the date of the invoice(s) as specified in Section 11.1 of the PTA or any payment demand from the Company to MIME being received by EDC or MIME, the Company may notify the Guarantor in writing that payment from MIME or EDC is overdue and make a demand for payment from the Guarantor under this Guarantee, and the Guarantor shall make payment within 30 (thirty) Days. The Guarantor's late payment hereunder shall bear interest at an annual rate of LIBOR plus 3% (three percent) And no demand made by the Company hereunder shall prejudice or restrict the right of the Company to make further or other demands against any other unpaid invoice(s)

   All sums payable by the Guarantor under this Guarantee shall be fully paid to the bank account designated by the Company in the Kingdom of Cambodia in US Dollars to the Company.

4. Any demand for payment made pursuant to this Guarantee shall be made by courier or in person by a duly authorized officer of the Company at the Guarantor's offices and shall be accompanied by a certificate signed by a duly authorized officer of the Company stating, without the obligation to substantiate. that: **(Please see attachement 2)**

5. The Guarantor represents and warrants that, as of the date hereof:

   - The Guarantor has full power, authority, and legal right to incur the obligation, to execute and deliver, and to perform and observe the terms and provisions of this Guarantee.
   - This Guarantee constitutes legal, valid, binding, and enforceable obligations of the Guarantor in accordance with its terms.
   - All necessary action has been taken, and all approvals required have been obtained, under the Laws of the Kingdom of Cambodia to authorize the execution, delivery, and performance of this Guarantee.
   - The obligations and covenants of the Guarantor in this Guarantee constitute unconditional obligations of the Guarantor, for the performance of which the full faith and credit of the Guarantor is pledged.
   - The Guarantor unconditionally and irrevocably agrees that the execution, delivery, and performance by it of this Guarantee constitute commercial acts

rather than public or governmental acts and such Guarantee constitutes our unconditional and irrevocable direct obligation.
Should any proceedings be brought against it or its assets in any jurisdiction in relation to this Agreement, no immunity from such proceedings shall be claimed by or on its behalf or with respect to its assets which it now has or may acquire in the future.

6. This Guarantee shall remain in full force and effect from the Construction Commencement Date until the termination of the term of the IA or PTA and for so long thereafter as any amount owed to the Company by EDC in connection with such term is or may be outstanding. However, such Guarantee on PTA Charges in the event of non-payment by EDC for the use of capacity of the Project shall be applicable from the Commercial Operation Date (COD), as definition stipulated in Page 64, Schedul I of PTA of the Project.

7. No failure or delay by the Company to exercise any right or remedy under this Guarantee shall constitute a waiver of that right or remedy. No single or partial exercise of any right or remedy shall preclude any other or further exercise thereof or the exercise of any other right or remedy. No waiver by the Company shall be effective unless it is in writing.

   The rights and remedies of the Company provided by this Guarantee are cumulative and not exclusive of any rights or remedies provided by law.

8. All notices or other communications (together "Notices") to be given or made hereunder shall be in writing, shall be addressed for the attention of the person indicated below and shall be delivered personally or by courier. All Notices shall be deemed delivered:
   (a) When presented personally, or
   (b) Upon the day of duly recorded and receipted delivery by a recognized international document courier, addressed to the receiving Party, at the address indicated below (or such other address as such Party may have specified by notice delivered to the delivering Party at its address or facsimile number specified below).

   The address for service of Notice shall be:

For the Guarantor:

Attention:	H E Minister, Ministry of Economy and Finance
Address:	Ministry of Economy and Finance Street No.92, Sangkat Wat Phnom Khan Daun Penh, Phnom Penh Kingdom of Cambodia
Facsimile:	855 23 427798

For the "Company":

Attention:	Chairman's Office YUNNAN SOUTHEAST-ASIA ECONOMY AND TECHNOLOGY INVESTMENT INDUSTRIAL CO., LTD.
Address:	No.10, St. Ling Guang, Kunming, Yunnan Province
Facsimile:	86-871-512 2337
Telephone:	86-871-354 5885

or such other addresses as either Party may have notified to the other Party.

9. The Guarantor shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of The Company, and

The Company shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Guarantor. Notwithstanding the provision of the immediately preceding sentence, for the purpose of development or permanent financing of the Project, The Company may assign or create a security interest over its rights and interests in and to this Guarantee in favor of the Lenders.

This Guarantee shall be binding upon and inure to the benefit of the Guarantor and The Company and the respective successors and permitted assignees of each Party.

10. The rights and obligations of the Guarantor and the Company under or pursuant to this Guarantee shall be governed by and construed according to the Laws of England, which shall also be the procedural law governing any arbitration.

If there is any dispute or difference of any kind whatsoever arising out of or in connection with this Guarantee, the Guarantor and The Company shall attempt for a period of thirty (30) days after the receipt by one Party of a notice from the other Party of the existence of the dispute to settle such dispute through mutual amicable discussions. Should such dispute can't be resolved through mutual amicable discussions, then it shall be submitted to the Singapore International Arbitration Center for arbitration in accordance with the arbitration rules of the Singapore International Arbitration Center. And if there are discrepancies between this clause and the rules of the Singapore International Arbitration Center, this clause shall govern The award rendered shall be in writing and shall be final, conclusive and binding upon the Guarantor and The Company and award thereon may be entered in any Cambodian court having jurisdiction for its enforcement. Such Parties shall execute and perform the award and each Party hereby irrevocably waives any right it may have to contest the validity of such award or the jurisdiction of the arbitration tribunal to hear any reference to arbitration to which this Guarantee applies. Any payment under arbitration award shall be payable in U.S. Dollars. The costs of arbitration shall be borne by the losing Party, unless otherwise determined by the arbitration tribunal. The Party that is responsible to pay an arbitration award shall pay interest at a rate of LIBOR plus 3% (three percent) to the other Party in receipt of such arbitration award from the due date for the payment of such award until the date of payment of such award.

11. The capitalized terms used but not defined in this Guarantee shall have the meanings given to them in the Power Transmission Agreement.

If one or more provisions contained in this Guarantee is held or found to be invalid, illegal, or unenforceable in any respect, the provision(s) shall be given effect to the extent permitted by law and the invalidity, illegality, or unenforceability of any provision shall not affect the validity of the remaining provisions of this Guarantee.
Subject to mutual agreement, no set-off, counterclaim, reduction, or diminution of any obligation that the Guarantor has or may have against The Company shall be available to the Guarantor against The Company in connection with any obligation of the Guarantor to The Company under this Guarantee.

12. This Guarantee shall expire upon the termination of the IA and PTA if no claim has been made and remains outstanding hereunder and any written demand made to us by your hereunder must therefore be received by us before that time.

13. This Guarentee shall become in Full force and effect on its ratification by legislatures of the Kingdom of Cambodia.

Please accept, Mr. Chairman, the assurances of my high consideration.

Keat Chhon
Sr. Minister
Minister of Economy and Finance
Acting on behalf of Royal Government of Cambodia

CC:

- Ministry of Royal Palace
- Secretariat of Senate
- Secretariat of National Assembly
- Council of Ministers
- Ministry of Foreign Affairs and International Cooperations
- Ministry of Industry Mine and Energy
- Cabinet of Semdech Prime Minister
- Council for the Development of Cambodia (CDC)
- Electricite du Cambodge (EDC)
- File

ATTACHEMENT : 2

SAMPLE OF CLAIM FORM FOR PAYMENT FROM THE GUARANTOR

Attention: **HE. Minister of Economy and Finance**
Address: Ministry of Economy and Finance
Street No.92 Sankat Wat Phnom
Khan Daun Penh, Phnom Penh
Kingdom of Cambodia.

Facsimile: 855 23 427798

"We hereby certify that:

(1) YUNNAN SOUTHEAST–ASIA ECONOMY AND TECHNOLOGY INVESTMENT INDUSTRIAL CO LTD, (the "Company") is making this demand on the Ministry of Economy and Finance (the "Guarantor") in the amount of U. S. Dollars --------- [insert amount] in accordance with Section 1 of the Guarantee dated -------------, between the Guarantor and the "Company";

(2) The amount specified above is due and payable by [EDC or MIME] under the PTA/IA between the "Company" and EDC/MIME and no part of the amount specified above is the subject of a dispute between the EDC/MIME and the "Company";

(3) Demand in writing for payment from MIME/EDC has been made;

(4) Such amount, on the date hereof, remains unpaid by MIME/EDC."

Sincerly Yours,

Authorised Representative
YUNNAN SOUTHEAST–ASIA ECONOMY AND TECHNOLOGY INVESTMENT INDUSTRIAL CO LTD

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០៧...សហវ.....

ភ្នំពេញ.ថ្ងៃទី១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

លិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់

ជូនចំពោះ : **លោកប្រធានក្រុមហ៊ុន China Yunnan Corporation For International Techno-Economic Co-operation**
ផ្ទះលេខ ៣០២ ផ្លូវ Chun Cheng ទីក្រុង Kunming ខេត្ត Yunnan
សាធារណរដ្ឋប្រជាមានិតចិន

យោង :

(ក) សិទ្ធិប្រទាន លេខ ១៥ សប្រទ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០០៧ ដោយសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា (ភ្ជាប់ជាមួយនូវលិខិតសិទ្ធិប្រទានក្នុងឧបសម្ព័ន្ធ១)។

(ខ) **កិច្ចព្រមព្រៀងអនុវត្តគំរោង** (IA) ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ដែលបានចុះហត្ថលេខារវាង រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ **រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល «ក្រ ឧ រ៉ ថ»** និង **ក្រុមហ៊ុន** China Yunnan Corporation For International Techno-Economic Co-operation «**ក្រុមហ៊ុន**» ។

(គ) **អគ្គិសនីកម្ពុជា «អក»** ជាសហគ្រាសរដ្ឋ ដែលមានការទទួលខុសត្រូវមានកំណត់ បានបង្កើតឡើងដោយ ព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៦ មានការិយាល័យធំរបស់ខ្លួនតាំងនៅផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នកបន្តវេន និងអ្នកដែលបានអនុញ្ញាតអោយទទួលសិទ្ធិ «អក» ដែលបានចុះកិច្ចព្រមព្រៀងទិញលក់អគ្គិសនី (PPA) ជាមួយ **ក្រុមហ៊ុន** China Yunnan Corporation For International Techno-Economic Co-operation operation «**ក្រុមហ៊ុន**» ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧។

(ឃ) **រាជរដ្ឋាភិបាលកម្ពុជា** យល់ព្រមផ្តល់ : (១)-ការធានាការទូទាត់ក្នុងការទិញថាមពលអគ្គិសនី ក្នុងករណីដែល **អគ្គិសនីកម្ពុជា** មិនធ្វើការទូទាត់ និង (២)-ការធានាទិញមធ្យោបាយគំរោង ដោយបញ្ចប់កិច្ចព្រមព្រៀង ស្របតាម **កិច្ចព្រមព្រៀងទិញលក់អគ្គិសនី** និង/ឬ **កិច្ចព្រមព្រៀងអនុវត្តគំរោង** និងក្នុងករណីដែល «**ក្រុមហ៊ុន**» មិនអាចដំណើរការមធ្យោបាយអគ្គិសនីបាន ដោយកើតចេញ ពីព្រឹត្តិការណ៍ប្រធានសក្តិផ្នែកនយោបាយ។

(ង) តាមការតម្រូវក្នុងផ្នែក ៩.៣ នៃកិច្ចព្រមព្រៀងអនុវត្តគំរោង **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ជំនួសមុខអោយរាជរដ្ឋាភិបាលកម្ពុជា (**អ្នកធានា**) បានយល់ព្រមចុះហត្ថលេខាលើលិខិតធានាការទូទាត់របស់ «**អកក**» / «**ក្រុ ខ្ញុំ ថ**» ស្របតាមកិច្ចព្រមព្រៀងទិញលក់អគ្គិសនី និងកិច្ចព្រមព្រៀងអនុវត្តគំរោង។

ដូច្នេះយើងខ្ញុំសូមធានា ថា:

១. **អ្នកធានា** ធានានិងសន្យាដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធទូទាត់អោយ «**ក្រុមហ៊ុន**» នូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ដែលត្រូវបង់ និងជំពាក់ដោយ «**អកក**»/«**ក្រុ ខ្ញុំ ថ**» អោយ «**ក្រុមហ៊ុន**» ស្របតាមកិច្ចព្រមព្រៀងអនុវត្តគំរោង ឬកិច្ចព្រមព្រៀងទិញលក់អគ្គិសនី ដែល «**ក្រុ ខ្ញុំ ថ**» ឬ «**អកក**» ខកខានពុំបានទូទាត់ អនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងអនុវត្តគំរោង ឬកិច្ចព្រមព្រៀងទិញលក់អគ្គិសនី ។

២. លិខិតធានានេះត្រូវជាការធានាថា បន្តរហូត នឹងអោយបានសមស្រប និងត្រូវទូទាត់គុណការទឹកប្រាក់ ដែលត្រូវបង់អោយ «**ក្រុមហ៊ុន**» គ្រប់ពេលដោយ «**ក្រុ ខ្ញុំ ថ**» ឬ «**អកក**» ស្របតាមកិច្ច-ព្រមព្រៀងអនុវត្តគំរោង ឬកិច្ចព្រមព្រៀងទិញលក់អគ្គិសនី ទោះជាមានលិខិតជូនដំណឹងណាមួយពីការបញ្ចប់កិច្ចព្រមព្រៀង ការរំលាយ ឬអសមត្ថភាព ឬការផ្លាស់ប្តូរណាមួយក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង «**ក្រុ ខ្ញុំ ថ**» ឬ «**អកក**» ឬក្នុងនាម ឬរបៀប ឬការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ។

៣. មុនពេលឈានដល់អនុវត្តលិខិតធានានេះ និងតម្រូវការការទូទាត់ពី **អ្នកធានា** «**ក្រុមហ៊ុន**» ត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរសុំរកការទូទាត់ពី «**ក្រុ ខ្ញុំ ថ**» ឬ «**អកក**»។ ក្រោយ ទទួលវិក្កយបត្រ ៦០ (ហុកសិប) ថ្ងៃ ដូចមានចែងក្នុងផ្នែក ៨.៧.១ នៃកិច្ចព្រមព្រៀងទិញលក់អគ្គិសនី ឬសំណើទូទាត់ណាមួយពី «**ក្រុមហ៊ុន**» ទៅ «**ក្រុ ខ្ញុំ ថ**» ឬ «**អកក**» «**ក្រុមហ៊ុន**» អាចជូនដំណឹងទៅ **អ្នកធានា**

ជាលាយលក្ខណ៍អក្សរថា ការទូទាត់ដោយ **«ក្រុមហ៊ុន»** ឬ **«អក»** បានហួសកាលកំណត់ និងលើកសំណើទូទាត់ពី **អ្នកធានា** ស្របតាមលិខិតធានានេះ ហើយ **អ្នកធានា** ត្រូវធ្វើការទូទាត់ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ។ ការយឺតយ៉ាវក្នុងការទូទាត់របស់ **អ្នកធានា** ក្រោមកិច្ចព្រមព្រៀងនេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ប្រចាំឆ្នាំ LIBOR ,បូកនឹង ៣% (បីភាគរយ)។ ហើយពុំមានសំណើណាដែលបានធ្វើឡើងដោយ **«ក្រុមហ៊ុន»** ស្របតាមកិច្ចព្រមព្រៀងនេះ ដែលប៉ះពាល់ ឬជំទាស់សិទ្ធិរបស់ **«ក្រុមហ៊ុន»** ក្នុងករណីសំណើបន្ថែម ឬផ្សេងទៀត ចំពោះវិក្កយប័ត្រមិនបានទូទាត់ផ្សេងទៀត។ ទឹកប្រាក់ទាំងអស់ដែល **អ្នកធានា** ត្រូវទូទាត់អោយតាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែល **«ក្រុមហ៊ុន»** បានកំណត់ជាដុល្លាអាមេរិកអោយ **«ក្រុមហ៊ុន»**។

៤. រាល់ការធ្វើសំណើទូទាត់ណាមួយដោយអនុលោមតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នកវត់សំបុត្រ ឬតាមរយៈបុគ្គលដែលជាមន្ត្រីទទួលបានការអនុញ្ញាតស្របច្បាប់របស់ **«ក្រុមហ៊ុន»** នៅការិយាល័យរបស់ **អ្នកធានា** និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រីដែលបានទទួលការអនុញ្ញាតស្របច្បាប់របស់ **«ក្រុមហ៊ុន»** ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀត ដោយបញ្ជាក់ថា : (ភ្ជាប់ជាមួយនូវគំរូលិខិតសំណើទូទាត់ពីអ្នកធានាក្នុងឧបសម្ព័ន្ធ ២)។

៥. **អ្នកធានាសូមអះអាង និង ធានា** នៅថ្ងៃនេះថា :

អ្នកធានា មានសិទ្ធិអំណាច និងការអនុញ្ញាតស្របច្បាប់ ដើម្បីអនុវត្ត និងប្រគល់ ព្រមទាំងប្រតិបត្តិតាមលក្ខខណ្ឌនៃលិខិតធានានេះ។

លិខិតធានានេះ ជាកាតព្វកិច្ចស្របច្បាប់មានសុពលភាព និងប្រសិទ្ធភាព និងជាឯកសារចំណងដែល **អ្នកធានា** ត្រូវអនុវត្តអនុលោមតាមលក្ខខណ្ឌរបស់វា។

រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការអនុវត្តន៍ត្រូវបានទទួល ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការអនុវត្តន៍ ការផ្គត់ផ្គង់ និងការប្រតិបត្តិ លិខិតធានានេះ។

កាតព្វកិច្ច នឹងកិច្ចព្រមព្រៀងនានារបស់ **អ្នកធានា** ក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានលក្ខខណ្ឌរបស់ **អ្នកធានា** ដើម្បីអនុវត្តកាតព្វកិច្ចទាំងនេះ សំរាប់ផ្តល់ការជឿទុកចិត្ត និងកិត្តិយសរបស់ **អ្នកធានា**។

អ្នកធានា បានយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធថា ការអនុវត្តន៍ និងការផ្តល់ជូនដោយ **អ្នកធានា** តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពជាសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ ជាកាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ។

ប្រសិនបើមានបណ្តឹងណាមួយចំពោះ **អ្នកធានា** ឬចំពោះទ្រព្យសម្បត្តិរបស់គេ ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងកិច្ចព្រមព្រៀងនេះ មិនមានអភ័យឯកសិទ្ធិណាពីបណ្តឹងត្រូវបានទាមទារដោយ ឬតាងនាមរបស់ខ្លួនឬទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់គេដែលមានបច្ចុប្បន្ន ឬអាចទទួលបាននាពេលអនាគត។

៦. លិខិតធានានេះត្រូវមានសុពលភាព និងប្រសិទ្ធភាពចាប់ពីថ្ងៃចាប់ផ្តើមដំណើរការសាងសង់រហូតដល់បញ្ចប់អាណត្តិនៃកិច្ចព្រមព្រៀងអនុវត្តគំរោង ឬកិច្ចព្រមព្រៀងទិញលក់អគ្គិសនីនិងបន្តពេលយូរតទៅទៀត តាមចំនួនទឹកប្រាក់ជំពាក់ណាមួយដែល «អក» ជំពាក់ «ក្រុមហ៊ុន» ទាក់ទងនឹងលក្ខខណ្ឌ ឬនៅពុំទាន់សង។ ប៉ុន្តែទោះបីយ៉ាងណា ក្នុងករណីនៃការធានាទិញថាមពលក្នុងករណីដែលអគ្គិសនីកម្ពុជាពុំបានទូទាត់សំរាប់ថាមពលមូលដ្ឋាន លិខិតធានានេះត្រូវមានប្រសិទ្ធភាព ចាប់ពីថ្ងៃដំណើរការអាជីវកម្មនៃគំរោង (ដូចដែលបានកំណត់នៅក្នុងទំព័រទី ៦៤ ក្នុងកម្មវិធីទី១ នៃ PPA)។

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **ស្វាយ សំអៀង** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៩ ជាអភិបាលរងខេត្តមណ្ឌលគិរី ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចមាត្រា ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៨៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជនសឹង្ហបុរី ចំនួន ០៣រូប ដែលបានឧបត្ថម្ភថវិកា ចំនួន ៤០.០០០ ដុល្លារអាមេរិក សំរាប់ជួយជួសជុល និងលាបអគារសិក្សា ចំនួន ០៩ខ្នង មាន ៥៨បន្ទប់ និង អគារទីចាត់ការ ០១ខ្នង នៅវិទ្យាល័យវត្តកោះ ក្នុងខណ្ឌដូនពេញ រាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម :-

១-Mr.JAMES SOH	Executive Director, Nationale Youth Achievement Award Council Republic of Singapore .
២-Miss.CELINE YEO	President of Singapore 2006 Organization Committee .
៣-លោក ធំ តោះសខ	នាយកក្រុមហ៊ុន VENTURE (CAMBODIA) PTE. LTD .

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៨៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកយាយ **លីសៀម ហៀង** សប្បុរសជនខ្មែរ រស់នៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៤បន្ទប់ បំពាក់ដោយគ្រឿងសង្ហារឹម ធ្វើសួនច្បារ កែលំអទីធ្លា និងធ្វើរបងនៅអនុវិទ្យាល័យព្រះពុទ្ធថ្មកែវ ស្ថិតក្នុងឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ចំណាយអស់ថវិកាចំនួន ២៦.៥៧០ ដុល្លារអាមេរិក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៨៩ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៦៧៩

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី **ROEHLING KIKUKO** ដែលបានឧបត្ថម្ភ ថវិកាចំនួន ៣៤.៣១០ ដុល្លារអាមេរិក សំរាប់ជួយសាងសង់អគារសិក្សា ចំនួន ០១ខ្នង មាន០៥បន្ទប់ បំពាក់ដោយគ្រឿងសង្ហារឹមគ្រប់គ្រាន់ និងបង្គន់អនាម័យ ចំនួន០១ខ្នង មាន០៤បន្ទប់ នៅសាលាបឋមសិក្សាភ្នំដិល ស្ថិតក្នុង ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៩០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការ **JHP** ជប៉ុន ដែលបានផ្តល់ថវិកា ចំនួន ៣០.០៥២ ដុល្លារអាមេរិក សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៤បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន ០៤បន្ទប់ និង អណ្តូងទឹក ០១ ជូនសាលាបឋមសិក្សាតាកែវ ស្ថិតក្នុងភូមិតាកែវក្រោម ឃុំបឹងកន្ទួត ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក SHIGETA YASUMITSU ដែលបានឧបត្ថម្ភថវិកា ចំនួន ៤៦.០១៥ ដុល្លារអាមេរិក សំរាប់សាងសង់អគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បំពាក់ដោយសម្ភារៈគ្រប់ប្រភេទ និង បង្គន់អនាម័យ ០៣បន្ទប់ នៅសាលាបឋមសិក្សាទ្រា ២ ស្ថិតក្នុងឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៩៧ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះសង្ឃ ០១អង្គ និង សប្បុរសជន ០១រូប ដែលបានបរិច្ចាគធនធានជួយកសាង សមិទ្ធផលនានា ដូចជាសាលារៀន ផ្លូវលំ ស្ពាន ព្រះវិហារ ខ្លោងទ្វារ សាលាធម្មសភា សាលាសំណាក់ ។ល។ ស្ថិតក្នុងឃុំចំបក់ និង ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ដូចមានព្រះនាម និងនាមខាងក្រោម :-

១-ព្រះតេជគុណ **ហ៊ួន ម៉ាន់** ចៅអធិការវត្តអង្គសឹង្ហ ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ បច្ច័យចំនួន ៣៨.៦៥០ ដុល្លារ

២-ឧបាសិកា **ឡុង នាង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១២.២០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៥៨៣...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានចំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៣រូប ជាស្ថាបនិកនៃអង្គការ " *ដើម្បីភាពញញឹមនៃកុមារ* " ដែលបានជួយសាងសង់អគារសិក្សា ចំនួន ០២ខ្នង នៅមជ្ឈមណ្ឌលរបស់អង្គការនេះ ដែលមានទីតាំងនៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម :-

១-លោក **CHRISTIAN des PALLIERES**

២-លោកស្រី **MARIE FRANCE des PALLIERES**

២-លោក **FRANCOIS MARION**

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ✕✕

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៧

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៩៤ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **FUJINO** ដែលបានឧបត្ថម្ភថវិកា តាមរយៈអង្គការ **School Aid Japan** មានទឹកប្រាក់ចំនួន ២៧.២៨២ ដុល្លារអាមេរិក សំរាប់សាងសង់ អគារសិក្សា ០១ខ្នង មាន ០៤បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់ នៅ *សាលាបឋមសិក្សាជម្ពូព្រឹក្ស* ក្នុងឃុំជម្ពូព្រឹក្ស ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៩៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត និងប្រើប្រាស់ប័ណ្ណស្ថាបនាជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន ផ្តល់ជូនសប្បុរសជនក្នុង និងក្រៅប្រទេសចំនួន ១៤ រូប ដែលបានបរិច្ចាគបច្ច័យ និងថវិកាផ្ទាល់ខ្លួន ជួយកសាងព្រះវិហារនៅវត្តប្រាសាទពង្រតាជូ ស្ថិតក្នុងឃុំតាជូ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ដូចមានព្រះនាម និងនាមខាងក្រោម :

ក- មេដាយមាសស្ថាបនាជាតិ :

១-លោក **ភឿង ផល**	សប្បុរសជននៅប្រទេសកាណាដា
២-ឧបាសិកា **ឆ្លីម ខាន់**	សប្បុរសជននៅប្រទេសកាណាដា
៣-ឧបាសិកា **ឡៅ សៃយីម**	សប្បុរសជននៅប្រទេសបារាំង
៤-ឧបាសក **តាន់ ភាខ**	សប្បុរសជននៅប្រទេសបារាំង
៥-លោក **ទ៉ោន សាហាក់**	សប្បុរសជននៅសហរដ្ឋអាមេរិក
៦-លោក **ស្ទិន សុទ៉ោន**	សប្បុរសជននៅសហរដ្ឋអាមេរិក
៧-លោក **ឈួស សោភា**	សប្បុរសជននៅខេត្តបន្ទាយមានជ័យ

ខ- មេដាយប្រាក់ស្ថាបនាជាតិ :

១- ព្រះតេជគុណ **ហ៊ុន យូយ**	គង់នៅប្រទេសកាណាដា	
២- ព្រះតេជគុណ **ទៃ លៀស**	ចៅអធិការ វត្តប្រាសាទពង្រគាថូ ឃុំគាថូ ស្រុកស្វាយចេក	
៣- ឧបាសិកា **ម៉ុត ធា**	សប្បុរសជននៅប្រទេសកាណាដា	
៤- លោក **ឡាន មឿន**	សប្បុរសជននៅប្រទេសកាណាដា	
៥- លោក **ឡុត សារឿត**	សប្បុរសជននៅសហរដ្ឋអាមេរិក	
៦- លោក **សាន់ ទិនយ**	សប្បុរសជននៅប្រទេសបារាំង	
៧- លោកស្រី **គាន់ សាទី**	សប្បុរសជននៅប្រទេសបារាំង ។	

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>**កន្លែងទទួល :**</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (<u>ដើម្បីជូនជ្រាប</u>)*
- *ដូចមាត្រា ១ និងមាត្រា ២ (<u>ដើម្បីអនុវត្ត</u>)*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៦៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ៈ ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **MITANI SHIRO** ដែលបានឧបត្ថម្ភថវិកាតាមរយៈអង្គការ **JHP** មានទឹកប្រាក់ចំនួន ៣៦.៨២៤.០០ ដុល្លារអាមេរិក ដើម្បីជួយសាងសង់អគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន០៣បន្ទប់ និងប្រព័ន្ធភ្លើងអគ្គិសនី ដើរដោយរស្មីព្រះអាទិត្យ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់ នៅសាលាបឋមសិក្សាតាសាស់ ក្នុងឃុំផ្ទះរុង ស្រុកភ្នំក្រវាញ ខេត្តពោធិសាត់ ។

មាត្រា២ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តពោធិសាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៥៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ៈ ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **WATANABE MIKI** អគ្គនាយក អង្គការ **School Aid Japan** ដែលបានឧបត្ថម្ភថវិកាជួយកសាងអគារសិក្សា ០១ខ្នង មាន០៣បន្ទប់ បំពាក់ដោយសង្ហារិមគ្រប់គ្រាន់ នៅសាលាបឋមសិក្សាត្រពាំងល្ពាក់ ក្នុងឃុំយុទ្ធសាមគ្គី ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ចំណាយអស់ទឹកប្រាក់ ចំនួន ១៩.៧១៨ ដុល្លារ ។

មាត្រា២ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៤៩៨...អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **WATANABE MIKI** អគ្គនាយកអង្គការ **School Aid Japan** ដែលបានឧបត្ថម្ភថវិកា ចំនួន ២៦.២៥០ ដុល្លារ សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៤បន្ទប់ នៅសាលាបឋមសិក្សាបត់ដៃ្វល ស្ថិតក្នុងភូមិបត់ដៃ្វល ឃុំផ្ទះរុង ស្រុកភ្នំក្រវាញ ខេត្តពោធិសាត់ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តពោធិសាត់ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។៚

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៧
នាយករដ្ឋមន្ត្រី
ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៩៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០៣គ្រឿង ផ្តល់ជូនសប្បុរសជន និងសមាគម ដែលបានឧបត្ថម្ភថវិកា ជួយសាងសង់អគារសិក្សា នៅខេត្តកំពង់ធំ ដូចមានខាងក្រោម :-

១-លោកស្រី **TOMIE KUWABARA** ប្រធានអង្គការ **Happy Apple** បានឧបត្ថម្ភថវិកា ចំនួន ២២.០០០ ដុល្លារ ជួយសាងសង់អគារសិក្សា ០១ខ្នង មាន ០៤បន្ទប់ ខ្លោងទ្វារ ០១ ដងទង់ជាតិ ០១ និងផ្លាកម្ចាស់អំណោយ នៅសាលាបឋមសិក្សា កំពង់ស្តេច ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

២-សមាគម **SANTIPHEAP MIYAGY VOLUNTEER ASSOCIATION** បានឧបត្ថម្ភថវិកា ចំនួន ១៧.២២៩ ដុល្លារ ជួយសាងសង់អគារសិក្សា ០១ខ្នង មាន ០៣បន្ទប់ បង្គន់អនាម័យ ០១ ខ្នង និងអណ្តូងទឹក ០១ នៅសាលាបឋមសិក្សាសង្វាត ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ។

៣-សមាគម **Association of Forest Rehabilitation the President Watanabekeiji** បានឧបត្ថម្ភថវិកា ចំនួន ១៧.៦៤០,៤២ ដុល្លារ ជួយសាងសង់អគារសិក្សា ០១ខ្នង មាន ០៣បន្ទប់ បង្គន់អនាម័យ ០១ខ្នង អណ្តូងទឹក ០១ ព្រមទាំងបំពាក់សម្ភារឹមសិក្សា នៅសាលាបឋមសិក្សា បុសធំ ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ X+

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦០០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន **AEON Fantasy Co.LTD** ដែលបានឧបត្ថម្ភថវិកា ចំនួន ២៧.៨៩០ ដុល្លារអាមេរិក ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៤បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់ នៅអនុវិទ្យាល័យទំពមានជ័យ ក្នុងឃុំស្តុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៣៤...សសរ

សេចក្តីសម្រេច

ស្តីពី

ការបង្កើតប្រតិភូចុះពិនិត្យជាក់ស្តែង លើសកម្មភាពចាក់ដីលុបអាងទឹកតាមោក និងសកម្មភាពអសកម្មនានា ដែលមាននៅក្នុងអាងទឹកតាមោក

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

ប្រការ ១ : ត្រូវបានបង្កើតប្រតិភូចុះពិនិត្យជាក់ស្តែង លើសកម្មភាពចាក់ដីលុបអាងទឹកតាមោក និងសកម្មភាពអសកម្មនានា ដែលមាននៅក្នុងអាងទឹកតាមោក រួមមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **លឹម គានហោ**	រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម	ប្រធាន
២- ឯកឧត្តម **នុត សាអាន**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក
៣- ឯកឧត្តម **ឆាន់ សាផាន់**	រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក

៤-	ឯកឧត្តម **តឹកអ៊ាវ សំអេច**	ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៥-	ឯកឧត្តម **សុខ ចិន្តា**	អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
៦-	ឯកឧត្តម **ពេជ អន្ទ**	សមាជិកបម្រុង នៃក្រុមប្រឹក្សាអ្នកច្បាប់	សមាជិក
៧-	ឯកឧត្តម **ឈុន ស៊ីរុន**	អភិបាលខេត្តកណ្តាល	សមាជិក។

ប្រការ ២ : ប្រតិភូចុះពិនិត្យជាក់ស្តែង លើសកម្មភាពចាក់ដីលុបអាងទឹកតាមោក និងសកម្មភាពអសកម្មនានា ដែលមាននៅក្នុងអាងទឹកតាមោក មានភារកិច្ចដូចតទៅ :

- ចុះពិនិត្យជាក់ស្តែង លើសកម្មភាពចាក់ដីលុបអាងទឹកតាមោក និងសកម្មភាពអសកម្មនានា ដែលមាននៅក្នុងអាងទឹកតាមោក
- ធ្វើការបូកសរុប វាយតម្លៃ ពីផលប៉ះពាល់ ដែលបណ្តាលមកពីសកម្មភាពអសកម្មទាំងនោះ
- លើកវិធានការជូនសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ពិនិត្យ និងសម្រេច ។

ប្រការ ៣ : ប្រតិភូចុះពិនិត្យជាក់ស្តែង លើសកម្មភាពចាក់ដីលុបអាងទឹកតាមោក និងសកម្មភាពអសកម្មនានា ដែលមាននៅក្នុងអាងទឹកតាមោក ត្រូវចូលរួមប្រជុំ និងចុះពិនិត្យការងារជាក់ស្តែង តាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៩ សសរ

សេចក្តីសម្រេច

ស្តីពី

ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីទ្រទ្រង់ដល់ការរៀបចំព្រឹត្តិការណ៍ "ការប្រកួតកីឡាវាយកូនគោលអាស៊ី លក្ខណៈអន្តរជាតិ Johnnie Walker Cambodia Open 2007 " នៅខេត្តសៀមរាប ពីថ្ងៃទី២៩ ខែវិច្ឆិកា ដល់ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- យោងលិខិតជូនដំណឹងលេខ៨៦៥ សជណ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- តាមការងារចាំបាច់

ស ម្រេ ច

ប្រការ១: ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីទ្រទ្រង់ដល់ការរៀបចំព្រឹត្តិការណ៍"ការប្រកួតកីឡាវាយកូនគោលអាស៊ី លក្ខណៈអន្តរជាតិ Johnnie Walker Cambodia Open 2007" ពីថ្ងៃទី២៩ ខែវិច្ឆិកា ដល់ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៧ នៅខេត្តសៀមរាបរួមមានសមាសភាពដូចតទៅ :

១-ឯកឧត្តម	ថោង ខុន	រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិអូឡាំពិក កម្ពុជា	ប្រធាន
២-ឯកឧត្តម	ទ្រាំ អ៊ីវតឹក	រដ្ឋលេខាធិការក្រសួងសាធារណៈការ និងដឹកជញ្ជូន	អនុប្រធាន
៣-ឯកឧត្តម	អ៊ុក ប្រាថ្នា	រដ្ឋលេខាធិការក្រសួងព័ត៌មាន	អនុប្រធាន
៤-ឯកឧត្តម	ស៊ូ ភីរិន្ទ	អភិបាលខេត្តសៀមរាប	អនុប្រធាន
៥-ឯកឧត្តម	សូ ម៉ារ៉ា	អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ -	អនុប្រធានអចិន្ត្រៃយ៍

៦-ឯកឧត្តម	មាស សារិន	អគ្គលេខាធិការនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា	អនុប្រធាន
៧-ឧត្តមសេនីយ៍ ថុន	សារ៉ាត់	អគ្គលេខាធិការសហព័ន្ធកីឡាវាយកូនគោលកម្ពុជា	សមាជិក
៨-ឯកឧត្តម	ភឹម គុណចឡូន៍	អគ្គនាយក នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា	សមាជិក
៩-លោក	ហោ សារុន	អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ និងជាប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅនៃក្រសួងទេសចរណ៍	សមាជិក
១០-លោកស្រី	ចៅស៊ុន ភិរិយា	ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍នៃអាជ្ញាធរអប្សរា	សមាជិក
១១-ឧត្តមសេនីយ៍ ថោង	លឹម	ប្រធាននាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ	សមាជិក
១២-ឧត្តមសេនីយ៍ ញាណ	ចិមុល	ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍នៃក្រសួងមហាផ្ទៃ	សមាជិក
១៣-លោក	ឡាយ ឫទ្ធី	នាយករងទីចាត់គយ និងរដ្ឋាករ	សមាជិក
១៤-លោក	ភុយ សុខ	ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប	សមាជិក

ប្រការ២: ក្រុមការងារទទួលខុសត្រូវដល់ការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាវាយកូនគោលអាស៊ី លក្ខណៈអន្តរជាតិ Johnnie Walker Cambodia Open 2007 មានមុខងារ និងភារកិច្ចដូចតទៅ :

- រៀបចំបដិសណ្ឋារកិច្ចស្វាគមន៍ដល់គណៈប្រតិភូ និងក្រុមកីឡាករអន្តរជាតិវាយកូនគោល នៅច្រកទ្វារព្រលានយន្តហោះអន្តរជាតិភ្នំពេញ ព្រលានយន្តហោះអន្តរជាតិខេត្តសៀមរាប និងច្រកទ្វារអន្តរជាតិផ្សេងៗទៀតទាំងពេលមកដល់ និងពេលនិវត្តន៍វិញ។
- ជួយសម្រួលបែបបទនៃការធ្វើដំណើរ និងបែបបទគយនៅតាមច្រកទ្វារអន្តរជាតិជូនគណៈប្រតិភូ និងក្រុមកីឡាករ។
- ជំរុញការស្ថាបនាផ្លូវជាតិលេខ ៦ សៀមរាប-ប៉ោយប៉ែត (កំណាត់ផ្លូវពីក្រុងសៀមរាបទៅកន្លែងវាយកូនគោល Phokeethra Country Club) ឱ្យបានទាន់ពេលវេលា។
- ការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈឱ្យបានល្អនៅក្នុងពេលប្រកួតកីឡាវាយកូនគោលអាស៊ីលក្ខណៈអន្តរជាតិនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសនៅលើទឹកដីខេត្តសៀមរាប។
- ធ្វើការផ្សព្វផ្សាយតាមបណ្តាញព័ត៌មានក្នុងប្រទេស និងក្រៅប្រទេស ជាពិសេសតាមវិទ្យុ ទូរទស្សន៍ដើម្បីឱ្យទេសចរអន្តរជាតិ និងសាធារណជនបានយល់ជ្រួតជ្រាប និងចូលរួមក្នុងព្រឹត្តិការណ៍ប្រកួតកីឡាវាយកូនគោលនេះ។
- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងផ្នែកឯកជន ព្រមទាំងមានសិទ្ធិស្វែងរក និងទទួលជំនួយ និងការឧបត្ថម្ភនានាដល់កិច្ចដំណើរការសកម្មភាពនេះ។
- ជ្រើសរើសអ្នកជំនាញវាយកូនគោល (Professional Golfer) កម្ពុជាដើម្បីចូលរួម។
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការរៀបចំ និងកិច្ចដំណើរការនៃពិធីនេះជូនប្រមុខរាជរដ្ឋាភិបាល។

ប្រការ៣: ក្រុមការងារនេះត្រូវសហការយ៉ាងជិតស្និទ្ធជាមួយអ្នករៀបចំកម្មវិធី (Organiser) និងផ្នែកឯកជនពាក់ព័ន្ធដើម្បីរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាវាយកូនគោលអាស៊ី លក្ខណៈអន្តរជាតិ Johnnie Walker Cambodia Open 2007 ឱ្យទទួលបានជោគជ័យ។

ប្រការ៤: ក្រុមការងារនេះមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីតាំងនៅទីស្តីការក្រសួងទេសចរណ៍ មានសមាសភាពដូចខាងក្រោម :

១-លោក	ហោ សារុន	អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ និងជាប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅនៃក្រសួងទេសចរណ៍	ប្រធាន

២-លោក ពេញ ពន្លក ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុនៃក្រសួងទេសចរណ៍ អនុប្រធាន

៣-លោក ឡាយ ឬទ្ធី នាយករងទីចាត់ការគយ និងរដ្ឋាករ សមាជិកអចិន្ត្រៃយ៍

៤-លោក សំ ឌុន្ថា អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅក្រសួងទេសចរណ៍ លេខាធិការ

៥-លោក ពិន ពិសិដ្ឋ អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ សមាជិក

៦-លោក ជាម សារ៉ាយ អនុប្រធាននាយកដ្ឋាននគរបាលទេសចរណ៍នៃក្រសួងមហាផ្ទៃ សមាជិក

៧-លោក គង់ សុឃីជា នាយកខុទ្ទកាល័យរដ្ឋមន្ត្រី សមាជិក

៨-លោក សំ ស៊ុយហ៊ីន ប្រធានអង្គភាពនគរបាលទេសចរណ៍ខេត្តសៀមរាប សមាជិក

៩-លោក ឡុំង សេខភាគ អនុប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប សមាជិក

១០-លោក ធីង មុន្នី នាយកការិយាល័យនៃក្រសួងទេសចរណ៍ លេខាកត់ត្រា

១១-លោក ស៊ុយ សុផា នាយរងការិយាល័យនៃក្រសួងព័ត៌មាន សមាជិក

១២-លោក នួច ម៉ានី នាយរងការិយាល័យនៃក្រសួងទេសចរណ៍ សមាជិក

១៣-លោក ឆន់ ចាន់នី អនុប្រធានការិយាល័យនៃមន្ទីរទេសចរណ៍ខេត្តសៀមរាប សមាជិក

១៤-លោក សម ចន្ទីធីរៈ មន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍នៃអាជ្ញាធរអប្សរា សមាជិក

១៥-លោក ស៊ីុខ សុណរាត មន្ត្រីនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅនៃក្រសួងទេសចរណ៍ សមាជិក

១៦-លោក អ៊ុច ចំនួនឡុងៈ មន្ត្រីនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅនៃក្រសួងទេសចរណ៍ សមាជិក

ប្រការ៥: -ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងទេសចរណ៍ក្នុងការបំពេញការងារ ។

-សមាជិកនៃក្រុមការងារនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ៦: ក្រុមការងារនេះនឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច ។

ប្រការ៧: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៨: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តសៀមរាប ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ៤ខាងលើ ត្រូវទទួលអនុវត្តតាមសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៧

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៧
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...០២ស.រ

សារាចរ

ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់

កន្លងមក ដីរដ្ឋ ទាំងដីសាធារណៈរបស់រដ្ឋ ទាំងដីឯកជនរបស់រដ្ឋ ភាគច្រើនមិនទាន់បានធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទីកំណត់ទីតាំង និងព្រំប្រទល់ច្បាស់លាស់ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីនៅឡើយ ដែលធ្វើឱ្យអាជ្ញាធរគ្រប់ជាន់ថ្នាក់ប្រឈមនឹងការលំបាកក្នុងការគ្រប់គ្រង ដូចជាការទប់ស្កាត់ ការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ជាដើម ។

ការចូលកាន់កាប់ដីតាមរូបភាពភោគៈ ត្រូវបានបញ្ចប់បន្ទាប់ពីច្បាប់ភូមិបាលឆ្នាំ ២០០១ ចូលជាធរមាន ក្នុងពេលដែលរដ្ឋមិនទាន់បានអនុវត្តទូលំទូលាយនៅឡើយនូវកម្មវិធីសម្បទានដីសង្គមកិច្ច សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ដើម្បីដោះស្រាយសេចក្តីត្រូវការដីរបស់ប្រជាពលរដ្ឋ ដែលចេះតែកើនឡើងជារៀងរាល់ថ្ងៃ ដោយសារកំណើនប្រជាជន ការរំសាយកងទ័ព ការបាត់បង់ដីដោយសារគ្រោះធម្មជាតិជាដើម ដែលជាហេតុនាំឱ្យមានការចូលកាន់កាប់ដីរដ្ឋ ដោយអនាធិបតេយ្យ ។ ទន្ទឹមនេះ ក៏មានជនឆ្លៀតឱកាស ពួកឈ្មួញដី និងអ្នកមានអំណាចមួយចំនួន បានចូលកាន់កាប់ដីរដ្ឋដោយខុសច្បាប់តាមរូបភាពផ្សេងៗ ។

ចំពោះមុខស្ថានការណ៍នេះ និងអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមានដែលទាក់ទងនឹងដីធ្លី ដូចជាច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ ច្បាប់ជលផល ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ និងព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការបង្កើត និងការគ្រប់គ្រងវបរិយជីវមណ្ឌលបឹងទន្លេសាប ជាដើម រាជរដ្ឋាភិបាលយល់ថា ដើម្បីដោះស្រាយបញ្ហាទន្ទ្រានកាន់កាប់ដីរបស់រដ្ឋដោយខុសច្បាប់កន្លងមក ពីសំណាក់បុគ្គលឯកជន ទន្ទឹមនឹងការអនុវត្តច្បាប់ ក៏ទាមទារនូវការពិនិត្យករណីរំលោភជាក់ស្តែងនីមួយៗ និងដោះស្រាយដោយមានការអនុគ្រោះមួយចំនួន ពិសេសចំពោះគ្រួសារជនក្រីក្រ និងចំពោះដីធ្លីដែលបានធ្វើអាជីវកម្មពិតប្រាកដ ស្របតាមគោលនយោបាយដែលមានចែងក្នុងសារាចរនេះ ។ ដោយឡែក ចំពោះសម្បទានដីសេដ្ឋកិច្ច ករណីដែលសម្បទានិកមិនបានធ្វើការអភិវឌ្ឍតាមកិច្ចសន្យា ឬកាន់កាប់ដីសរុបលើសពីទំហំកំណត់នៃច្បាប់ភូមិបាល ការដកហូត ឬការកាត់បន្ថយ ត្រូវអនុវត្តតាមនីតិវិធី ដែលមានចែងក្នុងអនុក្រឹត្យ ស្តីពីសម្បទានដីសេដ្ឋកិច្ច ។

ដើម្បីរួមចំណែកដល់គោលនយោបាយកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមរបស់រាជរដ្ឋាភិបាល តាមរយៈការផ្តល់សុវត្ថិភាពនៃការកាន់កាប់ដីធ្លី ការផ្តល់សម្បទានដីសង្គមកិច្ច ការបង្កើនចំណូលពីការប្រើប្រាស់ដីរដ្ឋ ការទប់ស្កាត់ និងកាត់បន្ថយចលនាទន្ទ្រានកាន់កាប់ដីរដ្ឋ ពិសេសដីព្រៃ និងដើម្បីធានាការពារធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព រាជរដ្ឋាភិបាលធ្វើការណែនាំនូវវិធានការ និងនីតិវិធីក្នុងការទាមទារ ដកយកដីរដ្ឋ ដែលកាន់កាប់ដោយខុសច្បាប់មកវិញ ដូចតទៅ :

១- ត្រូវចាត់ទុកជាការកាន់កាប់ដីរដ្ឋដោយខុសច្បាប់នូវ :

- រាល់ការចូលកាន់កាប់ដីរដ្ឋ (ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ) ជាភោគៈក្រោយច្បាប់ភូមិបាល ឆ្នាំ ២០០១ ចូលជាធរមាន
- រាល់ការកាន់កាប់ដីរដ្ឋជាភោគៈនៅលើដី ដែលត្រូវបានកំណត់រួចហើយ ជាដីសាធារណៈរបស់រដ្ឋ ទោះជាមុន ឬក្រោយច្បាប់ភូមិបាលចូលជាធរមានក៏ដោយ
- រាល់ការបន្តកាន់កាប់ដីរដ្ឋក្រោយពេលលិខិតអនុញ្ញាត ឬកិច្ចសន្យាឱ្យប្រើប្រាស់ដីរដ្ឋអស់សុពលភាព ហើយអ្នកកាន់កាប់មិនបានសុំបន្តសុពលភាពត្រឹមត្រូវតាមនីតិវិធីជាធរមាន
- រាល់ការកាន់កាប់ដីរដ្ឋលើសពីទំហំ ឬខុសទីតាំង ដែលកំណត់ក្នុងលិខិតអនុញ្ញាត ឬកិច្ចសន្យាឱ្យប្រើប្រាស់
- រាល់ការផ្ទេរសិទ្ធិប្រើប្រាស់ដីរដ្ឋដោយបំពានលក្ខខណ្ឌ ក្នុងលិខិតអនុញ្ញាត ឬកិច្ចសន្យា
- រាល់ការបំប្លែងការកាន់កាប់ដីរដ្ឋទៅជាកម្មសិទ្ធិឯកជនដោយខុសច្បាប់ មានជាអាទិ៍ ការបន្លំធ្វើប័ណ្ណកម្មសិទ្ធិលើដីសម្បទានសេដ្ឋកិច្ច ឬលើដី ដែលទទួលបានត្រឹមតែការអនុញ្ញាតឱ្យប្រើប្រាស់ ឬធ្វើអាជីវកម្ម ឬការបំប្លែងដី ដែលត្រូវបានកំណត់ជាដីសាធារណៈរបស់រដ្ឋ ។

២- នីតិវិធីអនុវត្តចំពោះដី ដែលបានចុះបញ្ជី ក្នុងសៀវភៅគោលបញ្ជីដីធ្លីជាដីរដ្ឋរួចហើយ :

២.១-អាជ្ញាធរកាន់កាប់ដីរដ្ឋ ត្រូវចេញលិខិតទាមទារយកដីរដ្ឋមកវិញ ដោយបញ្ជាក់ពីលេខក្បាលដី ទីតាំងក្បាលដី និងប្លង់បង្ហាញទីតាំងក្បាលដី ឈ្មោះអ្នកកាន់កាប់ដីបច្ចុប្បន្ន រយៈពេលឆ្លើយតប ឬប្តឹងតវ៉ារបស់អ្នកមានផលប្រយោជន៍ផ្សេងៗលើក្បាលដីនោះ (ប្រើទម្រង់លេខ ១) ។

២.២-លិខិតទាមទារយកដីរដ្ឋមកវិញ ត្រូវបិទប្រកាសជាសាធារណៈនៅសាលាឃុំ សង្កាត់ និងនៅលើដី ដែលជាកម្មវត្ថុនៃការទាមទារយកមកវិញ និងបញ្ជូនមួយច្បាប់ទៅឱ្យអ្នកកាន់កាប់ដី ប្រសិនបើគេរស់នៅក្នុងឃុំ សង្កាត់នៃទីតាំងដីនោះ ។ អាជ្ញាធរកាន់កាប់ដីរដ្ឋ ត្រូវប្រើប្រាស់គ្រប់មធ្យោបាយដើម្បីផ្តល់ដំណឹងដល់អ្នកកាន់កាប់ដីរដ្ឋ ប្រសិនបើគេរស់នៅក្រៅឃុំ សង្កាត់នៃទីតាំងដីនោះ ។

២.៣-ក្នុងករណីដែលអាជ្ញាធរកាន់កាប់ដីរដ្ឋ មិនអាចរកឃើញថា បុគ្គលណាមួយជាក់លាក់ជាអ្នកកាន់កាប់ដីនោះទេ អាជ្ញាធរកាន់កាប់ដីរដ្ឋអាចចេញលិខិតទាមទារយកដីរដ្ឋមកវិញ ដោយគ្មានបញ្ជាក់ឈ្មោះអ្នកកាន់កាប់ដី ហើយបិទប្រកាសជាសាធារណៈនៅសាលាឃុំ សង្កាត់នៃទីតាំងដី នៅលើដីដែលជាកម្មវត្ថុនៃការទាមទារយកមកវិញ និងផ្សព្វផ្សាយតាមសារព័ត៌មានថែមទៀត ។

២.៤-អាជ្ញាធរកាន់កាប់ដីរដ្ឋ ត្រូវទុករយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃបិទប្រកាស ឬអ្នកកាន់កាប់ដីរដ្ឋបានទទួលលិខិតទាមទារយកដីរដ្ឋមកវិញ ដើម្បីឱ្យអ្នកកាន់កាប់ដីធ្វើការឆ្លើយតប ឬអ្នកមានផលប្រយោជន៍លើក្បាលដីនោះ ប្តឹងតវ៉ាមកអាជ្ញាធរដែលចេញលិខិត ។ ចំពោះករណី ដែលអាជ្ញាធរកាន់កាប់ដីរដ្ឋមិនអាចរកឃើញបុគ្គលណាមួយជាក់លាក់ជាអ្នកកាន់កាប់ដីរដ្ឋនោះទេ រយៈពេល ៣០ ថ្ងៃ ត្រូវគិតចាប់ពីថ្ងៃដែលបានបិទប្រកាសជាសាធារណៈ និងដែលបានផ្សព្វផ្សាយតាមសារព័ត៌មាន ។

២.៥-ក្នុងរយៈពេលនោះ អ្នកកាន់កាប់ដីរដ្ឋត្រូវឆ្លើយតបដោយបង្ហាញពីការយល់ព្រមប្រគល់ដីនោះមកឱ្យរដ្ឋវិញដោយគ្មានលក្ខខណ្ឌ ឬការយល់ព្រមប្រគល់ដោយមានសំណើ លក្ខខណ្ឌច្បាស់លាស់ ឬការមិនយល់ព្រមប្រគល់ហើយទាមទារសិទ្ធិលើដីនោះ (ប្រើទម្រង់លេខ ២) និងភ្ជាប់នូវរាល់ឯកសារភស្តុតាងពាក់ព័ន្ធដែលខ្លួនមានមកជាមួយ ។

២.៦-ក្រោយរយៈពេលកំណត់ ៣០ ថ្ងៃខាងលើ ប្រសិនបើមានការឆ្លើយតបមិនយល់ព្រមប្រគល់ដីឱ្យរដ្ឋវិញដោយគ្មានលក្ខខណ្ឌ ឬមានការប្តឹងតវ៉ាណាមួយ អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវធ្វើលិខិតជូនទៅមេឃុំ ចៅសង្កាត់ និងអភិបាលស្រុក ខណ្ឌ ដើម្បីស្នើសុំកិច្ចសហការចូលរួមរបស់អាជ្ញាធរដែនដី ក្នុងការពិភាក្សាសម្របសម្រួល ដោយផ្អែកលើគោលនយោបាយ ដែលបានកំណត់ក្នុងចំណុច ៦ និង ៧ នៃសារាចរនេះ ជាមួយអ្នកកាន់កាប់ដីរដ្ឋ ឬអ្នកប្តឹងតវ៉ា ហើយក្នុងលិខិតនោះត្រូវមានកំណត់កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃការជួបពិភាក្សាសម្របសម្រួល ព្រមទាំងភ្ជាប់នូវច្បាប់ចម្លងនៃលិខិតឆ្លើយតប ឬពាក្យប្តឹងតវ៉ានោះ ។

២.៧-បើការពិភាក្សាសម្របសម្រួលជាមួយអ្នកកាន់កាប់ដីរដ្ឋខុសច្បាប់ ឬអ្នកប្តឹងតវ៉ាមិនអាចសម្រេចបាននូវដំណោះស្រាយ ដែលអាចទទួលយកបានទាំងសងខាងទេ អាជ្ញាធរកាន់កាប់ដីរដ្ឋ ដែលជាអាជ្ញាធរមានសមត្ថកិច្ច ត្រូវចេញលិខិតបញ្ជាឱ្យអ្នកកាន់កាប់ដីរដ្ឋខុសច្បាប់នោះរុះរើ ជួសជុលការខូចខាត និងចាកចេញពីដីរដ្ឋ ក្នុងរយៈពេល ៤៥ ថ្ងៃ (ប្រើទម្រង់លេខ ៣) ។

២.៨-បើអ្នកកាន់កាប់ដីរដ្ឋខុសច្បាប់នោះ មិនយល់ព្រមចាកចេញតាមកាលកំណត់ អាជ្ញាធរកាន់កាប់ដីរដ្ឋ ត្រូវរៀបចំពាក្យប្តឹងទៅតុលាការ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់ជាធរមាន ។

២.៩-បើអ្នកកាន់កាប់ដីរដ្ឋខុសច្បាប់បានចាកចេញ ប៉ុន្តែខកខានមិនបានជួសជុលការខូចខាត ចំពោះដីនោះ អាជ្ញាធរកាន់កាប់ដីរដ្ឋ អាចរៀបចំសំណុំរឿងប្តឹងទៅតុលាការ ដើម្បីស្នើសុំការជួសជុល ឬសំណងការខូចខាតដីរដ្ឋនោះ ។

២.១០-នៅពេលដែលអ្នកកាន់កាប់ដីបានចាកចេញដោយស្ម័គ្រចិត្ត ឬក្រោយការអនុវត្តវិធានការបណ្តេញចេញបានសម្រេច អាជ្ញាធរកាន់កាប់ដីរដ្ឋ ត្រូវអនុវត្តផែនការប្រើប្រាស់ដី ឬរៀបចំដំណើរការធ្វើចំណាត់ថ្នាក់ដី និង/ឬធ្វើផែនការប្រើប្រាស់ដីនោះ ប្រសិនបើមិនទាន់បានធ្វើ ។

២.១១-ចំពោះក្បាលដីរដ្ឋណា ដែលរកអ្នកកាន់កាប់មិនឃើញ ផុតរយៈពេលកំណត់ ៣០ ថ្ងៃ គិតចាប់ពីថ្ងៃបិទប្រកាសជាសាធារណៈ អាជ្ញាធរកាន់កាប់ដីរដ្ឋមានសិទ្ធិរឹបអូសយកក្បាលដី នៃដីរដ្ឋនោះមកវិញដោយស្វ័យប្រវត្ត។

ចំពោះករណីដែលអ្នកកាន់កាប់ក្បាលដីរដ្ឋណា បានទទួលលិខិតទាមទារយកដីរដ្ឋមកវិញហើយ តែមិនបានឆ្លើយតប ឬមិនបានតវ៉ា ផុតរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតទាមទារនេះ អាជ្ញាធរកាន់កាប់ដីរដ្ឋ មានសិទ្ធិរឹបអូសយកក្បាលដី នៃដីរដ្ឋនោះមកវិញដោយស្វ័យប្រវត្ត។

៣ - នីតិវិធីអនុវត្តចំពោះដី ដែលមានក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋ ឬដីដែលបានធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ ហើយមានការឯកភាពគ្នាលើអាណត្តិកាន់កាប់ដី :

៣.១-អាជ្ញាធរកាន់កាប់ដីរដ្ឋ ត្រូវចេញលិខិតទាមទារយកដីរដ្ឋមកវិញ ដោយបញ្ជាក់ទីតាំងក្បាលដី ឬប្លង់បង្ហាញទីតាំងក្បាលដី ទំហំប្រហាក់ប្រហែលនៃក្បាលដី ព័ត៌មានអំពីព្រំប្រទល់ប្រហាក់ប្រហែលនៃក្បាលដី ឈ្មោះអ្នកកាន់កាប់ដីបច្ចុប្បន្ន រយៈពេលឆ្លើយតប ឬប្តឹងតវ៉ាដោយអ្នកមានផលប្រយោជន៍ផ្សេងៗ លើក្បាលដីនោះ (ប្រើទម្រង់លេខ ១) ។ អាជ្ញាធរកាន់កាប់ដីរដ្ឋ ត្រូវអនុវត្តដូចមានចែងក្នុងចំណុច ២.២. ២.៣. ២.៤. ២.៥. ២.៦ និងចំណុច ២.១១ នៃសារាចរនេះ ។

៣.២-ក្រោយពីបានធ្វើការពិភាក្សាសម្របសម្រួលជាមួយអ្នកកាន់កាប់ដី ឬអ្នកប្តឹងតវ៉ាដើម្បីរកដំណោះស្រាយ (ដោយធ្វើកំណត់ហេតុអំពីការពិភាក្សាសម្របសម្រួលនោះផង) អាជ្ញាធរកាន់កាប់ដីរដ្ឋ ត្រូវធ្វើរបាយការណ៍ និងលើកយោបល់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុងដោយចម្លងជូនក្រុមប្រឹក្សាឃុំ សង្កាត់ និងអភិបាលស្រុក ខណ្ឌ ដែលជាប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ។

៣.៣-ក្នុងករណីមិនឯកភាពលើខ្លឹមសាររបាយការណ៍របស់អាជ្ញាធរកាន់កាប់ដីរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ឬអភិបាលស្រុក ខណ្ឌ មានសិទ្ធិសរសេរលិខិតបង្ហាញហេតុផល អំពីការមិនឯកភាពរបស់ខ្លួន ភ្ជាប់នឹងរបាយការណ៍របស់អាជ្ញាធរកាន់កាប់ដីរដ្ឋ ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ។

៣.៤-ក្រោយពីទទួលបានរបាយការណ៍ ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង អាចចាត់តាំងមន្ត្រីចុះទៅពិនិត្យ ឬពិភាក្សាបន្ថែមទៀតជាមួយអ្នកកាន់កាប់ដី ឬអ្នកប្តឹងតវ៉ាដល់ទីកន្លែង តាមការចាំបាច់ និងត្រូវកោះប្រជុំគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ដើម្បីពិនិត្យពិចារណាលើរបាយការណ៍ និងមតិយោបល់នានា ដែលទទួលបាន ដើម្បីស្វែងរកការឯកភាពគ្នា ផ្អែកលើគោលនយោបាយ ដែលបានកំណត់ក្នុងចំណុច ៦ និង ៧ នៃសារាចរនេះ និងរកដំណោះស្រាយសម្រាប់ករណីអ្នកកាន់កាប់ដី ឬអ្នកប្តឹងតវ៉ានីមួយៗ ។

៣.៥-ក្រោយពីបញ្ចប់ការប្រជុំពិនិត្យពិចារណាលើករណីនោះ (ដោយធ្វើកំណត់ហេតុប្រជុំផង) ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវធ្វើរបាយការណ៍អំពីករណីអ្នកកាន់កាប់ និងអ្នកប្តឹងតវ៉ានីមួយៗ ដោយមានភ្ជាប់នូវបញ្ជីឈ្មោះរបស់ពួកគេ គំនូសប្លង់បង្ហាញទីតាំង និងទំហំដីប្រហាក់ប្រហែល

ដែលពួកគេកាន់កាប់ឬតវ៉ា ព្រមទាំងយោបល់របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ចំពោះករណីអ្នកកាន់កាប់ដីរដ្ឋ ឬអ្នកប្តឹងតវ៉ានីមួយៗ ដើម្បីសុំយោបល់សម្រេចពីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

៣.៦-ក្រោយពីបានទទួលសេចក្តីសម្រេចពីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អភិបាលខេត្ត ក្រុង ត្រូវចេញដីកាសម្រេច ដោយមានបញ្ជាក់ឈ្មោះអ្នកកាន់កាប់ដី ឬអ្នកប្តឹងតវ៉ា ទីតាំង និងទំហំដីពាក់ព័ន្ធនីមួយៗ និងទុករយៈពេល ៦០ ថ្ងៃ គិតចាប់ពីថ្ងៃចេញដីកា សម្រាប់ការប្តឹងតវ៉ា ។

៣.៧-ក្នុងករណីអ្នកកាន់កាប់ដីរដ្ឋយល់ព្រមតាមដីការបស់អភិបាលខេត្ត ក្រុងដោយពុំមានការតវ៉ា អាជ្ញាធរកាន់កាប់ដីរដ្ឋ ត្រូវដាក់ពាក្យស្នើសុំទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ដើម្បី ចុះបញ្ជីដីនោះក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

៣.៨-ក្នុងដំណើរការចុះបញ្ជី ប្រសិនបើមានវិវាទ អំពីសិទ្ធិលើដីនោះជាមួយបុគ្គលឯកជន ឬសមូហភាពណាមួយ ក្រៅពីអ្នកមានឈ្មោះក្នុងបញ្ជី ដែលកំណត់នៅចំនុច ៣.៥ វិវាទនោះត្រូវដាក់ជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីសម្រេច ។

៣.៩-ក្រោយពីបានចុះបញ្ជីជាដីរដ្ឋរួចហើយ ប្រសិនបើនៅមានអ្នកបន្តកាន់កាប់ដីនោះដោយខុសច្បាប់ អាជ្ញាធរកាន់កាប់ដីរដ្ឋ ដែលជាអាជ្ញាធរមានសមត្ថកិច្ច ត្រូវចេញលិខិតបញ្ជាឱ្យអ្នកកាន់កាប់ដីរដ្ឋខុសច្បាប់នោះ រុះរើ ជួសជុលការខូចខាត និងចាកចេញពីដីនោះ ក្នុងរយៈពេល ៤៥ ថ្ងៃ (ប្រើទម្រង់លេខ ៣) ។

៣.១០-ប្រសិនបើអ្នកកាន់កាប់ដីរដ្ឋខុសច្បាប់នោះមិនយល់ព្រមចាកចេញតាមកាលកំណត់ អាជ្ញាធរកាន់កាប់ដីរដ្ឋ ត្រូវរៀបចំពាក្យប្តឹងទៅតុលាការ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់ជាធរមាន ។

៣.១១-ប្រសិនបើអ្នកកាន់កាប់ដីរដ្ឋខុសច្បាប់បានចាកចេញតាមកាលកំណត់ ប៉ុន្តែខកខានមិនបានជួសជុលការខូចខាតចំពោះដីនោះ ត្រូវអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច ២.៩ ។ នៅពេលដែលអ្នកកាន់កាប់ដីបានចាកចេញដោយស្ម័គ្រចិត្ត ឬក្រោយការអនុវត្តវិធានការបណ្តេញចេញបានសម្រេច អាជ្ញាធរកាន់កាប់ដីរដ្ឋ ត្រូវអនុវត្តតាមខ្លឹមសារដូចមានចែងក្នុងចំណុច ២.១០ ។

៤- នីតិវិធីអនុវត្តចំពោះដីរដ្ឋ ដែលមិនទាន់បញ្ចូលក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋ និងមិនទាន់បានធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ ឬបានធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋចប់ហើយ ប៉ុន្តែមិនទាន់មានការឯកភាព ឬមិនទាន់ដឹងអំពីអាណត្តិកាន់កាប់ដីរដ្ឋ :

៤.១-ចំពោះក្បាលដីរដ្ឋណា ដែលមិនទាន់បានធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទី និងមិនទាន់បានបញ្ចូលក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវប្រមូលព័ត៌មានអំពីទីតាំង និងអ្នកកាន់កាប់ក្បាលដីរដ្ឋ ទំហំ និងព្រំប្រទល់ប្រហាក់ប្រហែលនៃក្បាលដី ។ បន្ទាប់មក អភិបាលខេត្ត ក្រុង ត្រូវទទួលភារៈជាអាជ្ញាធរមានសមត្ថកិច្ចចេញលិខិតទាមទារដីរដ្ឋមកវិញ ។ នីតិវិធីនៃការទាមទារដីរដ្ឋមកវិញ ត្រូវអនុវត្តតាមខ្លឹមសារដូចមានចែងក្នុងចំណុច ៣.១ ដល់ ៣.៧ នៃសារាចរនេះ ទើបអាជ្ញាធរដែល

មានអាណត្តិកាន់កាប់ដីរដ្ឋនោះ ក្លាយជាអាជ្ញាធរមានសមត្ថកិច្ច ទទួលអនុវត្តជំហាន និងនីតិវិធីបន្តបន្ទាប់ទៀត នៃចំណុច ៣ ។

៤.២-ចំពោះក្បាលដីរដ្ឋណា ដែលបានធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋរួចហើយ ប៉ុន្តែមិនមាន ការឯកភាពគ្នា អំពីអាណត្តិកាន់កាប់ ឬមិនទាន់ដឹងអំពីអាណត្តិកាន់កាប់ដីរដ្ឋ និងមិនទាន់បានបញ្ចូលក្នុងបញ្ជី សារពើភ័ណ្ឌទ្រព្យរដ្ឋ អភិបាលខេត្ត ក្រុង ត្រូវទទួលភារៈជាអាជ្ញាធរមានសមត្ថកិច្ច ចេញលិខិតទាមទារដីរដ្ឋ មកវិញ ។ នីតិវិធីនៃការទាមទារដីរដ្ឋមកវិញ ត្រូវអនុវត្តតាមខ្លឹមសារដូចមានចែងក្នុងចំណុច ៣.១ ដល់ ៣.៧ នៃសារាចរនេះ ទើបអាជ្ញាធរដែលមានអាណត្តិកាន់កាប់ដីរដ្ឋនោះ ក្លាយជាអាជ្ញាធរមានសមត្ថកិច្ច ដែលមាន ភារកិច្ចទទួលអនុវត្តជំហាន និងនីតិវិធីបន្តបន្ទាប់ទៀតនៃចំណុច ៣ នៃសារាចរនេះ ។

៥ - នីតិវិធីអនុវត្ត ចំពោះដីព្រៃឈើគ្រប់ប្រភេទ ដែលបានចេញដីកាប្រកាសបដិសេធ និងដកហូតតាម បទបញ្ជាលេខ ០១ ប.ប របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការទប់ស្កាត់ ការកាប់រានដី ព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋ យកធ្វើជាកម្មសិទ្ធិ :

៥.១-បន្ទាប់ពីបានទទួលពាក្យប្តឹងតវ៉ា ចំពោះដីកាប្រកាសបដិសេធ និងដកហូតតាមបទបញ្ជាលេខ ០១ ប.ប របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការទប់ស្កាត់ការកាប់រានដីព្រៃឈើ គ្រប់ប្រភេទរបស់រដ្ឋ យកធ្វើជាកម្មសិទ្ធិ អាជ្ញាធរខេត្ត ក្រុង ត្រូវធ្វើការសម្របសម្រួលដោយត្រូវធ្វើកំណត់ហេតុ ជាមួយអ្នកប្តឹងតវ៉ា ដើម្បីរកដំណោះស្រាយជាបឋម ។ ការសម្របសម្រួលត្រូវយកផែនទីតម្របព្រៃឆ្នាំ ២០០២ ជាគោល និងផ្អែកលើគោលនយោបាយ ដែលបានកំណត់ក្នុងចំណុច ៦ និង ៧ នៃសារាចរនេះ ជា ពិសេសតាមស្ថានភាពជាក់ស្តែងនៅលើដី ។

៥.២-ករណីអ្នកប្តឹងតវ៉ាមិនយល់ព្រមតាមការសម្របសម្រួលនោះទេ អភិបាលខេត្ត ក្រុង ត្រូវចេញ សេចក្តីសម្រេចបដិសេធពាក្យប្តឹងតវ៉ា បន្ទាប់ពីថ្ងៃសម្របសម្រួល ។

៥.៣-ករណីអ្នកប្តឹងតវ៉ាមិនឯកភាពតាមសេចក្តីសម្រេចបដិសេធរបស់អភិបាលខេត្ត ក្រុង លើពាក្យ ប្តឹងតវ៉ា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង/ឬក្រសួងបរិស្ថាន ត្រូវសហការជាមួយមេធាវីរាជ រដ្ឋាភិបាល ប្តឹងអ្នកប្តឹងតវ៉ានោះ ទៅតុលាការ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់ជាធរមាន ។

៥.៤-ចំពោះដីព្រៃឈើគ្រប់ប្រភេទ ដែលអ្នកប្តឹងតវ៉ាឯកភាពតាមសេចក្តីសម្រេចបដិសេធរបស់ អភិបាលខេត្ត ក្រុង លើពាក្យប្តឹងតវ៉ានោះ ឬដែលពុំមានអ្នកប្តឹងតវ៉ា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង/ឬក្រសួងបរិស្ថាន ត្រូវរឹបអូសយកដីព្រៃទាំងនោះ មកទុកជាសម្បត្តិរដ្ឋវិញដោយស្វ័យប្រវត្ត ។

៥.៥-អភិបាលខេត្ត ក្រុង ត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីសកម្មភាពដោះស្រាយពាក្យប្តឹងតវ៉ាខាង លើនេះ ជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដើម្បីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានមូលដ្ឋានធ្វើ សេចក្តីរាយការណ៍ ជូនប្រមុខរាជរដ្ឋាភិបាល ។ ក្នុងករណីចាំបាច់ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី នឹង ចុះធ្វើអធិការកិច្ច លើដំណោះស្រាយទាំងឡាយណា ដែលមានភាពមិនប្រក្រតី ។

៥.៦-ដីព្រៃឈើគ្រប់ប្រភេទ ដែលប្រមូលបានដូចមានចែងក្នុងចំណុច ៥.៣ និងចំណុច ៥.៤ ខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង/ឬក្រសួងបរិស្ថាន ត្រូវស្នើទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើការចុះបញ្ជីដីនោះ ក្នុងសៀវភៅគោលបញ្ជីដីធ្លី ថាជាដីរដ្ឋតាមនីតិវិធីច្បាប់ជាធរមាន ។

៥.៧-អភិបាលខេត្ត ក្រុង ត្រូវបន្តចេញដីកាប្រកាសបដិសេធ និងដកហូតដីព្រៃឈើគ្រប់ប្រភេទ ដែលត្រូវបានរំលោភកាន់កាប់ដោយខុសច្បាប់ ជាការចាំបាច់ និងបន្ទាន់ ។

៦- គោលនយោបាយចំពោះអ្នកកាន់កាប់ដីរដ្ឋដោយខុសច្បាប់ :

៦.១-អ្នកដែលកាន់កាប់ដីរដ្ឋដោយខុសច្បាប់ គ្មានសិទ្ធិទាមទារសំណង និងអាចត្រូវទទួលទោស ដូចមានចែងក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១ ។

៦.២-គ្រួសារក្រីក្រគ្មានដី ឬខ្វះដី ជនងាយរងគ្រោះ ដែលកាន់កាប់ដីរដ្ឋដោយខុសច្បាប់ គ្មានសិទ្ធិទាមទារសំណង ប៉ុន្តែរាជរដ្ឋាភិបាលអាចផ្តល់ការអនុគ្រោះក្នុងការទទួលបានដី ដែលមានទំហំសមស្រប ដើម្បីប្រកបរបរចិញ្ចឹមជីវិត និង/ឬស្នាក់នៅ តាមករណីជាក់ស្តែង ដូចមានចែងក្នុងចំណុច ៧ នៃសារាចរនេះ ។

៦.៣-ករណីពាក់ព័ន្ធនឹងជនជាតិដើមភាគតិច ដែលអាជ្ញាធរប្រពៃណីរបស់គេបានអះអាងថា ក្បាលដី ឬចំណែកនៃក្បាលដី ដែលជាកម្មវត្ថុនៃការទាមទាររបស់រដ្ឋមកវិញនោះ ស្ថិតក្រោមការប្រើប្រាស់ជាសមូហភាពតាមទំនៀមទំលាប់ប្រពៃណីរបស់ពួកគេ នោះការទាមទារយកដីមកវិញត្រូវផ្អាកសិន រហូតដល់ដីនោះត្រូវបានចុះបញ្ជីថាជាដីរដ្ឋ។ ប៉ុន្តែចំពោះការកាន់កាប់ និងការទាមទារសិទ្ធិលើដីដោយបុគ្គលឯកជនណាម្នាក់ជាជនជាតិដើមភាគតិច ដំណើរការទាមទារដកដីរដ្ឋមកវិញ ត្រូវអនុវត្តជាធម្មតា ដូចករណីអ្នកកាន់កាប់ដីរដ្ឋដោយខុសច្បាប់ជាទូទៅដែរ ។

៧- គោលនយោបាយចំពោះដីរដ្ឋដែលបានកាន់កាប់ដោយខុសច្បាប់ :

៧.១-ដីដែលជាកម្មវត្ថុនៃការដកយកមកវិញ ឬដីដែលបានដកយកមកវិញពីការកាន់កាប់ដោយខុសច្បាប់ ហើយដែលជាផ្នែកនៃដីឯកជនរបស់រដ្ឋ អាចជាកម្មវត្ថុនៃការលក់ ការជួល ការធ្វើប្រទានកម្ម ការផ្តល់សិទ្ធិផលុបភោគ ការផ្តល់សម្បទានដីសង្គមកិច្ច ការផ្តល់សម្បទានដីសេដ្ឋកិច្ច ឬការអនុញ្ញាតឱ្យប្រើប្រាស់ក្នុងទម្រង់ផ្សេងៗទៀត តាមនីតិវិធីជាធរមាន ។ ការសម្រេចអំពីជំរើសជាក់លាក់ណាមួយ ត្រូវធ្វើឡើងផ្អែកលើការសម្របសម្រួលរបស់អាជ្ញាធរដែនដី រវាងអាជ្ញាធរកាន់កាប់ដីរដ្ឋ និងបុគ្គលដែលកាន់កាប់ដី ឬគាំអំពីដីនោះ និងផ្អែកលើផែនការប្រើប្រាស់ដី ។

៧.២-ដីដែលជាកម្មវត្ថុនៃការទាមទារយកមកវិញ ឬដីដែលបានទាមទារយកមកវិញពីការកាន់កាប់ដោយខុសច្បាប់ ហើយជាផ្នែកនៃដីសាធារណៈរបស់រដ្ឋ មិនអាចជាកម្មវត្ថុនៃការលក់ ការជួលរយៈពេលវែង ការផ្តល់ជាសម្បទាន ឬការផ្តល់ជាកម្មសិទ្ធិបានឡើយ ។ ប៉ុន្តែ ដីសាធារណៈរបស់រដ្ឋនេះ អាចជាកម្មវត្ថុនៃ :

-ការជួលរយៈពេលខ្លី ហើយអាចបន្តជាថ្មីបានតាមនីតិវិធីជាធរមាន

-ការផ្តល់សិទ្ធិផលុបភោគ

-ការអនុញ្ញាតឱ្យកាន់កាប់ ឬប្រើប្រាស់ជាបណ្តោះអាសន្ន មិនទៀង ហើយអាចដកហូតវិញបាន

-ការចុះកិច្ចព្រមព្រៀងសហគមន៍ កិច្ចព្រមព្រៀងផ្សេងៗទៀត

-ឬការស្នើសុំធ្វើចំណាត់ថ្នាក់ដីឡើងវិញ ដោយអនុវត្តតាមនីតិវិធីជាធរមាន ។

៨ - ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ច មិនអាចរកភស្តុតាងបញ្ជាក់ អំពីពេលវេលានៃការចូលកាន់កាប់ដីរដ្ឋក្រោយច្បាប់ភូមិបាលឆ្នាំ ២០០១ ចូលជាធរមាន ឬមិនអាចរកភស្តុតាងបញ្ជាក់ពីការបោះបង់ចោលភោគៈ ហើយមានការទាមទារពីអ្នកកាន់កាប់ដីនោះ អាចផ្តល់ជូនអ្នកកាន់កាប់ ឬអ្នកទាមទារ ក្នុងករណីដែលដីនោះ :

-មិនជាប់ផលប្រយោជន៍សាធារណៈ ឬមិនមានចរិតបម្រើផលប្រយោជន៍សាធារណៈ

-មិនទាន់បានចុះបញ្ជីជាដីរដ្ឋ និង

-បានធ្វើអាជីវកម្មពិតប្រាកដ និងបានបំពេញលក្ខខណ្ឌតម្រូវផ្សេងៗទៀតនៃភោគៈស្របច្បាប់ ។

ទទួលបានសារាចរនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់សាលាខេត្ត-ក្រុង
-គ្រប់សាលាស្រុក-ខណ្ឌ
-គ្រប់សាលាឃុំ-សង្កាត់
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៧.សរណន

សារាចរណែនាំ
ស្តីពី
ការរៀបចំខួបលើកទី ៥៨ "ទិវាកុមារអន្តរជាតិ ១ មិថុនា " និងខួបលើកទី ៦ "ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា " ឆ្នាំ ២០០៧

ក្នុងអំឡុងឆ្នាំ ១៩៤២-១៩៤៤ នៃសង្គ្រាមលោកលើកទី២ ពួកហ្វាស៊ីសអ៊ីត្លែរបានបង្កវិនាសកម្មកាប់សម្លាប់ស្ត្រី និងកុមារនៅភូមិលីឌីសែ ប្រទេសឆេក និងភូមិអូរ៉ាឌី ប្រទេសបារាំង។ វិនាសកម្មនេះធ្វើឱ្យ ប្រជាជនក្នុងពិភពលោកឈឺចាប់យ៉ាងខ្លាំង ជំរុញឱ្យប្រទេសជាច្រើនលើពិភពលោក កំណត់យកថ្ងៃទី ១ មិថុនា នេះជាទិវាកុមារអន្តរជាតិ។ ដោយឡែកការប្រើប្រាស់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរ បានកើតមានក្នុងចំណោមកុមារប្រមាណជាង ១០០ លាននាក់ អាយុពី ៥ឆ្នាំ ដល់១៧ ឆ្នាំ។ ទម្រង់ដ៏អាក្រក់នោះ មាន ទាសករកុមារ ការជួញដូរកុមារ ពេស្យាចារកុមារ កុមារក្នុងជម្លោះប្រដាប់អាវុធ និងការប្រើប្រាស់កុមារក្នុងស្ថានភាព ងាយរងគ្រោះ។ ហេតុនេះហើយ បានជាអង្គភាពពលកម្មកុមារអន្តរជាតិ បានសម្រេចយកថ្ងៃ ១២ មិថុនា ជារៀងរាល់ឆ្នាំ ដើម្បីរំលឹកទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ។

ព្រះរាជាណាចក្រកម្ពុជាធ្លាប់បានជួបប្រទះ និងបានទទួលរងមហាវិនាសកម្មដ៏ធ្ងន់ធ្ងរ បង្កឡើងដោយរបបប្រល័យពូជសាសន៍ប៉ុល ពត ដែលបានធ្វើឱ្យប្រជាជន យុវជន កុមារ បាត់បង់សិទ្ធិជាមនុស្ស ត្រូវបានបង្ខំឱ្យធ្វើការជាទម្ងន់ រស់នៅយ៉ាងសែនវេទនា រងទារុណកម្ម និងការកាប់សម្លាប់ដោយអយុត្តិធម៌អស់រាប់លាននាក់។ ក្រោយ ថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ សិទ្ធិរបស់ប្រជាពលរដ្ឋ ជាពិសេស សិទ្ធិរបស់កុមារនៅកម្ពុជា ត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់ ដោយមានចែងច្បាស់ក្នុងរដ្ឋធម្មនុញ្ញ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលស្របទៅតាមអនុសញ្ញាអន្តរជាតិផ្សេងៗដែលពាក់ព័ន្ធនឹងកុមារ។ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញា ស្តីពីសិទ្ធិកុមារ នៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៩៩២ និងនៅឆ្នាំ ២០០២ បានផ្តល់សច្ចាប័នលើពិធីសារពីរ គឺ : **មួយ:** ការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ **ពីរ :**,ការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសរបស់កុមារ ។ នៅឆ្នាំ ២០០៣ រាជរដ្ឋាភិបាលបានចេញសេចក្តីថ្លែងការណ៍ស្តីពីកម្ពុជាដើម្បីកុមារ និងនៅឆ្នាំ ២០០៥ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាលេខ ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារ ហើយនៅពេលកន្លងមកថ្មីៗនេះ បានផ្តល់សច្ចាប័នលើអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។ ទន្ទឹមនេះ ព្រះរាជាណាចក្រកម្ពុជាក៏បានចុះកិច្ចព្រមព្រៀងជាមួយប្រទេសវៀតណាម

ប្រទេសថៃឡង់ដ៏ និងបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ក្នុងការលុបបំបាត់ការជួញដូរកុមារ និងស្ត្រី និងជួយជនរងគ្រោះ ។

ក្នុងស្មារតីបង្កើនសកម្មភាព នៃកិច្ចគាំទ្រ និងការពារដល់កុមារ ដើម្បីអនុវត្តឱ្យបានកាន់តែប្រសើរឡើង ថែមទៀតនូវសិទ្ធិចម្បងទាំង ០៤ របស់កុមារ គឺសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការការពារ សិទ្ធិក្នុងការអភិវឌ្ឍ និងសិទ្ធិក្នុងការចូលរួម និងដើម្បីលើកស្ទួយឧត្តមប្រយោជន៍របស់កុមារ រាជរដ្ឋាភិបាលណែនាំ ចាត់តាំងទិវាកុមារអន្តរជាតិ ១ មិថុនា និងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា ឆ្នាំ ២០០៧ ដូចខាងក្រោម :

១-ប្រធានបទនៃទិវាកុមារអន្តរជាតិ ១ មិថុនា ឆ្នាំនេះគឺ "**យើងរួមគ្នាលុបបំបាត់អំពើហិង្សាលើកុមារ** " ។

២-គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ ត្រូវធ្វើកិច្ចសហការគ្នាជាមួយ អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋ ដើម្បីឧបត្ថម្ភគាំទ្រ និងផ្សព្វផ្សាយជូនដល់អង្គភាពក្រោមឱវាទ និងសង្គមជាតិទាំងមូលឱ្យបានជ្រួតជ្រាប អំពីប្រវត្តិនៃទិវាកុមារ អន្តរជាតិ ១ មិថុនា និងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា។

៣-គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីខេត្ត ក្រុង ត្រូវរៀបចំពិធីមីទិញ ឬពិធីជួបសំណេះសំណាល ជាមួយកុមារ និងមានកម្មវិធីកំសាន្តសប្បាយរបស់កុមារ នៅក្នុងមូលដ្ឋានរបស់ខ្លួនតាមលទ្ធភាព ជាក់ស្តែង ។

៤-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ សាលាក្រុងភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំមីទិញ និងមានកម្មវិធីកំសាន្តផ្សេងៗ សម្រាប់កុមារនៅទីសាធារណៈ ឬរមណីយដ្ឋានណាមួយ សមស្របនៅរាជធានីភ្នំពេញ ឱ្យបានអធិកអធម ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីត្រៀម ថវិកាសម្រាប់ការរៀបចំពិធីនេះ ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់ខេត្ត ក្រុង ត្រូវរៀបចំ ចាត់តាំងអនុវត្តឱ្យបានប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-គ្រប់ក្រសួង ស្ថាប័ន

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-សាលាខេត្ត ក្រុង

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...៤៦៥.....សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០០៧

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជា ឆ្នាំ២០០៧

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក.ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០ នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែ ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ៦៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២៣ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៦
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០៣ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

- បានឃើញក្រឹត្យលេខ៥៧ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញ នាំចេញនាំចូល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលបានប្រកាស ឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០០១
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាអន្តរជាតិ ស្តីពីការធ្វើឱ្យស៊ីចង្វាក់គ្នានៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ
- បានឃើញពិធីសារស្តីពីការអនុវត្តនាមវលី នៃតារាងពន្ធគយស៊ីចង្វាក់គ្នារបស់អាស៊ាន ដែលចុះហត្ថលេខា ដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៣ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធ និងអាករគយលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ អាករពិសេស លើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ : ដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ២០០៧ ដូចមានភ្ជាប់ជាមួយនេះ ដែលបានរៀបចំដោយអនុលោមតាមប្រព័ន្ធស៊ីចង្វាក់ នៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ និងស្របទៅតាមតារាងពន្ធគយ នៃប្រព័ន្ធស៊ីចង្វាក់របស់អាស៊ាន (AHTN 2007) ចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០០៧ តទៅ ។

ប្រការ ២ : រាល់មុខទំនិញនាំចេញ នាំចូលត្រូវជាប់ពន្ធនាំចូល អាករពិសេស អាករលើតម្លៃបន្ថែម និងអាករនាំចេញ ដូចមានចែងលំអិតក្នុងតារាងពន្ធគយនេះ ។

ប្រការ ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលបានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ ខាងមុខនេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

<u>ចម្លងជូន</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន ខេត្តក្រុង "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្ម
- ទីចាត់ការគយ និងរដ្ឋាករ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ត មកពីរាជកិច្ចលេខ ៥៥ .... ៥៦

	(a)	ល្បាយ ឬគ្រឿងចំណីអាហារដែលមានជាតិជាខ្លាញ់ ឬប្រេងអំពីសត្វ ឬរុក្ខជាតិ ប្រភេទប្រើប្រាស់ជាផលិតផលសំរាប់ដោះចេញពីពុម្ពនៃទីតាំងលេខ ១៥.១៧ ។	Edible mixtures or preparations of animal or vegetable fats or oils of a kind used as mould release preparations (heading No. 15.17);
	(b)	ប្រភេទចំណីផ្សេងទៀតដែលមានជាតិគីមីមួយចំនួនជាក់លាក់	Separate chemically defined compounds; or
	(c)	សាប៊ូកក់សក់ ថ្នាំដុសធ្មេញ ក្រែម និងថ្នាំសំរាប់កោរពុកមាត់ និងផលិតផលសំរាប់ងូតទឹកជំរះកាយ ដូចជាវាមានសាប៊ូ ឬវត្ថុគ្រឿងសំអាតផ្ទៃខាងក្រៅនៃសរីរាង្គ (ទីតាំងលេខ ៣៣.០៥ ៣៣.០៦ ឬ ៣៣.០៧) ។	Shampoos, dentifrices, shaving creams and foams, or bath preparations, containing soap or other organic surface-active agents (heading No 33.05, 33.06 or 33.07).
2.-		តាមន័យនៃទីតាំងលេខ ៣៤.០១ ពាក្យថា "សាប៊ូ" សំរាប់តែសាប៊ូដែលរលាយនៅក្នុងទឹក ។ សាប៊ូ និងផលិតផលផ្សេងទៀត ដែលស្ថិតនៅក្នុងទីតាំងនេះអាចនឹងត្រូវបន្ថែមនូវសារជាតិផ្សេងទៀត "ដូចជាថ្នាំសំលាប់មេរោគ ម្សៅខាត់ ហ្វីលើ (Filler) ផលិតផលឱសថ" ។ ផលិតផលសំរាប់ខាត់ទាំងឡាយនឹងត្រូវរាប់បញ្ចូល ទៅក្នុងទីតាំងនេះ ក្នុងករណី ដែលវាមានរាងជាដុំ ជាផែន ឬជាពំបង ។ ប្រសិនបើវាមានរាងផ្សេងទៀតត្រូវ ចាត់ថ្នាក់ទៅក្នុងទីតាំងលេខ ៣៤.០៥ ដូចជាម្សៅស្វិត ទន់ និងម្សៅស្អាតសំរាប់ ដុសខាត់ និងវត្ថុប្រហាក់ប្រហែល ។	For the purposes of heading No. 34.01, the expression "soap" applies only to soap soluble in water. Soap and the other products of heading No. 34.01 may contain added substances (for example, disinfectants, abrasive powders, fillers or medicaments). Products containing abrasive powders remain classified in heading No. 34.01 only if in the form of bars, cakes or moulded pieces or shapes. In other forms they are to be classified in heading No. 34.05 as "scouring powders and similar preparations".
3.-		តាមន័យទីតាំងលេខ ៣៤.០២ (វត្ថុសំរាប់សំអាតផ្ទៃខាងក្រៅនៃសរីរាង្គ) គឺជាផលិតផលដែលកាលបើគេលាយវាជាមួយនឹងទឹកចំនួន ០,៥% ក្នុងសីតុណ្ហភាព ២០°c និងទុកឱ្យវានៅស្ងៀមក្នុងរយៈពេលមួយម៉ោងក្នុងសីតុណ្ហភាពដដែល ។	For the purposes of heading No. 34.02, "organic surface-active agents" are products which when mixed with water at a concentration of 0.5 % at 20 °C and left to stand for one hour at the same temperature :
	(a)	វាបង្កើតឱ្យមាននូវវត្ថុរាវថ្លាឬផ្កូល្អក់ ល្បាយថេរដោយមិនផ្តាច់ចេញពីអង្គធាតុមិនរលាយក្នុងទឹក ។	give a transparent or translucent liquid or stable emulsion without separation of insoluble matter; and

	(b)	កាត់បន្ថយតង់ស្យុងផ្ទៃលើរបស់ទឹកតាមរូបមន្ត 4.5 x 10^{-2} N/m (45 dyne/cm) ឬតិចជាង ។	reduce the surface tension of water to 4.5 x 10^{-2} N/m (45 dyne/cm) or less.
4.-		ពាក្យ "ប្រេងនៃតេលសិលា ឬប៊ីទីម" នៅក្នុងទីតាំងលេខ ៣៤.០៣ គោលប្រើចំពោះតែផលិតផលដែលមានចែងនៅក្នុងកំណត់សំគាល់ ២ នៃជំពូក ២៧ ។	In heading No. 34.03 the expression "petroleum oils and oils obtained from bituminous minerals" applies to the products defined in Note 2 to Chapter 27.
5.-		លើកលែងតែវត្ថុធាតុដែលចែងនៅខាងក្រោមនេះ ពាក្យថា "ក្រមួន" ពីក្រមួនសិប្បនិម្មិត និងក្រមួនកែច្នៃដែលគេរៀបចំហើយ(ដែលគេប្រើនៅក្នុងសេចក្ដីយោងទីតាំងលេខ៣៤.០៤) អនុវត្តទៅលើ :	In heading No. 34.04, subject to the exclusions provided below, the expression "artificial waxes and prepared waxes" applies only to :
	(a)	ផលិតផលដែលមានលក្ខណៈជាក្រមួនដែលបានដោយវិធីគីមី ទោះវាស្ថិតនៅក្នុងភាពរលាយក្នុងទឹកក៏ដោយ ។	Chemically produced organic products of a waxy character, whether or not water-soluble;
	(b)	ផលិតផលទទួលបានដោយការលាយបញ្ចូលគ្នានូវក្រមួនផ្សេងៗ ។	Products obtained by mixing different waxes;
	(c)	ផលិតផលដែលមានលក្ខណៈជាក្រមួនមួយមុខឬច្រើនមុខ ដែលមានមូលដ្ឋានពីក្រមួន ឬជាតិចាហ៊ុីនម្យ៉ាងទៀតវាមានជាតិខ្លាញ់ជាតិជ័រ និងជាតិរ៉ែ ឬអង្គធាតុផ្សេងទៀត ។	Products of a waxy character with a basis of one or more waxes and containing fats, resins, mineral substances or other materials.
		ទីតាំងនេះមិនអនុវត្តចំពោះ ÷	The heading does not apply to :
	(a)	ផលិតផលទីតាំងលេខ ១៥.១៦ ៣៤.០២ ឬ ៣៨.២៣ ទោះបីវាមានលក្ខណៈជាក្រមួនក៏ដោយ ។	Products of heading No. 15.16, 34.02 or 38.23, even if having a waxy character;
	(b)	ក្រមួនដែលបានមកពីសត្វដែលមិនទាន់លាយនឹងក្រមួនបានមកពីរុក្ខជាតិដែលមិនទាន់លាយនៃទីតាំងលេខ ១៥.២១ ទោះជាកែច្នៃ ឬជាក់ពណ៌ហើយក៏ដោយ។	Unmixed animal waxes or unmixed vegetable waxes, whether or not refined or coloured, of heading No. 15.21;

(c) ក្រមួនដែលបានមកពីរ៉ែ និងផលិតផលប្រហាក់ប្រហែលនៃទីតាំងលេខ ២៧.១២ ទោះជាលាយគ្នា ឬគ្រាន់តែជាក់ពណ៌។ Mineral waxes or similar products of heading No. 27.12, whether or not intermixed or merely coloured; or

(d) ក្រមួនលាយ ឬលាយជាមួយវត្ថុរាវ (ទីតាំងលេខ ៣៤.០៥ ៣៨.០៩ ...) ។ Waxes mixed with, dispersed in or dissolved in a liquid medium (headings Nos. 34.05, 38.09, etc.).

Head.	Tariff Code	បរិយាយមុខទំនិញ	Description of Goods	Unit	Duty and Tax (%)				Reference
					Imp.			Exp	
					CD	ST	VAT	ET	
34.01		សាប៊ូ ផលិតផល និងគ្រឿងសរីរាង្គដែលមានផ្ទៃខាងក្រៅសំរាប់ប្រើជាសាប៊ូរាងជាដុំបងជាផែន ជាដុំ ឬជារូបភាពផ្សេងៗទោះជាមានជាតិសាប៊ូក៏ដោយក្រដាស សំឡី កប្បាស ហ្វឺត និង សំពត់មិនត្បាញជ្រលក់ លាបឬស្រោបជាមួយសាប៊ូ ម្សៅសាប៊ូ ។	**Soap; organic surface-active products and preparations for use as soap, in the form of bars, cakes, moulded pieces or shapes, whether or not containing soap; paper, wadding, felt and nonwovens, impregnated, coated or covered with soap or detergent.**						
		- សាប៊ូ ផលិតផលនិងគ្រឿងសរីរាង្គដែលមានផ្ទៃខាងក្រៅសំរាប់ប្រើជាសាប៊ូរាងជាដុំបង ជាផែន ជាដុំ ឬជារូបភាពផ្សេងៗទោះជាមានជាតិសាប៊ូក៏ដោយ ក្រដាស សំឡី កប្បាស ហ្វឺត និងសំពត់មិនត្បាញជ្រលក់លាបឬស្រោបជាមួយសាប៊ូម្សៅសាប៊ូ :	- Soap,organic surface-active products and preparations , in the form of bars, cakes, moulded pieces or shapes, and paper, wadding, felt and nonwovens, impregnated, coated or covered with soap or detergent:						
	3401.11	- - សំរាប់ប្រើការថែរក្សាខ្លួនប្រើទឹក (រួមទាំងផលិតផលឱសថ) :	- - For toilet use (including medicated products):						
	3401.11.10	- - - ផលិតផលដែលមានជាតិឱសថ	- - - Medicated products	kg	7	0	10	0	
	3401.11.20	- - - សាប៊ូដុសខ្លួន	- - - Bath soap	kg	7	0	10	0	
	3401.11.30	- - - ជាហ្វឺត ឬក្រណាត់មិនត្បាញជ្រលក់ លាបឬស្រោបជាមួយសាប៊ូ ឬសារធាតុម្សៅសាប៊ូផ្សេងទៀត ។	- - - Other of felt and nonwovens, impregnated, coated or covered with soap or detergent	kg	7	0	10	0	
	3401.11.90	- - - ផ្សេងទៀត	- - - Other	kg	7	0	10	0	
	3401.19	- - ផ្សេងទៀត :	- - Other :						

	3401.19.10	- - - នៃហ្វឺត និងក្រណាត់មិនត្បាញជ្រលក់ លាប ឬ ស្រោបដោយសាប៊ូ ឬ សារធាតុម្សៅសាប៊ូ ។	- - - Of felt and non-woven, impregnated, coated or covered with soap or detergent	kg	7	0	10	0	
	3401.19.90	- - - ផ្សេងទៀត	- - - Other	kg	7	0	10	0	
	3401.20	- សាប៊ូ ដែលមានសណ្ឋានផ្សេងទៀត :	- Soap in other forms:						
	3401.20.10	- - សំរាប់លាងទឹកល័ក្ខនៃក្រដាសដែលប្រើបានច្រើនដង	- - For flotation de-inking of recycled paper	kg	7	0	10	0	
	3401.20.90	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
	3401.30.00	- ផលិតផលសំរាប់សំអាតផ្ទៃខាងក្រៅសរីរាង្គ និងផលិតផលសំរាប់ដុសលាងស្បែក មានទំរង់ជាវត្ថុរាវ ឬក្រែម ហើយសំរាប់លក់រាយ ទោះមាន ឬមិនមានជាតិសាប៊ូ	- Organic surface-active products and preparations for washing the skin, in the form of liquid or cream and put up for retail sale, whether or not containing soap	kg	7	0	10	0	
34.02		ភារកៈសំរាប់សំអាតផ្ទៃក្រសើរាង្គ (ក្រៅពីសាប៊ូ) ។ ផលិតផលសំរាប់សំអាតផ្ទៃខាងក្រៅ ផលិតផលសំរាប់បោកលាង (រាប់បញ្ចូលទាំងផលិតផលជំនួយជាទៀតនៅក្នុងការដុសលាង) និងផលិតផលជូតសំអាតទោះមានឬគ្មានជាតិសាប៊ូក៏ដោយ ក្រៅពីផលិតផលដែលក្នុងទីតាំងលេខ ៣៤.០១ ។	Organic surface-active agents (other than soap); surface-active preparations, washing preparations (including auxiliary washing preparations) and cleaning preparations, whether or not containing soap, other than those of heading No 34.01.						
		- ភារកៈសំរាប់សំអាតផ្ទៃខាងក្រៅសរីរាង្គសកម្មលាត ទោះជាសំរាប់លក់រាយ ឬមិន លក់រាយក៏ដោយ :	- Organic surface - active agents, whether or not put up for retail sale :						
	3402.11	- - អានីអូនិក:	- - Anionic:						
	3402.11.10	- - - អាល់កុលមានជាតិស៊ុលហ្វាត	- - - Sulphated fatty alcohols	kg	7	0	10	0	
	3402.11.20	- - - សារធាតុធ្វើឱ្យសើមដែលប្រើក្នុងការផលិតគីណាជាត	- - - Wetting agents used in the manufacture of herbicide	kg	7	0	10	0	
	3402.11.90	- - - ផ្សេងទៀត	- - - Other	kg	7	0	10	0	
	3402.12	- - កាទីអូនិក:	- - Cationic:						
	3402.12.10	- - - សារធាតុធ្វើឱ្យសើមដែលប្រើក្នុងការផលិតគីណាជាត	- - - Wetting agents used in the manufacture of herbicide	kg	7	0	10	0	

	3402.12.90	- - - ផ្សេងទៀត	- - - Other	kg	7	0	10	0	
	3402.13.00	- - មិនមែនអ៊ីយ៉ូនិក	- - Non-ionic	kg	7	0	10	0	
	3402.19.00	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
	3402.20	- វត្ថុធាតុសំរាប់ដាក់លក់រាយ :	- Preparations put up for retail sale :						
		- - វត្ថុធាតុរាវ:	- - In liquid form:						
	3402.20.11	- - - វត្ថុធាតុអានីអូនិកសំរាប់សំអាតផ្ទៃខាងក្រៅ	- - - Anionic surface active preparations	kg	7	0	10-	0	
	3402.20.12	- - - វត្ថុធាតុដុសលាងអានីអូនិក និងសំអាត រួមទាំងវត្ថុធាតុដែលធ្វើឱ្យស ស្អាត និង សំអាតខ្លាញ់	- - - Anionic washing preparations and cleaning preparations, including bleaching, cleansing and degreasing preparations	kg	7	0	10	0	
	3402.20.13	- - - វត្ថុធាតុសំរាប់សំអាតផ្ទៃខាងក្រៅផ្សេងទៀត	- - - Other surface active preparations	kg	7	0	10	0	
	3402.20.19	- - - វត្ថុធាតុដុសលាងផ្សេងទៀត និងសំអាត រួមទាំងវត្ថុធាតុដែលធ្វើឱ្យស ស្អាត និង សំអាតខ្លាញ់	- - - Other washing preparations and cleaning preparations, including bleaching, cleansing and degreasing preparations	kg	7	0	10	0	
		- - ផ្សេងទៀត :	- - Other:						
	3402.20.91	- - - វត្ថុធាតុអានីអូនិកសំរាប់សំអាតផ្ទៃខាងក្រៅ	- - - Anionic surface active preparations	kg	7	0	10	0	
	3402.20.92	- - - វត្ថុធាតុដុសលាងអានីអូនិក និងសំអាត រួមទាំងវត្ថុធាតុដែលធ្វើឱ្យស ស្អាត និង សំអាតខ្លាញ់	- - - Anionic washing preparations and cleaning preparations, including bleaching, cleansing and degreasing preparations	kg	7	0	10	0	
	3402.20.93	- - - វត្ថុធាតុអានីអូនិកសំរាប់សំអាតផ្ទៃខាងក្រៅ	- - - Other surface active preparations	kg	7	0	10	0	
	3402.20.99	- - - វត្ថុធាតុដុសលាងផ្សេងទៀត និងសំអាត រួមទាំងវត្ថុធាតុដែលធ្វើឱ្យស ស្អាត និង សំអាតខ្លាញ់	- - - Other washing preparations and cleaning preparations, including bleaching, cleansing and degreasing preparations	kg	7	0	10	0	
	3402.90	- ផ្សេងទៀត:	- Other						
		- - វត្ថុធាតុរាវ:	- - In liquid form:						
		- - - វត្ថុធាតុអានីអូនិកសំរាប់សំអាតផ្ទៃខាងក្រៅ	- - - Anionic surface active preparations						
	3402.90.11	- - - - ភ្នាក់ងារសំណើម	- - - - Wetting agents	kg	7	0	10	0	

	3402.90.12	- - - ផ្សេងទៀត	- - - Other	kg	7	0	10	0	
	3402.90.13	- - - វត្ថុធាតុដុសលាងអានីអូនិក និងសំអាត រួមទាំងវត្ថុធាតុដែលធ្វើឱ្យស ស្អាត និង សំអាតខ្លាញ់	- - - Anionic washing preparations and cleaning preparations, including bleaching, cleansing and degreasing preparations	kg	7	0	10	0	
		- - - វត្ថុធាតុអានីអូនិកសំរាប់សំអាតផ្ទៃខាងក្រៅ :	- - - Other surface active preparations:						
	3402.90.14	- - - - ភ្នាក់ងារសំណើម	- - - - Wetting agents	kg	7	0	10	0	
	3402.90.15	- - - - ផ្សេងទៀត	- - - - Other	kg	7	0	10	0	
	3402.90.19	- - - វត្ថុធាតុដុសលាងផ្សេងទៀត និងសំអាត រួមទាំងវត្ថុធាតុដែលធ្វើឱ្យស ស្អាត និង សំអាតខ្លាញ់	- - - Other washing preparations and cleaning preparations, including bleaching, cleansing and degreasing preparations	kg	7	0	10	0	
		- - ផ្សេងទៀត:	- - Other:						
		- - - វត្ថុធាតុអានីអូនិកសំរាប់សំអាតផ្ទៃខាងក្រៅ	- - - Anionic surface active preparations						
	3402.90.91	- - - - ភ្នាក់ងារសំណើម	- - - - Wetting agents	kg	7	0	10	0	
	3402.90.92	- - - - ផ្សេងទៀត	- - - - Other	kg	7	0	10	0	
	3402.90.93	- - - វត្ថុធាតុដុសលាងអានីអូនិក និងសំអាត រួមទាំងវត្ថុធាតុដែលធ្វើឱ្យស ស្អាត និង សំអាតខ្លាញ់	- - - Anionic washing preparations and cleaning preparations, including bleaching, cleansing and degreasing preparations	kg	7	0	10	0	
		- - - វត្ថុធាតុអានីអូនិកសំរាប់សំអាតផ្ទៃខាងក្រៅ:	- - - Other surface active preparations:						
	3402.90.94	- - - - ភ្នាក់ងារសំណើម	- - - - Wetting agents	kg	7	0	10	0	
	3402.90.95	- - - - ផ្សេងទៀត	- - - - Other	kg	7	0	10	0	
	3402.90.99	- - - វត្ថុធាតុដុសលាងផ្សេងទៀត និងសំអាត រួមទាំងវត្ថុធាតុដែលធ្វើឱ្យស ស្អាត និង សំអាតខ្លាញ់	- - - Other washing preparations and cleaning preparations, including bleaching, cleansing and degreasing preparations	kg	7	0	10	0	

34.03		ផលិតផលដែលធ្វើឱ្យរអិល (ដោយរាប់បញ្ចូលទាំងផលិតផលប្រេងកាត់ ផលិតផលសំរាប់បោះប៊ូឡុង និងខ្ចៅ ផលិតផលសំរាប់លាបកុម្មដែលមាន មូលដ្ឋានជាប្រេងរំអិល) និងប្រភេទផលិតផលដែលគេប្រើប្រាស់សំរាប់ លាបប្រេង ឬខ្លាញ់លើសំភារៈវាយនភ័ណ្ឌ ការបញ្ចូលជាតិប្រេង និងជាតិ ខ្លាញ់ទៅក្នុងស្បែក ស្បែកជាប់រោម និងអង្គធាតុឯទៀត ដោយលើកលែង នូវរបស់មួយចំនួនដែលមានជាតិប្រេងឬប្រេងកាតឬជាតិប៊ីទូមលើសពី ៧០% ។	**Lubricating preparations, (including cutting-oil preparations, bolt or nut release preparations, anti-rust or anti-corrosion preparations and mould release preparations, based on lubricants) and preparations of a kind used for the oil or grease treatment of textile materials, leather, furskins or other materials, but excluding preparations containing, as basic constituents, 70 % or more by weight of petroleum oils or of oils obtained from bituminous minerals.**						
		- ដែលមានជាតិប្រេងឥន្ធនៈ ឬប្រេងដែលមានចំរាញ់ពីប៊ីទូម :	- Containing petroleum oils or oils obtained from bituminous minerals:						
	3403.11	- - វត្ថុប្រេងសំរាប់លាបសំភារៈវាយនភ័ណ្ឌ ស្បែក ស្បែកជាប់រោម ឬរបស់ផ្សេងទៀត :	- - Preparations for the treatment of textile materials, leather, furskins or other materials:						
		- - - ជាទម្រង់រាវ :	- - - In liquid form:						
	3403.11.11	- - - - វត្ថុធាតុដើមប្រេងរំអិល	- - - - Lubricating oil preparation	kg	7	0	10	0	
	3403.11.19	- - - - ផ្សេងទៀត	- - - - Other	kg	7	0	10	0	
	3403.11.90	- - - ផ្សេងទៀត	- - - Other	kg	7	0	10	0	
	3403.19	- - ផ្សេងទៀត :	- - Other:						
		- - - ជាទម្រង់រាវ :	- - - In liquid form:						
	3403.19.11	- - - - ប្រេងសំរាប់ម៉ាស៊ីនយន្តហោះ	- - - - Oil for aircraft engines	kg	7	0	10	0	
	3403.19.12	- - - - សារធាតុមានប្រេងស៊ីលីស	- - - - Preparation containing silicone oil	kg	7	0	10	0	
	3403.19.19	- - - - ផ្សេងទៀត	- - - - Other	kg	7	0	10	0	
	3403.19.90	- - - ផ្សេងទៀត	- - - Other	kg	7	0	10	0	
		- ផ្សេងទៀត :	- Other:						

	3403.91	- - វត្ថុធាតុប្រេងសំរាប់លាបសំភារៈវាយនភ័ណ្ឌ ស្បែក ស្បែកជាប់រោម ឬ របស់ផ្សេងទៀត :	- - Preparations for the treatment of textile materials, leather, furskins or other materials					
		- - - ជាទម្រង់រាវ :	- - - In liquid form:					
	3403.91.11	- - - - សារធាតុមានប្រេងស៊ីលីស	- - - - Preparation containing silicone oil	kg	7	0	10	0
	3403.91.19	- - - - ផ្សេងទៀត	- - - - Other	kg	7	0	10	0
	3403.91.90	- - - ផ្សេងទៀត	- - - Other	kg	7	0	10	0
	3403.99	- - ផ្សេងទៀត :	- - Other					
		- - - ជាទម្រង់រាវ:	- - - In liquid form:					
	3403.99.11	- - - - ប្រេងសំរាប់ម៉ាស៊ីនយន្តហោះ	- - - - Oil for aircraft engines	kg	7	10	10	0
	3403.99.12	- - - - សារធាតុមានប្រេងស៊ីលីស	- - - - Preparation containing silicone oil	kg	7	10	10	0
	3403.99.19	- - - - ផ្សេងទៀត	- - - - Other	kg	7	10	10	0
	3403.99.90	- - - ផ្សេងទៀត	- - - Other	kg	7	10	10	0
34.04		ក្រមួនសិប្បនិម្មិត និងក្រមួនដែលកែច្នៃរួច	**Artificial waxes and prepared waxes.**					
	3404.20.00	- ដែលមានសារធាតុប៉ូលីអ៊ែទីឡែន គ្លីកុល	- Of poly (oxyethylene) (polyethylene glycol)	kg	35	0	10	0
	3404.90.00	- ផ្សេងទៀត	- Other	kg	35	0	10	0
34.05		ក្រមួនខាត់និងក្រែមសំរាប់ខាត់ស្បែកជើង សង្ហារឹម កំរាល តួរថយន្ត ឬលោហធាតុ ម្សៅស្អិតខាត់ និងម្សៅស្អិតសំរាប់ខាត់និងផលិតផលប្រហាក់ប្រហែល (ទោះបីជាមាន ឬគ្មានរូបភាពជាក្រដាស សំឡី កប្បាស ហ្វឺត ក្រណាត់មិនត្បាញ រូបធាតុផ្លាស្ទិកឬកៅស៊ូ ដែលមានរន្ធតូចៗជ្រលក់លាប ឬស្រោបដោយផលិតផលនេះ) ដោយលើកលែងនូវក្រមួនដែលមានចែងនៅក្នុងទីតាំងលេខ ៣៤.០៤ ។	**Polishes and creams, for footwear, furniture, floors, coachwork, glass or metal, scouring pastes and powders and similar preparations (whether or not in the form of paper, wadding, felt, nonwovens, cellular plastics or cellular rubber, impregnated, coated or covered with such preparations), excluding waxes of heading No. 34.04.**					

	3405.10.00	- ក្រមួនខាត់ និង ក្រែម ឬវត្ថុធាតុស្រដៀងសំរាប់ដុសខាត់ស្បែកជើង	- Polishes, creams and similar preparations for footwear or leather	kg	35	0	10	0	
	3405.20.00	- ក្រមួនខាត់ និង ក្រែម ឬវត្ថុធាតុស្រដៀងសំរាប់ថែគ្រឿងសង្ហារឹមអំពីឈើ ក្តារក្រាល ឬ សំភារៈឈើផងទៃ ។	- Polishes, creams and similar preparations for the maintenance of wooden furniture, floors or other woodwork	kg	35	0	10	0	
	3405.30.00	- ក្រមួន និងវត្ថុធាតុស្រដៀងសំរាប់ការងារទូររថភ្លើង លើកលែងតែក្រមួនសំរាប់ដុសខាត់លោហធាតុ ។	- Polishes and similar preparations for coachwork, other than metal polishes	kg	35	0	10	0	
	3405.40	- ថ្នាំ និងម្សៅសំរាប់ខាត់ និងវត្ថុធាតុសំរាប់ខាត់ផ្សេងទៀត :	- Scouring pastes and powders and other scouring preparations:						
	3405.40.10	- - ម្សៅស្អិតទន់ និងម្សៅស្ងួត	- - Scouring pastes and powders	kg	35	0	10	0	
	3405.40.90	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
	3405 90	- ផ្សេងទៀត	- Other						
	3405.90.10	- - ម្សៅលោហៈ	- - Metal polishes	kg	35	0	10	0	
	3405.90.90	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
34.06	3406.00.00	ទៀន និងប្រភេទទៀនប្រហាក់ប្រហែល	Candles, tapers and the like.	kg	35	0	10	0	
34.07		ម្សៅសំរាប់សូនរូប ដោយរាប់បញ្ចូលទាំងម្សៅដែលគេប្រើសំរាប់ធ្វើជារបស់ក្មេងលេងធាតុផ្សំដែលគេហៅថា "ក្រមួនសំរាប់ធេ្មញ" ដែលគេបង្ហាញជាកញ្ចប់ដូចគ្នាសំរាប់លក់រាយឬជាបន្ទះតូចៗជារាងក្រចកសេះ ដំបង ជារាងប្រ ហាក់ប្រហែលធាតុផ្សំផ្សេងទៀតសំរាប់ធេ្មញដែលមានមូលដ្ឋានពីប្លាងសិលា។	**Modelling pastes, including those put up for children's amusement; preparations known as "dental wax" or as "dental impression compounds", put up in sets, in packings for retail sale or in plates, horseshoe shapes, sticks or similar forms; other preparations for use in dentistry, with a basis of plaster (of calcined gypsum or calcium sulphate).**						
	3407.00.10	- ម្សៅសំរាប់សូនរូប ដោយរាប់បញ្ចូលទាំងម្សៅដែលគេប្រើសំរាប់ធ្វើជារបស់ក្មេងលេង	- Modelling pastes, including those put up for amusement	kg	35	0	10	0	

	3407.00.20	- ធាតុផ្សំដែលគេហៅថា "ក្រមួនសំរាប់ពេទ្យធ្មេញ" ដែលគេបង្គុំជាកញ្ចប់ ដូចគ្នាសំរាប់លក់រាយ ឬ ជាបន្ទះតូចៗ ជារាងក្រចកសេះ រាងជាដំបង ជារាងប្រហាក់ប្រហែល	- Preparations known as "dental wax" or "dental impression compounds", put up in sets, in packings for retail sale or in plates, horseshoe shapes, sticks or similar forms	kg	35	0	10	0	
	3407.00.30	- ធាតុផ្សំផ្សេងទៀតសម្រាប់ប្រើក្នុងពេទ្យធ្មេញ ដែលមានមូលដ្ឋានពីម្នាងសិលា (ម្នាងសិលាកាល់ស៊ីន ឬកាល់ស្យូមស៊ុលហ្វាត)	- Other preparations for use in dentistry, with a basis of plaster (of calcined gypsum or calcium sulphate)	kg	35	0	10	0	

ជំពូកទី ៣៥

Chapter 35

សារធាតុអលប៊ុយមីនជាតិ ឬម្សៅធញ្ញជាតិ បច្ចុជាតិកែច្នៃ កាវ អង់ស៊ីម

Albuminoidal substances; modified starches; glues; enzymes

កំណត់សំគាល់

1.- ជំពូកនេះមិនរាប់បញ្ចូលនូវ ៖

(a) មេដំបែ (ទីតាំងលេខ ២១.០២)

(b) ធាតុបង្កបស់ឈាម (ក្រៅពីអាល់ប៊ុយមីនរបស់ឈាមមិនទាន់រៀបចំដែលគេប្រើសំរាប់ព្យាបាល ឬបង្ការរោគ) ឱសថ និងផលិតផលផ្សេងទៀតមានចែងនៅក្នុងជំពូកទី ៣០ ។

(c) ផលិតផលដែលមានជាតិអង់ស៊ីម ដើម្បីប្រើសំរាប់ឆាប់ស្បែក (ទីតាំងលេខ ៣២.០២) ។

(d) ផលិតផលដែលមានជាតិអង់ស៊ីមដើម្បីត្រាំ ឬសំរាប់បោកលាង និងផលិតផលផ្សេងទៀត ដែលមានចែងនៅក្នុងជំពូកទី ៣៤ ។

(e) ជាតិប្រូតេអ៊ីនរឹង (ទីតាំងលេខ ៣៩.១៣) ឬ

Notes

1.- This Chapter does not cover :

(a) Yeasts (heading No. 21.02);

(b) Blood fractions (other than blood albumin not prepared for therapeutic or prophylactic uses), medicaments or other products of Chapter 30;

(c) Enzymatic preparations for pre-tanning (heading No. 32.02);

(d) Enzymatic soaking or washing preparations or other products of Chapter 34;

(e) Hardened proteins (heading No. 39.13); or

(f) ផលិតផលដែលមានជាតិចាប់អង្កិលសំរាប់ប្រើក្នុងឧស្សាហកម្មបោះពុម្ព (ជំពូកទី ៤៩) ។ Gelatin products of the printing industry (Chapter 49).

2.- តាមអត្ថន័យនៃទីតាំងលេខ ៣៥.០៥ ពាក្យ "Dextrin" គឺជាផលិតផល ដែលមានបម្លែងជាតិកិច្ចស្ត ដោយបន្ថយបរិមាណជាតិស្ករ បញ្ជាក់ជាសណ្ឋាន នៃគ្លុយកូសនៅលើអង្គធាតុស្ងួតដែលមិនលើសពី ១០ % ។ For the purposes of heading No. 35 05, the term "dextrins" means starch degradation products with a reducing sugar content, expressed as dextrose on the dry substance, not exceeding 10 %.

ផលិតផលដែលបន្ថយបរិមាណស្ករលើសពី ១០% ត្រូវចាត់ចូលទៅក្នុងទីតាំង លេខ ១៧.០២ ។ Such products with a reducing sugar content exceeding 10 % fall in heading No 17 02.

Head.	Tariff Code	បរិយាយមុខទំនិញ	Description of Goods	Unit	Duty and Tax (%)				Reference
					Imp.			Exp.	
					CD	ST	VAT	ET	
35.01		ការសេអ៊ីន និងវត្ថុដទៃទៀតដែលចំរាញ់ចេញពីការសេអ៊ីន កាវការសេអ៊ីន	**Casein, caseinates and other casein derivatives; casein glues.**						
	3501.10.00	- ការសេអ៊ីន	- Casein	kg	35	0	10	0	
	3501.90	- ផ្សេងទៀត	- Other						
	3501.90.10	- - កាស៊ីណាត និងកាស៊ីនដទៃទៀត និងដេរីវេរបស់វា	- - Caseinates and other casein derivatives	kg	35	0	10	0	
	3501.90.20	- - កាវកាស៊ីន	- - Casein glues	kg	35	0	10	0	
35.02		អាល់ប៊ុយមីន (ដោយរួមបញ្ចូលការប្រមូលផ្តុំប្រូតេអ៊ីនកាកទឹកដោះពីរឬច្រើន ដោយមានទំងន់ច្រើនជាង ៨០% ដែលគេគណនាទៅលើរូបធាតុស្ងួត ។	**Albumins (including concentrates of two or more whey proteins, containing by weight more than 80 % whey proteins, calculated on the dry matter), albuminates and other albumin derivatives.-**						
		- ជាតិអាល់ប៊ុយមីនបានមកពីស៊ុត :	- Egg albumin :						
	3502.11.00	- - ស្ងួត	- - Dried	kg	35	0	10	0	
	3502.19.00	- - ផ្សេងទៀត	- - Other	kg	35	0	10	0	

	3502.20.00	- ទឹកដោះដែលមានជាតិអាល់ប៊ុយមីន គិតទាំងវត្ថុចំរាញ់ចេញពីប្រូតេអ៊ីនពីរ ឬ ច្រើនពីនេះ ។	- Milk albumin ,including concentrates of two or more whey proteins	kg	35	0	10	0	
	3502.90.00	- ផ្សេងទៀត	- Other	kg	35	0	10	0	
35.03		ចាហួយ (ដោយរួមបញ្ចូលទាំងចាហួយខ្លះទៀត ដែលមានរាងជា សន្លឹក បន្ទះ ការ ឬចតុកោណកែង ទោះជាវាមានរាងណី ឬ គ្មាន មានមុខជាក្បាច់ក៏ដោយ និងរបស់ខ្លះទៀត ដែលគេចម្រាញ់បានពី ជាតិខាប់អន្ទិល ភាគច្រាកត្រី កាវ ផ្សេងទៀតដែលមានប្រភពពី សត្វដោយមិនរាប់បញ្ចូលកាវ ការសេអ៊ីនដែលមានចែងនៅក្នុងទីតាំង លេខ ៣៥.០១ ។	**Gelatin (including gelatin in rectangular (including square) sheets, whether or not surface-worked or coloured) and gelatin derivatives; isinglass; other glues of animal origin, excluding casein glues of heading No 35.01.**						
	3503.00.10	- ជ័រកាវ	- Glues	kg	35	0	10	0	
	3503.00.20	- ហ្គេឡាទីនក្នុងទំរង់ជាម្សៅដោយមានកំរិតប៉ោង A-២៥០ ឬ B-២៣០ ឬ លើស	- Gelatin in powder form with bloating level of A-250 or B-230 or more	kg	35	0	10	0	
	3503.00.30	- អាយស៊ីងក្លាស	- Isinglass	kg	35	0	10	0	
	3503.00.90	- ផ្សេងទៀត	- Other	kg	35	0	10	0	
35.04	3504.00.00	ប៉ិបតូន "អាហារទឹកកើតពីសាច់រលាយដោយធាតុបាចិ" និង ជាតិចំរាញ់ចេញពីប៉ិបតូន។ សារជាតិប្រូតេអ៊ីនដទៃទៀត និង ជាតិចំរាញ់ចេញពីប្រូតេអ៊ីនដែល គ្មានឈ្មោះ និងពុំទាន់មាន ចែងនៅក្នុងទីតាំងណាមួយម្សៅស្បែកដែលគេធ្វើ ឬ មិនទាន់ ធ្វើជាមួយក្រូមនៅឡើយ ។	**Peptones and their derivatives; other protein substances and their derivatives, not elsewhere specified or included; hide powder, whether or not chromed.**	kg	35	0	10	0	
35.05		ឌិចទ្រីន និងបន្លិជាតិកែប្រែ (ឧទាហរណ៍ ធ្វើអោយប៉ោង ឬ អេស្ទែរកម្ម) កាវដែលមានមូលដ្ឋានពីបន្លិជាតិ (កាវដែល មានប្រភពពីជាតិអាមីដុង ឬ ម្សៅធញ្ញជាតិ) កាវ ដែលមាន ប្រភពពីជាតិឌិចទ្រីន ឬបន្លិជាតិកែប្រែផ្សេងៗទៀត។	**Dextrins and other modified starches (for example, pregelatinised or esterified starches); glues based on starches, or on dextrins or other modified starches.**						

	3505.10	- ឌិចទ្រីន និងបង្អិជាតិកែប្រែផ្សេងទៀត:	- Dextrins and other modified starches:						
	3505.10.10	- - ឌិចទ្រីន និងបង្អិជាតិដែលអាចរលាយ ឬ ដុតបាន	- - Dextrins and soluble or roasted starches	kg	35	0	10	0	
	3505.10 90	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
	3505.20.00	- ជ័រកាវ	- Glues	kg	35	0	10	0	
35.06		កាវនិងជាតិស្អិតផ្សេងទៀតដែលរៀបចំហើយមិនបានរៀបរាប់ និងមិនបានចែងនៅកន្លែងដទៃ ផលិតផលទាំងឡាយណាដែលគេប្រើសំរាប់ជាកាវ ឬជ័រស្អិត ដែលគេយកមកសំរាប់ លក់រាយដូចជាកាវ ឬជាតិស្អិត ដែលមានទម្ងន់សុទ្ធរបស់វាមិនលើសពី ១ គ.ក្រ ។	**Prepared glues and other prepared adhesives, not elsewhere specified or included; products suitable for use as glues or adhesives, put up for retail sale as glues or adhesives, not exceeding a net weight of 1 kg.**						
	3506.10.00	- ផលិតផលគ្រប់ប្រភេទសំរាប់ប្រើជាកាវសំរាប់បិទ ឬបន្ទះស្អិតដែលវេចខ្ចប់សំរាប់ជាការលក់រាយជាជ័រកាវ ឬបន្ទះស្អិត ដែលមានទំងន់មិនលើសពី ១ គ.ក្រ	- Products suitable for use as gluaes or adhesives , put up for retail sale as glues or adhesives, not exceeding a netweight of 1kg	kg	7	0	10	0	
		- ផ្សេងទៀត :	- Other :						
	3506.91.00	- - បន្ទះស្អិត ដែលមានមូលដ្ឋានពីកៅស៊ូ ឬវត្ថុធាតុប្លាស្ទិក (រួមទាំងជ័រសិប្បនិម្មិតផង)	- - Adhesives based on polymers of headings 39.01 to 39.13 or on rubber	kg	7	0	10	0	
	3506.99.00	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
35.07		អង់ស៊ីម អង់ស៊ីមដែលរៀបចំហើយ និងពុំទាន់មានចែងក្នុង ទីតាំងណាមួយ	Enzymes: prepared enzymes not elsewhere specified or included.						
	3507.10.00	- រ៉ែនេ និងសូលុយស្យុងខាប់របស់វា ។	- Rennet and concentrates thereof	kg	35	0	10	0	
	3507.90.00	- ផ្សេងទៀត	- Other	kg	35	0	10	0	

ជំពូកទី ៣៦

មេឡាជាតិផ្ទុះ ផលិតផលធ្វើពីគ្រឿងសេះ ឈើគូស សំលោហៈដែលឆេះខ្យល់ងាយឆេះ អង្គធាតុងាយឆេះ

Chapter 36

Explosives; pyrotechnic products; matches; pyrophoric alloys; certain combustible preparations

កំណត់សំគាល់

Notes

1.- ជំពូកនេះមិនរាប់បញ្ចូលនូវសារធាតុគីមីរួមផ្សំ ដែលគេកំណត់ដោយឡែកពីគេ ដោយលើកលែងនូវផលិតផលដែលមានចែងនៅក្នុងកំណត់សំគាល់ ២ (ក) ឬ ២ (ខ) ខាងក្រោមនេះ ។

This Chapter does not cover separate chemically defined compounds other than those described in Note 2 (a) or (b) below.

2.- តាមអត្ថន័យវត្ថុធាតុដែលងាយឆេះក្នុងទីតាំងលេខ ៣៦.០៦ អនុវត្តចំពោះតែ

The expression "articles of combustible materials" in heading No. 36.06 applies only to :

(a) មេតាល់ដេអ៊ីដ អេចសាមេទីឡែនតេត្រាមីន និងផលិតផលប្រហាក់ប្រហែល មានរាងជាបន្ទះ រាងទ្រវែង ឬ មានរាងប្រហាក់ប្រហែលសំរាប់ប្រើប្រាស់ជាគ្រឿងឆេះព្រមទាំងគ្រឿងឆេះដែលមានមូលដ្ឋានពីជាតិអាកុល និងគ្រឿងឆេះរៀបចំប្រហាក់ប្រហែលបង្ហាញក្រោមរូបភាពរឹង ឬពាក់កណ្តាលរឹង ។

Metaldebyde, hexamethylenetetramine and similar substances, put up in forms (for example, tablets, sticks or similar forms) for use as fuels; fuels with a basis of alcohol, and similar prepared-fuels, in solid or semi-solid form ;

(b) អង្គធាតុរាវ ឬគ្រឿងឆេះជាឧស្ម័នរាវដែលគេប្រើប្រាស់សំរាប់បញ្ចូលដែកកេះ ឬប្រដាប់សំរាប់ដុតផ្សេងទៀត ហើយដែលមានចំណុះមិនលើសពី ៣០០សង់ទីម៉ែត្រគូប

Liquid or liquefied-gas fuels in containers of a kind used for filling or refilling cigarette or similar lighters and of a capacity not exceeding 300 cm3; and

(c) ចន្លុះ និងប្រភេទចន្លុះផ្សេងទៀតធ្វើពីជាតិជ័រឈើ គ្រឿងសំរាប់ដុតប្រហាក់ប្រហែល។

Resin torches, firelighters and the like.

Custom

Head.	Tariff Code	បរិយាយមុខទំនិញ	Description of Goods	Unit	Duty and Tax (%)				Reference
					Imp.			Exp.	
					CD	ST	VAT	ET	
36.01	3601.00.00	ម្សៅផ្តល់កំលាំងរុញទៅមុខ	**Propellent powders.**	kg	35	0	10	0	
36.02	3602.00.00	ជាតិផ្ទុះផលិតឡើង ក្រៅពីម្សៅផ្តល់កំលាំងរុញទៅមុខ	**Prepared explosives, other than propellent powders.**	kg	15	0	10	0	
36.03		ខ្នួនសុវត្ថិភាព ខ្នួនធ្វើឱ្យផ្ទុះកិប ឬប្រដាប់នាំឱ្យផ្ទុះ ប្រដាប់បញ្ឆេះ កន្ទុះផ្ទុះអគ្គិសនី	**Safety fuses; detonating fuses; percussion or detonating caps; igniters; electric detonators.**						
	3603.00.10	- ពាក់កណ្តាលខ្នួន គិបធម្មតា បំពង់ឱ្យសញ្ញា	- Semi - fuses, elemental caps, signal tubes	kg	15	0	10	0	
	3603.00.20	- បញ្ឆេះសុវត្ថិភាព ឬ បញ្ឆេះផ្ទុះ	- Safety fuses or detonating fuse	kg	15	0	10	0	
	3603.00.90	- ផ្សេងទៀត	- Other	kg	15	0	10	0	
36.04		កាំជ្រួចលំអ កាំជ្រួចឱ្យសញ្ញា កាំជ្រួចនាំឱ្យមានភ្លៀង ភ្លើងអោយសញ្ញាពេលចុះ អ័ព្ទ និងផលិតផលធ្វើពីគ្រឿងផ្ទុះដទៃទៀត ។	**Fireworks, signalling flares, rain rockets, fog signals and other pyrotechnic articles.**						
	3604.10.00	- កាំជ្រួច	- Fireworks	kg	35	0	10	0	
	3604.90	- ផ្សេងទៀត :	- Other :						
	3604.90.10	- - ឧបករណ៍ឱ្យសញ្ញាគ្រោះថ្នាក់	- - Distress signal equipment	kg	35	0	10	0	
	3604.90.20	- - រំសេវជាតិផ្ទុះ និង ជាវសម្រាប់ក្មេងលេង	- - Miniature pyrotechnic munitions and percussion caps for toys	kg	35	0	10	0	
	3604.90.90	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
36.05	3605.00.00	ឈើគូស ក្រៅពីផលិតផលជាតិផ្ទុះ នៃទីតាំងលេខ ៣៦.០៤	**Matches, other than pyrotechnic articles of heading No. 36.04.**	kg	35	0	10	0	
36.06		ហ្វេរ៉ូសេរីយ៉ូម និងសំលោហៈប៉ះខ្យល់ឆេះផ្សេងទៀតក្រោមគ្រប់រូបភាព សំភារៈធ្វើពីអង្គធាតុងាយឆេះ ដូចមានចែងនៅក្នុងកំណត់ ២ នៃជំពូកនេះ ។	**Ferro-cerium and other pyrophoric alloys in all forms; articles of combustible materials as specified in Note 2 to this Chapter.**						

	3606.10.00	គ្រឿងឆេះរាវ ឬឧស្ម័នឆេះរាវ ដាក់ក្នុងធុងប្រភេទសំរាប់ដាក់ដែកកេះបារី ឬ បំពេញឡើងវិញដែកកេះប្រហាក់ប្រហែល និងដែលមានចំណុះមិនលើស ៣០០ស.ម³ ។	- Liquid or liquefied-gas fuels in containers of a kind used for filling or refilling cigarette or similar lighters and of a capacity not exceeding 300 cm³.	kg	35	0	10	0	
	3606.90	- ផ្សេងទៀត :	- Other :						
	3606.90.10	- - គ្រឿងឆេះរឹង ឬពាក់កណ្តាលរឹង អាល់កុលរឹង និងគ្រឿងឆេះប្រហាក់ប្រហែល ។	- - Solid or semi-solid fuels, solidified alcohols and other similar prepared fuels.	kg	35	0	10	0	
	3606.90.20	- - ថ្មដែកកេះ	- - Lighter flints	kg	35	0	10	0	
	3606.90.30	- - ហ្វេរ៉ូសេរ្យូម និងអាលុយមីញ៉ូមដែលឆេះដោយខ្យល់គ្រប់ទម្រង់	- - Other ferro-cerium and other pyrophoric alloys in all forms	kg	35	0	10	0	
	3606.90.40	- - ចន្លុះ, ដែកកេះ និងវត្ថុប្រហាក់ប្រហែល	- - Resin torches, firelighters and the like	kg	35	0	10	0	
	3606.90.90	- - ផ្សេងទៀត	- - Other	kg	35	0	10	0	

ជំពូកទី ៣៧ — Chapter 37

ផលិតផលថតរូប និងផលិតផលថតភាពយន្ត — Photographic or cinematographic goods

កំណត់សំគាល់

Notes :

1.- ជំពូកនេះមិនរាប់បញ្ចូលទេនូវកាកសំណល់ និងកំទេចកំទីផ្សេងទៀត។

This Chapter does not cover waste or scrap.

2.- នៅក្នុងជំពូកនេះពាក្យថា (ថតរូប) គឺជានិយាយពីវិធីដែលអាចបង្កើតឱ្យមានចេញជារូបភាពមើលឃើញដោយផ្ទាល់ ឬមិនផ្ទាល់តាមរយៈអំពើនៃពន្លឺ ឬកាំរស្មីដទៃទៀតដែលចាំងទៅលើផ្ទៃដែលអាចទទួលបាន ។

In this Chapter the word "photographic" relates to the process by which visible images are formed, directly or indirectly, by the action of light or other forms of radiation on photosensitive surfaces.

Head.	Tariff Code	បរិយាយមុខទំនិញ	Description of Goods	Unit	Duty and Tax (%)				Reference
					Imp.			Exp.	
					CD	ST	VAT	ET	
37.01		ផ្លាក និងហ្វីលថតរូប មានស្រោម ឆាប់ចាប់ពន្លឺ មិនទាន់ថតធ្វើពីវត្ថុធាតុក្រៅពីក្រដាស ក្រដាសកាតុង ឬក្រណាត់ ហ្វីលថតយករូបភ្លាមមានស្រោបសំរាប់ថតតែមិនទាន់ថត ទោះដាក់ ឬមិនដាក់ប្រអប់ក៏ដោយ ។	Photographic plates and film in the flat, sensitised, unexposed, of any material other than paper, paperboard or textiles; instant print film in the flat, sensitised, unexposed, whether or not in packs.						
	3701.10.00	- សំរាប់កាំរស្មី x	- For X-ray.	m^2	7	0	10	0	
	3701.20.00	- ហ្វីលថតយករូបភ្លាម	- Instant print film.	kg	15	0	10	0	
	3701.30.00	- ផ្លាក និងហ្វីលផ្សេងទៀត ដែលមានជ្រុងលើស ២៥៥ ម.ម	- Other plates and film, with any side exceeding 255 mm.	m^2	15	0	10	0	
		- ផ្សេងទៀត:	- Other:						
	3701.91.00	- ផ្សេងទៀត	- Other	kg	15	0	10	0	
	3701.99.00	- - ផ្សេងទៀត	- - Other	m^2	15	0	10	0	
37.02		ហ្វីលថតរូបជារ៉ូឡូ ឆាប់ចាប់ពន្លឺ មិនទាន់ថតធ្វើពីវត្ថុធាតុក្រៅពីក្រដាស ក្រដាសកាតុង ឬក្រណាត់ ហ្វីលថតយករូបភ្លាមជារ៉ូឡូឆាប់ចាប់ពន្លឺមិនទាន់ថត ។	Photographic film in rolls, sensitised, unexposed, of any material other than paper, paperboard or textiles; instant print film in rolls, sensitised, unexposed.						
	3702.10.00	- សំរាប់កាំរស្មី x	- For X-ray	m^2	7	0	10	0	
		- ហ្វីលផ្សេងទៀត មិនចោះរន្ធ ដែលមានទទឹងមិនលើស ១០៥ ម.ម :	- Other film, without perforation , of a width not exceeding 105 mm :						
	3702.31.00	- - សំរាប់ការថតរូបពណ៌ (polychrome)	- - For colour photography (polychrome)	u	15	0	10	0	
	3702.32	- - ផ្សេងទៀតដែល silver halide emulsion :	- - Other, with silver halide emulsion :						
	3702.32.40	- - - ជាប្រភេទដែលប្រើក្នុងវិជ្ជាសាស្ត្រ វេជ្ជសាស្ត្រ ទន្តសាស្ត្រ វិជ្ជាសាស្ត្រសត្វ ឬក្នុងឧស្សាហកម្មបោះពុម្ព	- - - Of a kind suitable for use in medical, surgical, dental or veteriary sciences or in the printing industry	m^2	15	0	10	0	
	3702.32.90	- - - ផ្សេងទៀត	- - - Other	m^2	15	0	10	0	
	3702.39	- - ផ្សេងទៀត :	- - Other :						

	3702.39.30	- - - ហ្វីលថ្លាសម្រាប់បញ្ចាំង	- - - Infra red transparent film	m²	15	0	10	0	
	3702.39.50	- - - ជាប្រភេទដែលប្រើក្នុងវិជ្ជាសាស្ត្រ វះកាត់ ពេទ្យធ្មេញ ឬវិជ្ជាសាស្ត្រ បសុព្យាបាល ឬក្នុងឧស្សាហកម្មបោះពុម្ព	- - - Of a kind suitable for use in medical, surgical, dental or veteriary sciences or in the printing industry	m²	15	0	10	0	
	3702.39.90	- - - ផ្សេងទៀត	- - - Other	m²	15	0	10	0	
		- ហ្វីលផ្សេងទៀត មិនចោះរន្ធ ដែលមានទទឹងលើសពី ១០៥ ម.ម :	- Other film, without perforation , of a width exceeding 105 mm :						
	3702.41	- - ដែលមានទទឹងលើស ៦១០ ម.ម និងបណ្តោយលើស ២០០ ម. សំរាប់ការថតរូបពណ៌ ប៉ូលីក្រូម	- - Of a width exceeding 610 mm and of a length exceeding 200 m, for colour photography (polychrome)						
	3702.41.30	- - - ជាប្រភេទដែលប្រើក្នុងវិជ្ជាសាស្ត្រ វះកាត់ ពេទ្យធ្មេញ ឬវិជ្ជាសាស្ត្រ បសុព្យាបាល ឬក្នុងឧស្សាហកម្មបោះពុម្ព	- - - Of a kind suitable for use in medical, surgical, dental or veteriary sciences or in the printing industry	m²	15	0	10	0	
	3702.41.90	- - - ផ្សេងទៀត	- - - Other	m²	15	0	10	0	
	3702.42	- - ដែលមានទទឹងលើស ៦១០ ម.ម និងបណ្តោយលើស ២០០ ម ក្រៅពីការថតរូបពណ៌។	- - Of a width exceeding 610 mm and of a length exceeding 200m , other than for colour photography						
	3702.42.40	- - - ជាប្រភេទដែលប្រើក្នុងវិជ្ជាសាស្ត្រ វះកាត់ ពេទ្យធ្មេញ ឬវិជ្ជាសាស្ត្រ បសុព្យាបាល ឬក្នុងឧស្សាហកម្មបោះពុម្ព	- - - Of a kind suitable for use in medical, surgical, dental or veteriary sciences or in the printing industry	m²	15	0	10	0	
	3702.42.90	- - - ផ្សេងទៀត	- - - Other	m²	15	0	10	0	
	3702.43	- - ដែលមានទទឹងលើស ៦១០ ម.ម និងបណ្តោយមិនលើស ២០០ ម.	- - Of a width exceeding 610 mm and of a length not exceeding 200m						
	3702.43.30	- - - ហ្វីលថ្លាសម្រាប់បញ្ចាំង	- - - Infra red transparent film	m²	15	0	10	0	
	3702.43.50	- - - ជាប្រភេទដែលប្រើក្នុងវិជ្ជាសាស្ត្រ វះកាត់ ពេទ្យធ្មេញ ឬវិជ្ជាសាស្ត្រ បសុព្យាបាល ឬក្នុងឧស្សាហកម្មបោះពុម្ព	- - - Of a kind suitable for use in medical, surgical, dental or veteriary sciences or in the printing industry	m²	15	0	10	0	
	3702.43.90	- - - ផ្សេងទៀត	- - - Other	m²	15	0	10	0	
	3702.44	- - ដែលមានទទឹងលើស ១០៥ ម.ម ប៉ុន្តែមិនលើស ៦១០ ម.ម:	- - Of a width exceeding 105 mm and but not exceeding 610 mm:						
	3702.44.30	- - - ហ្វីលថ្លាសម្រាប់បញ្ចាំង	- - - Infra red transparent film	m²	15	0	10	0	

	3702.44.50	- - - ជាប្រភេទដែលប្រើក្នុងវិជ្ជាសាស្ត្រ វះកាត់ ពេទ្យធ្មេញ ឬវិជ្ជាសាស្ត្របសុព្យាបាល ឬក្នុងឧស្សាហកម្មបោះពុម្ព	- - - Of a kind suitable for use in medical, surgical, dental or vereriary sciences or in the printing industry	m^2	15	0	10	0	
	3702.44.90	- - - ផ្សេងទៀត	- - - Other	m^2	15	0	10	0	
		- ហ្វីលផ្សេងទៀត សំរាប់ការថតរូបពណ៌ ប៉ូលីក្រូម	- Other film, for colour photography (polychrome):						
	3702.51	- - ដែលមានទទឹងមិនលើស ១៦ ម.ម និងបណ្តោយមិនលើស ១៤ ម	- - Of a width not exceeding 16 mm and of a length not exceeding 14m						
	3702.51.40	- - - ជាប្រភេទដែលប្រើក្នុងវិជ្ជាសាស្ត្រ វះកាត់ ពេទ្យធ្មេញ ឬវិជ្ជាសាស្ត្របសុព្យាបាល ឬក្នុងឧស្សាហកម្មបោះពុម្ព	- - - Of a kind suitable for use in medical, surgical, dental or vereriary sciences or in the printing industry	m	15	0	10	0	
	3702.51.90	- - - ផ្សេងទៀត	- - - Other	m	15	0	10	0	
	3702.52	- - ដែលមានទទឹងមិនលើស ១៦ ម.ម និងបណ្តោយលើស ១៤ ម.	- - Of a width not exceeding 16 mm and of a length exceeding 14m						
	3702.52.20	- - - សម្រាប់ភាពយន្ត	- - - For cinematography	m	15	0	10	0	
	3702.52.50	- - - ជាប្រភេទដែលប្រើក្នុងវិជ្ជាសាស្ត្រ វះកាត់ ពេទ្យធ្មេញ ឬវិជ្ជាសាស្ត្របសុព្យាបាល ឬក្នុងឧស្សាហកម្មបោះពុម្ព	- - - Of a kind suitable for use in medical, surgical, dental or vereriary sciences or in the printing industry	m	15	0	10	0	
	3702.52.90	- - - ផ្សេងទៀត	- - - Other	m	15	0	10	0	
	3702.53	- - ដែលមានទទឹងលើសពី ១៦ ម.ម ប៉ុន្តែមិនលើស ៣៥ ម.ម និងបណ្តោយមិនលើស ៣០ ម សំរាប់ស្លាយដ៍ ។	- - Of a width exceeding 16 mm but not exceeding 35 mm and of allength not exceeding 30 m, for slides						
	3702.53.40	- - - ជាប្រភេទដែលប្រើក្នុងវិជ្ជាសាស្ត្រ វះកាត់ ពេទ្យធ្មេញ ឬវិជ្ជាសាស្ត្របសុព្យាបាល ឬក្នុងឧស្សាហកម្មបោះពុម្ព	- - - Of a kind suitable for use in medical, surgical, dental or vereriary sciences or in the printing industry	m	15	0	10	0	
	3702.53.90	- - - ផ្សេងទៀត	- - - Other	m	15	0	10	0	
	3702.54	- - ដែលមានទទឹងលើសពី ១៦ ម.ម ប៉ុន្តែមិនលើស ៣៥ ម.ម និងបណ្តោយមិនលើសពី ៣០ ម ក្រៅពីហ្វីលស្លាយដ៍ ។	- - Of a width exceeding 16 mm but not exceeding 35 mm and of allength not exceeding 30 m, other than for slides						
	3702.54.40	- - - ជាប្រភេទដែលប្រើក្នុងវិជ្ជាសាស្ត្រ វះកាត់ ពេទ្យធ្មេញ ឬវិជ្ជាសាស្ត្របសុព្យាបាល ឬក្នុងឧស្សាហកម្មបោះពុម្ព	- - - Of a kind suitable for use in medical, surgical, dental or vereriary sciences or in the printing industry	m	15	0	10	0	

	3702.54.90	- - - ផ្សេងទៀត	- - - Other	m	15	0	10	0	
	3702.55	- - ដែលមានទទឹងលើសពី ១៦ ម.ម ប៉ុន្តែមិនលើស ៣៥ ម.ម និងបណ្តោយលើសពី ៣០ ម :	- - Of a width exceeding 16 mm but not exceeding 35 mm and of a length exceeding 30 m :						
	3702.55.20	- - - សម្រាប់ភាពយន្ត	- - - For cinematography	m	15	0	10	0	
	3702.55.50	- - - ជាប្រភេទដែលប្រើក្នុងវិជ្ជសាស្ត្រ វះកាត់ ពេទ្យធ្មេញ ឬវិជ្ជសាស្ត្របសុព្យាបាល ឬក្នុងឧស្សាហកម្មបោះពុម្ព	- - - Of a kind suitable for use in medical, surgical, dental or vereriary sciences or in the printing industry	m	15	0	10	0	
	3702.55.90	- - - ផ្សេងទៀត	- - - Other	m	15	0	10	0	
	3702.56	- - ដែលមានទទឹងលើស ៣៥ ម.ម	- - Of a width exceeding 35 mm						
	3702.56.20	- - - សម្រាប់ភាពយន្ត	- - - For cinematography	m	15	0	10	0	
	3702.56.50	- - - ជាប្រភេទដែលប្រើក្នុងវិជ្ជសាស្ត្រ វះកាត់ ពេទ្យធ្មេញ ឬវិជ្ជសាស្ត្របសុព្យាបាល ឬក្នុងឧស្សាហកម្មបោះពុម្ព	- - - Of a kind suitable for use in medical, surgical, dental or vereriary sciences or in the printing industry	m	15	0	10	0	
	3702.56.90	- - - ផ្សេងទៀត	- - - Other	m	15	0	10	0	
		- ផ្សេងទៀត :	- Other :						
	3702.91	- - ដែលមានទទឹងមិនលើសពី ១៦ ម.ម និងបណ្តោយមិនលើស ១៤ ម ។	- - Of a width not exceeding 16 mm and of a length not exceeding 14m						
	3702.91.40	- - - ផ្សេងទៀត ដែលមានបណ្តោយ១៦០ម ឬលើស	- - - Infra red transparent film	m	15	0	10	0	
	3702.91.50	- - - ជាប្រភេទដែលប្រើក្នុងវិជ្ជសាស្ត្រ វះកាត់ ពេទ្យធ្មេញ ឬវិជ្ជសាស្ត្របសុព្យាបាល ឬក្នុងឧស្សាហកម្មបោះពុម្ព	- - - Of a kind suitable for use in medical, surgical, dental or vereriary sciences or in the printing industry	m	15	0	10	0	
	3702.91.90	- - - ផ្សេងទៀត	- - - Other	m	15	0	10	0	
	3702.93	- - ដែលមានទទឹងលើសពី ១៦ ម.ម តែមិនលើស៣៥ ម.ម និងបណ្តោយមិនលើស ៣០ម:	- - Of a width exceeding16mm but not exceeding 35 mm and of allength not exceeding 30 m:						
	3702.93.40	- - - ផ្សេងទៀត ដែលមានបណ្តោយ១៦០ម ឬលើស	- - - Infra red transparent film	m	15	0	10	0	

	3702.93.50	- - - ជាប្រភេទដែលប្រើក្នុងវិទ្យាសាស្ត្រ វេជ្ជសាស្ត្រ វះកាត់ ពេទ្យធ្មេញ ឬវិទ្យាសាស្ត្រសត្វពេទ្យ ឬក្នុងឧស្សាហកម្មបោះពុម្ព	- - - Of a kind suitable for use in medical, surgical, dental or vereriary sciences or in the printing industry	m	15	0	10	0	
	3702.93.90	- - - ផ្សេងទៀត	- - - Other	m	15	0	10	0	
	3702.94	- - ដែលមានទទឹងលើសពី ១៦ម.ម ប៉ុន្តែមិនលើស៣៥ម.ម និងបណ្ដោយ លើស ៣០ ម :	- - Of a width exceeding 16 mm but not exceeding 35 mand of a length exceeding 30 m:						
	3702.94.20	- - - សម្រាប់បញ្ចាំង	- - - Infra red transparent film	m	15	0	10-	0	
	3702.94.40	- - - ជាប្រភេទដែលប្រើក្នុងវិទ្យាសាស្ត្រ វះកាត់ ពេទ្យធ្មេញ ឬវិទ្យាសាស្ត្រសត្វពេទ្យ ឬក្នុងឧស្សាហកម្មបោះពុម្ព	- - - Of a kind suitable for use in medical, surgical, dental or vereriary sciences or in the printing industry	m	15	0	10	0	
	3702.94.90	- - - ផ្សេងទៀត	- - - Other	m	15	0	10	0	
	3702.95	- - ដែលមានទទឹងលើសពី ៣៥ ម.ម:	- - Of a width exceeding 35 mm:						
	3702.95.20	- - - សម្រាប់ភាពយន្ត	- - - For cinematography	m	15	0	10	0	
	3702.95.40	- - - ហ្វីលថ្លាសម្រាប់បញ្ចាំង	- - - Infra red transparent film	m	15	0	10	0	
	3702.95.50	- - - ផ្សេងទៀត ដែលមានបណ្ដោយ១២០ម ឬលើស	- - - Other, of a length of 120 m or more	m	15	0	10	0	
	3702.95.60	- - - ជាប្រភេទដែលប្រើក្នុងវិទ្យាសាស្ត្រ វះកាត់ ពេទ្យធ្មេញ ឬវិទ្យាសាស្ត្រសត្វពេទ្យ ឬក្នុងឧស្សាហកម្មបោះពុម្ព	- - - Of a kind suitable for use in medical, surgical, dental or vereriary sciences or in the printing industry	m	15	0	10	0	
	3702.95.90	- - - ផ្សេងទៀត	- - - Other	m	15	0	10	0	
37.03		ក្រដាស ក្រដាសកាតុង ក្រណាត់ថ្លុកថតដែលប្រឹងធ្វើឡើង ជាប់ថាប់ពន្លឺមិនទាន់ថត	Photographic paper, paperboard and textiles, sensitised, unexposed.						
	3703.10.00	- ជារ៉ូឡូ ដែលមានទទឹងលើស ៦១០ ម.ម :	- In rolls of a width exceeding 610mm :	kg	15	0	10	0	
	3703.20.00	- ផ្សេងៗ សំរាប់ការថតរូបពណ៌ ប៉ូលីក្រូម :	- Other, for colour photography (polychrome):	kg	15	0	10	0	
	3703.90.00	- ផ្សេងទៀត	- Other	kg	15	0	10	0	
37.04		ផ្លាក ហ្វីល ក្រដាស ក្រដាសកាតុង និងក្រណាត់ថ្លុកថតហើយតែមិនទាន់ផ្ដិត	Photographic plates, film, paper, paperboard and textiles, exposed but not developed.						

	3704.00.10	- ផ្ទាំង និងហ្វីលសម្រាប់កាំរស្មី x	- Plate and film for X-ray	kg	15	0	10	0	
	3704.00.90	- ផ្សេងទៀត	- Other	kg	15	0	10	0	
37.05		ផ្ទាំង និងហ្វីលថតរូប ថតនិងលាងរួច ក្រៅពីហ្វីលថតភាពយន្ត	Photographic plates and film, exposed and developed, other than cinematographic film.						
	3705.10.00	- សំរាប់ការផលិតឡើងវិញ តាមរបៀបoffset	- for offset reproduction	kg	15	0	10	0	
	3705.90	- ផ្សេងទៀត :	- Other :						
	3705.90.10	- - សម្រាប់កាំរស្មី x	- - For X-ray	kg	15	0	10	0	
	3705.90.20	- - មីក្រូហ្វីម	- - Microfilm	kg	15	0	10	0	
	3705.90.90	- - ផ្សេងទៀត	- - Other	kg	15	0	10	0	
37.06		ហ្វីលថតភាពយន្ត ថតនិងលាងហើយ ទោះមានឬគ្មានសំឡេង ឬគ្រាន់តែមានសំឡេងតែឡូប ។	Cinematographic film, exposed and developed, whether or not incorporating sound track or consisting only of sound track.						
	3706.10	- មានទទឹង ៣៥ ម.ម ឬលើស :	- Of a width of 35 mm or more :						
	3706.10.10	- - ខ្សែភាពយន្តបច្ចុប្បន្នភាព ខ្សែភាពយន្តពីការធ្វើដំណើរ និងខ្សែភាពយន្តស្តីពីបច្ចេកទេស និងវិទ្យាសាស្ត្រ	- - Newsreels, travelogues, technical and scientific films	m	15	0	10	0	
	3706.10.30	- - ឯកសារហ្វីលដទៃទៀត	- - Other documentary film	m	15	0	10	0	
	3706.10.40	- - ផ្សេងទៀត, រួមទាំងមានថតសំលេង	- - Other, consisting only of sound track	m	15	0	10	0	
	3706.10.90	- - ផ្សេងទៀត	- - Other	m	15	0	10	0	
	3706.90	- ផ្សេងទៀត :	- Other :						
	3706.90.10	- - ខ្សែភាពយន្តបច្ចុប្បន្នភាព ខ្សែភាពយន្តពីការធ្វើដំណើរ ខ្សែភាពយន្តស្តីពីបច្ចេកទេស និងវិទ្យាសាស្ត្រ	- - Newsreels, travelogues, technical and scientific films	kg	15	0	10	0	
	3706.90.30	- - ឯកសារហ្វីលដទៃទៀត	- - Other documentary film	kg	15	0	10	0	
	3706.90.40	- - ផ្សេងទៀត, រួមទាំងមានថតសំលេង	- - Other, consisting only of sound track	kg	15	0	10	0	

	3706.90.90	- - ផ្សេងទៀត	- - Other	kg	15	0	10	0	
37.07		ផលិតផលគីមីសំរាប់ប្រើប្រាស់ក្នុងការថតរូប (ក្រៅពីវ៉ែនី កាវ បង់ស្អិត និងផលិតផលប្រហាក់ប្រហែល) ផលិតផលមិនទាន់លាយសំរាប់ប្រើប្រាស់ក្នុងការថតរូបដាក់ក្នុងសំបកវេចខ្ចប់សំរាប់លក់ឱ្យអ្នកប្រើប្រាស់ និងត្រៀមសំរាប់ប្រើប្រាស់	Chemical preparations for photographic uses (other than varnishes, glues, adhesives and similar preparations), unmixed products for photographic uses, put up in measured portions or put up for retail sale in a form ready for use.						
	3707.10.00	- ដែលមានវត្ថុធាតុជាប់ចាប់ពន្លឺ	- Sensitising emulsions	kg	15	0	10	0	
	3707.90	- ផ្សេងទៀត :	- Other:						
	3707.90.10	- - ឧបករណ៍បញ្ចាំងពន្លឺ	- - Flashlight materials	kg	15	0	10	0	
	3707.90.90	- - ផ្សេងទៀត	- - Other	kg	15	0	10	0	

ជំពូកទី ៣៨ — Chapter 38

ផលិតផលគីមីផ្សេងៗនៃឧស្សាហកម្មគីមី — Miscellaneous chemical products

កំណត់សំគាល់ : Notes

1.- ជំពូកនេះមិនរាប់បញ្ចូលនូវ ÷ — This Chapter does not cover :

(a) ផលិតផលគីមីដែលរួមផ្សំដោយធាតុគីមីជាក់លាក់ បង្ហាញដាច់ពីគ្នាក្រៅពីផលិតផលដែលចែងនៅខាងក្រោមនេះ ÷ — Separate chemically defined elements or compounds with the exception of the following :

1/ ធ្យូងក្រាហ្វិត សិប្បនិម្មិតទីតាំងលេខ ៣៨.០១ ។ — Artificial graphite (heading No. 38 01);

2/	ថ្នាំសំលាប់សត្វល្អិត ថ្នាំការពារសត្វកកេរ ថ្នាំសំលាប់ផ្សិត ថ្នាំសំលាប់ស្មៅ ថ្នាំទប់មិនឱ្យចេញពន្លក និងថ្នាំសំរាប់ប្រើកំណត់ការរីកដុះដាល នៃរុក្ខជាតិថ្នាំសំលាប់មេរោគ និងផលិតផលស្រដៀងគ្នា ដែលបង្ហាញក្រោមរូបភាពរួចរាល់ ឬខ្ចប់តាមទំរង់ដែលមានចែងនៅក្នុងទីតាំងលេខ ៣៨.០៨ ។	Insecticides, rodenticides, fungicides, herbicides, anti-sprouting products and plant-growth regulators, disinfectants and similar products, put up as described in heading No. 38.08;
3/	ផលិតផលសំរាប់ឧបករណ៍ពន្លត់ភ្លើងប្រើប្រាស់សំរាប់បញ្ចូលទៅក្នុងឧបករណ៍ពន្លត់ភ្លើង ឬបញ្ចូលទៅក្នុងគ្រាប់បែកដើម្បីពន្លត់ភ្លើងទីតាំងលេខ ៣៨.១៣ ។	Products put up as charges for fire-extinguishers or put up in fire-extinguishing grenades (heading No. 38.13);
4/	ការបញ្ជាក់នៃការយោងដែលបានកំណត់នៅក្នុងកំណត់សំគាល់២ ខាងក្រោម :	Certified reference materials specified in Note 2 below;
5/	ផលិតផលដូចបានបញ្ជាក់នៅក្នុងកំណត់សំគាល់៣(ក) ឬ ៣(គ) ខាងក្រោម:	Products specified in Note 3 (a) or 3(c) below;
(b)	ល្បាយរវាងផលិតផលគីមី និងសារជាតិចំណីអាហារ ឬគ្រឿងបរិភោគផ្សេងទៀតដែលមានជាតិអាហារប្រភេទប្រើប្រាស់ការធ្វើអាហារសំរាប់មនុស្សទីតាំងលេខ ២១.០៦ ។	Mixtures of chemicals with foodstuffs or other substances with nutritive value, of a kind used in the preparation of human foodstuffs (generally heading No. 21.06);
(c)	ផេះនិងសំណល់ (រួមទាំងកក់ ក្រៅពីជ្រាំ)ដែលមានលោហៈ អាសេនិក ឬ ល្បាយដែលឆ្លើយតបទៅនឹងតម្រូវការកំណត់សំគាល់ ៣(ក) ឬ ៣(ខ) នៃ ជំពូកទី ២៦ (ទីតាំងលេខ ២៦.២០) ។	Ash and residues (including sludges, other than sewage sludge), containing metals, arsenic or their mixtures and meeting the requirements of Note 3(a) or 3 (b) to Chapter 26 (heading 26.20);
(d)	ឱសថទីតាំងលេខ ៣០.០៣ ឬ ៣០.០៤ ឬ	Medicaments (heading No. 30.03 or 30.04); or

	(e)	សំណល់កាតាលីករ នៃប្រភេទប្រើសំរាប់ទាញយកលោហធាតុរួម ឬសំរាប់ផលិតសមាសធាតុគីមី ផលិតចេញពីលោហៈរួម (ទីតាំងលេខ ២៦.២០) សំណល់កាតាលីករ នៃប្រភេទប្រើជាមូលដ្ឋានសំរាប់ការទាញយកមកវិញនូវលោហធាតុមានតំលៃ (ទីតាំងលេខ ៧១.១២) ព្រមទាំងកាតាលីករដែលផ្សំឡើងដោយលោហៈឬសំលោហៈក្នុងទម្រង់ ឧទាហរណ៍ អាចបំបែកចុងក្រោយជាម្សៅឬសំណាញ់ (ជំពូក XIV ឬ XV)	Spent catalysts of a kind used for the extraction of base metals or for the manufacture of chemical compounds of base metals (heading No. 26.20), spent catalysts of a kind used principally for the recovery of precious metal (heading No. 71.12) or catalys consisting of metals or metal alloys in the form of, for example, finely divided powder or woven gauze (Section XIV or XV).
2.-	(a)	ជាគោលបំណងនៃទីតាំង៣៨.២២ ពាក្យថា យោងតាមការបញ្ជាក់អំពីសារធាតុ មានន័យថារូបធាតុរួមផ្សំដោយបង្ហាញនូវតម្លៃរូបធាតុ របៀបប្រើប្រាស់ តម្លៃដែលជាភាគដោយមានសមភាព ឬតាមគោលបំណងដែលចង់បាន ។	For the purpose of heading 38.22, the expression "certified reference material" means reference materials which are accompanied by a certificate which indicates the values of the certified properties, the methods used to determine these values and the degree of certainty associated with each value and which are suitable for analytical, calibrating or referencing purposes.
	(b)	ការលើកលែងនៃផលិតផលក្នុងជំពូក ២៨ ឬ ២៩ ការកំណត់ចាត់ថ្នាក់ទំនិញដែលមានលក្ខណៈយោង . ទីតាំងលេខ ៣៨.២២ ត្រូវគិតមុនគេបង្អស់នៅក្នុងនាមវលី្ល ។	With the exception of the products of Chapter 28 or 29, for the classification of certified reference materials, heading 38.22 shall take precedence over any other heading in the Nomenclature.
3.-		ត្រូវរាប់បញ្ចូលនៅក្នុងទីតាំងលេខ ៣៨.២៤ ចំពោះទំនិញដែលមិនរាប់បញ្ចូលទៅក្នុងទីតាំងណាមួយផ្សេងទៀតនៃនាមវលី្លដូចខាងក្រោម ÷	Heading No. 38.24 includes the following goods which are not to be classified in any other heading of the Nomenclature :
	(a)	ផលិតផលគ្រីស្តាល់ (ក្រៅពីគ្រឿងអុបទិក) នៃម៉ាញ៉េស្យូមអុកស៊ីត ឬអំបិលលោហៈអាល់កាឡាំង ឬអាល់កាលីណូទែរ៍ ដែលមានទំងន់ឯកតាស្មើឬលើសពី ២,៥ ក្រាម។	Cultured crystals (other than optical elements) weighing not less than 2.5 g each, of magnesium oxide or of the halides of the alkali or alkaline-earth metals;
	(b)	ប្រេងហ្វូយសែល ប្រេងឌីប៉ែល ។	Fusel oil; Dippel's oil;
	(c)	ប្រដាប់លុបទឹកខ្មៅដែលគេដាក់ក្នុងកញ្ចប់ ឬសំរាប់លក់រាយ ។	Ink removers put up in packings for retail sale;

(d) ផលិតផលសំរាប់លុបកែអក្សរលើស្តង់ស៊ីល និងទឹកលុបផ្សេងទៀតដែលវេចខ្ចប់ ឬកញ្ចប់សំរាប់លក់រាយ ។

Stencil correctors and other correcting fluids put up in packings for retail sale; and

(e) នាឡិកាសំរាប់ត្រួតពិនិត្យកំរិតកំដៅនៅក្នុងឡ ។

Ceramic firing testers, fusible (for example, Seger cones).

4.- នៅក្នុងនាមវលី្លតារាងពន្ធគយ ពាក្យថា "កាកសំណល់ទីក្រុង" មានន័យថា កាកសំណល់ដែលប្រមូលពីលំនៅដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន មន្ទីរពេទ្យ ហាង ការិយាល័យ ។ល។ ការប្រមូលសំរាមតាមផ្លូវ ក៏ដូចជាសំណល់ពីការ សាងសង់។ កាកសំណល់ទីក្រុង ជាទូទៅមានសមាសធាតុច្រើនផ្សេងគ្នា ដូចជាប្លាស្ទិក កៅស៊ូ ឈើ ក្រដាស ក្រណាត់ កែវ លោហៈ ចំណីអាហារ សម្ភារៈពាក់បែក គ្រឿងកាត់បែកផ្សេងទៀត ឬឧបករណ៍ដែលគេបោះចោល ។ ពាក្យថា "កាកសំណល់ទីក្រុង" ក៏មិនរាប់បញ្ចូលផងដែរ នូវ :

Throughout the Nomenclature, "municipal waste" means waste of a kind collected from households, hotels, restaurants, hospitals, shops, office, etc., road and pavement sweepings, as well as construction and demolition waste. Municipal waste generally contains a large variety of materials such as plastics, rubber, wood, paper, textiles, glass, metals, food materials, broken furniture and other damaged or discarded articles. The term "municipal waste", however, does not cover :

(a) ឧបករណ៍ដោយឡែក ឬឧបករណ៍ដែលគេទុកដោយឡែកពីកាកសំណល់ ដូចជា សំណល់ប្លាស្ទិក កៅស៊ូ ឈើ ក្រដាស ក្រណាត់ កញ្ចក់ លោហៈ ឬ អាគុយដែលត្រូវចាត់ថ្នាក់ទៅតាមទីតាំងនៃនាមវលី្ល ។

Individual materials or articles segregated from the waste, such as wastes of plastics, rubber, wood, paper, textiles, glass or metals and spent batteries which fall in their appropriate headings of the Nomenclature;

(b) កាកសំណល់ឧស្សាហកម្ម ។

Industrial waste;

(c) កាកសំណល់ថ្នាំពេទ្យ ដូចមាននៅក្នុងកំណត់សម្គាល់ ៤ ខ នៃជំពូក ៣០ ឬ

Waste pharmaceuticals, as defined in Note 4 (k) to Chapert 30; or

(d) កាកសំណល់ពីគ្លីនិច ដូចមានកំណត់ក្នុងកំណត់សម្គាល់ ៦ (ក) ខាងក្រោម ។

Clinical waste, as defined in Note 6 (a) below.

5.- ទីតាំង ៣៨.២៥ ពាក្យថា "ភក់ ឬល្បាប់" មានន័យថា ភក់ ដែលកើតចេញពីប្រព្រឹត្តកម្មរោងចក្រ និងរួមបញ្ចូលទាំងកាកសំណល់ដែលមិនទាន់បាន ប្រព្រឹត្តកម្ម លាងសំអាត និងភក់ ។ ភក់មានចិរភាព នៅពេលណាដែលគេអាច យកធ្វើជាជី តែក្រៅពី ជំពូក ៣១ ។

For the purposes of heading 38.25, "sewage sludge" means sludge arising from urban effluent treatment plant and includes pre-treatment waste, scourings and unstabilised sludge. Stabilised sludge when suitable for use as fertiliser is excluded (Chapter 31).

6.- ទីតាំងលេខ ៣៨.២៥ ពាក្យថា "កាកសំណល់ផ្សេងទៀត" អនុវត្តចំពោះ

For the purposes of heading 38.25, the expression "other wastes" applies to :

(a)	កាកសំណល់វេជ្ជគ្រឹះ មានន័យថា រួមបញ្ចូលទាំង ការស្រាវជ្រាវវេជ្ជសាស្ត្រ ការវិភាគរោគសញ្ញា ការព្យាបាល ឬវេជ្ជសាស្ត្រផ្សេងទៀត សល្យកម្ម ទន្តពេទ្យ ឬបសុពេទ្យ ដែលតែងតែរួមបញ្ចូលទាំង ជម្ងឺ និងថ្នាំពេទ្យ និងតម្រូវឱ្យមាននីតិវិធីកម្ទេចចោលឲ្យសលាស់ ឧទាហរណ៍ សម្លៀកបំពាក់ប្រឡាក់ ស្រោមដៃចាស់ និងសឺរាំងចាស់ ។	Clinical waste, that is, contaminated waste arising from medical research, diagnosis, treatment or other medical, surgical, dental or veterinary procedures, which often contain pathogens and pharmaceutical substances and require special disposal procedures (for example, soiled dressings, used gloves and used syringes);
(b)	កាកសំណល់ទឹកស៊ុលវ៉ង់សរីរាង្គ ។	Waste organic solvents;
(c)	កាកសំណល់សារធាតុរាវជាតិដែក ប្រេងអ៊ីដ្រូលិក ប្រេងហ្វ្រាំង និងសារធាតុការពារច្រេះ និង	Wastes of metal pickling liquors, hydraulic fluids, brake fluids and anti-freezing fluids; and
(d)	កាកសំណល់គីមីផ្សេងទៀត ឬសំណល់ឧស្សាហកម្ម	Other wastes from chemical or allied industries.
	ពាក្យថា " កាកសំណល់ផ្សេងទៀត" មិនគ្របដណ្តប់លើកាកសំណល់ដែលមានប្រភពពីផលិតផលប្រេងកាតសិលា ឬប្រេងដែលចេញពីរ៉ែប៊ីទុយមីណឺ (នីតាំងលេខ ២៧.១០) ។	The expression "other wastes" does not , however, cover wastes which contain mainly petroleum oils or oils obtained from bituminius minerals (heading 27.10).
កំណត់សម្គាល់ទីតាំងរង		**Subheading Note.**
1.-	គោលបំណងនីតាំងរងលេខ៣៨២៥.៤១ និង៣៨២៥.៤៩ " កាកសំណល់គីមីអសរីរៈ ស៊ុលវ៉ង់" ដែលមិនអាចយកទៅប្រើប្រាស់បានដូចផលិតផលដើមទោះជាមានឬគ្មានបំណងសម្រាប់ទាញយកណាមួយពីស៊ុលវ៉ង់ក៏ដោយ ។	For the purposes of subheadings 3825.41 and 3825.49, "waste organic solvents" are wastes containing mainly organic solvents, not fit for further use as presented as primary products, whether or not intended for recovery of the solvents.

តទៅរាជកិច្ចលេខ ៥៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៤៣ សហវ.ប្រក

ប្រកាស
ស្ដីពី
ភារកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យធ្វើសវនកម្មគណនេយ្យសហគ្រាស

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ខែ កក្កដា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ៧៨/អនក្រ/បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ស្ដីពីការបំពេញបន្ថែម និងការកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ/បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៣ ស្ដីពីសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ១៨/អនក្រ/បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- បានឃើញរបាយការណ៍អង្គប្រជុំថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៦ របស់ក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- បានឃើញកំណត់ហេតុអង្គប្រជុំ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាជាតិគណនេយ្យ

សម្រេច

ប្រការ ១ : ដោយអនុលោមទៅតាមមាត្រា ១៦ នៃច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ សហគ្រាសគ្រប់ប្រភេទជារូបវន្តបុគ្គល ឬនិតិបុគ្គល សញ្ជាតិខ្មែរ ឬបរទេស ដែលបោះទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលស្ថិតនៅក្នុងលក្ខណៈវិនិច្ឆ័យពីរ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យបី ដូចបញ្ជាក់ខាងក្រោម មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនឱ្យសវនករឯករាជ្យ ដែលបានចុះឈ្មោះក្នុងតារាងវិជ្ជាជីវៈសវនករប្រតិស្រុតនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករ កម្ពុជា ធ្វើសវនកម្មទៅតាមច្បាប់ជាធរមាន គឺ :

- លក្ខណៈវិនិច្ឆ័យទី ១ : មានទឹកប្រាក់ផលរបរប្រចាំឆ្នាំចាប់ពី ៣.០០០.០០០.០០០ រៀល (បីពាន់លានរៀល) ឡើងទៅ
- លក្ខណៈវិនិច្ឆ័យទី ២ : មានទ្រព្យសកម្មសរុបចាប់ពី ២.០០០.០០០.០០០ រៀល (ពីរពាន់លានរៀល) ឡើងទៅ ដោយយោងទៅតាមតម្លៃទ្រព្យសកម្មមធ្យមភាគដែលមានក្នុងឆ្នាំតម្រូវឱ្យធ្វើសវនកម្ម
- លក្ខណៈវិនិច្ឆ័យទី ៣ : មានចំនួននិយោជិតបម្រើការងារចាប់ពី ១០០ (មួយរយ)នាក់ឡើងទៅ ដោយយោងទៅតាមចំនួននិយោជិតមធ្យមភាគ ដែលមានក្នុងឆ្នាំ តម្រូវឱ្យធ្វើសវនកម្ម ។

ប្រការ ២ : រាល់គំរោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបានចុះឈ្មោះនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុលោមទៅតាមច្បាប់ស្តីពីវិនិយោគ មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនឱ្យសវនករឯករាជ្យ ដែលបានចុះឈ្មោះក្នុងតារាងវិជ្ជាជីវៈសវនករប្រតិស្រុតនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ធ្វើសវនកម្ម ។

ប្រការ ៣ : រាល់សហគ្រាសដែលបានចែងក្នុងប្រការ១ និងប្រការ២នៃប្រកាសនេះ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា (សគក) ។ គ្រប់សហគ្រាសក៏ត្រូវតែបន្តរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងត្រូវតែបានធ្វើសវនកម្មឯករាជ្យក្នុងឆ្នាំបន្តបន្ទាប់ ក្រោយពីមានការធ្វើសវនកម្មលើកដំបូង ទោះបីសហគ្រាសទាំងនោះមិនបានបំពេញ គ្រប់លក្ខណៈវិនិច្ឆ័យ ដូចបានចែងនៅប្រការ១ ក៏ដោយ ។

ប្រការ ៤ : របាយការណ៍ហិរញ្ញវត្ថុតាមស្មារតីប្រកាសនេះរួមមាន តារាងតុល្យការ របាយការណ៍លទ្ធផល តារាងចលនាសាច់ប្រាក់ និងកំណត់សម្គាល់ ដូចបានចែងក្នុងមាត្រា៨ នៃច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ។

ប្រការ ៥ : រាល់សហគ្រាសអាចស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវបដិប្បញ្ញត្តិដូចតទៅ :

១. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា និង

២. ការដាក់ឱ្យធ្វើសវនកម្មដោយសវនករឯករាជ្យ

ប្រសិនបើសហគ្រាសសាម៉ីនោះ មិនមានសកម្មភាពពាណិជ្ជកម្ម ក្នុងរយៈពេលលើសពី ១២ខែ បន្ទាប់ពីមានការធ្វើសវនកម្ម នៅឆ្នាំមុន ។

ប្រការ ៦ : រាល់សវនកម្មត្រូវតែបានធ្វើឡើងសម្រាប់ការិយបរិច្ឆេទដែលបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ឬកាលបរិច្ឆេទផ្សេងពីថ្ងៃទី៣១ ខែធ្នូ ប្រសិនបើកាលបរិច្ឆេទផ្សេងនោះទទួលបានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ឆ្នាំដែលត្រូវធ្វើសវនម្មជាលើកទីមួយ គឺការិយបរិច្ឆេទ ដែលបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៧ ឬក្រោយថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ប្រសិនបើកាលបរិច្ឆេទបិទបញ្ជីគណនេយ្យបញ្ចប់នៅថ្ងៃផ្សេងពី៣១ ខែធ្នូ។ សវនកម្មត្រូវតែបានបញ្ចប់ក្នុងរយៈពេល ៦ ខែ បន្ទាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ ។

ប្រការ ៧ : របាយការណ៍ហិរញ្ញវត្ថុត្រូវតែបានធ្វើសវនកម្មដោយសវនករឯករាជ្យ ដែលបានចុះឈ្មោះក្នុងតារាង វិជ្ជាជីវៈសវនករប្រតិស្រុតនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ។

ប្រការ ៨ : ក្រុមប្រឹក្សាជាតិគណនេយ្យ អគ្គលេខាធិការដ្ឋាន ខុទ្ទកាល័យ នាយកដ្ឋានពន្ធដារ គ្រប់នាយកដ្ឋាន អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហគ្រាសរដ្ឋ សហគ្រាសចំរុះរដ្ឋ សហគ្រាសឯកជន និងបុគ្គល ដែលពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះឱ្យ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០០៧

គាត ឈន់

__ចម្លងជូន__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អាជ្ញាធរសវនកម្មជាតិ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត-ក្រុង
- ដូចប្រការ ៨
  " ដើម្បីអនុវត្ត "
- ឯកសារ/កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦២៧ សហវ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០០៧

ប្រកាសអន្តរក្រសួង
ស្តីពី
ការកំណត់តម្លៃអាជ្ញាបណ្ណ គាពយន្ត និងវីដេអូ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និង
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ /១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩២ /០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ ០១ /នស/៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យ ប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 856-23-724 664 Fax : 855-23-427 798

និងត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៦

- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្ដីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- អនុវត្តតាមអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០ ស្ដីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ
- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០០៦ ស្ដីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- អនុវត្តតាមប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្ដីពីវិធានគណនេយ្យចំណូល
- បានឃើញលិខិត លេខ ១១៦៤ សជណ.អវ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៦ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីពីការអនុញ្ញាតកែសម្រួលកម្រៃអាជ្ញាប័ណ្ណ និងកម្រៃរដ្ឋបាល ដែលក្រុមហ៊ុនផលិតកម្ម ឬ រូបវន្តបុគ្គលដែលធ្វើផលិតកម្ម ភាពយន្ត ឬ ផលិតកម្មវីដេអូ ត្រូវបង់ជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញសារាចរណែនាំលេខ ០៧ សរណ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០០ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លើការអនុវត្តអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្ដីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈភាពយន្ត និង វីដេអូ
- តាមការចាំបាច់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

<u>សម្រេច</u>

ប្រការ ១ : អនុញ្ញាតឱ្យនាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ កំណត់កម្រៃលើអាជ្ញាប័ណ្ណ និងបន្តសុពលភាពអាជ្ញាប័ណ្ណ អនុញ្ញាតថត សេវាពិនិត្យអត្ថបទនិពន្ធ និងពិនិត្យខ្លឹមសាររូបភាពពាក់ព័ន្ធនឹងវិស័យភាពយន្ត និងវីដេអូ ដែលមានវិសាលភាពចំពោះ :

- រាល់ក្រុមហ៊ុន ផលិតកម្មភាពយន្ត វីដេអូនៅក្នុងប្រទេស និង ក្រុមហ៊ុនបរទេស ។
- រាល់ផលិតករក្នុងគោលដៅផលិតខ្សែភាពយន្ត ឬ វីដេអូ ។
- អ្នកនាំចូល អ្នកនាំចេញផលិតផលភាពយន្ត ឬ វីដេអូ ។
- សេវាករ នៃសេវាកម្មដែលពាក់ព័ន្ធ និងផលិតផលភាពយន្ត ឬ វីដេអូ ។

ប្រការ ២ : កម្រៃអាជ្ញាបណ្ណ័ និងបន្តសុពលភាពអាជ្ញាប័ណ្ណ ចំពោះផលិតកម្ម សេវាកម្មភាពយន្តវីដេអូ ត្រូវបានកំណត់ដូចតទៅ :

ប្រភេទអាជ្ញាប័ណ្ណ	តម្លៃ (គិតជារៀល)	
	រយៈពេល ២ ឆ្នាំ	បន្តសុពលភាព រយៈពេល ១ឆ្នាំ
ផលិតកម្មភាពយន្ត វីដេអូ	២០០.០០០	១០០.០០០
ក្រុមហ៊ុននាំចេញ-នាំចូល ភាពយន្ត វីដេអូ	៨០០.០០០	៤០០.០០០
បន្ទប់បញ្ចូលសំឡេង ស្លាដែភាពយន្ត ឬ ស្លាដែវីដេអូ	៥០០.០០០	២៥០.០០០
បន្ទប់កាត់ត ដំឡើងរូបភាព ស្លាដែភាពយន្ត ឬ ស្លាដែវីដេអូ	៥០០.០០០	២៥០.០០០
រោងបញ្ចាំងភាពយន្ត វីដេអូ ដែលមានកន្លែងអង្គុយតិចជាង ២០០ កន្លែង	១.០០០.០០០	៥០០.០០០
រោងបញ្ចាំងភាពយន្ត វីដេអូ ដែលមានកន្លែងអង្គុយ លើសពី ២០០ កន្លែង	១.៥០០.០០០	៧៥០.០០០

ប្រការ ៣ : កម្រៃសេវា ពិនិត្យអត្ថបទនិពន្ធរឿងពិស្តារជាអក្សរសិល្ប៍ភាសាជាតិមាន ពាក្យសន្ទនា អត្ថបទចម្រៀង និងអត្ថបទនិពន្ធឯកសារ ដើម្បីផ្តល់ការអនុញ្ញាតថតខ្សែភាពយន្ត ឬថតខ្សែវីដេអូនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះផលិតកម្មភាពយន្ត វីដេអូខ្មែរ និងបរទេស ត្រូវកំណត់ដូចតទៅ :

ប្រភេទផលិតកម្មភាពយន្ត ឬ វីដេអូ	តម្លៃ (គិតជារៀល)	
	ខ្មែរ	បរទេស
សេវាពិនិត្យខ្លឹមសារអត្ថបទនិពន្ធរឿងពិស្តារសំរាប់ថតខ្សែភាពយន្ត ឬ វីដេអូរឿង ខ្នាតវែង	៥០.០០០	២០០.០០០
សេវាពិនិត្យខ្លឹមសារអត្ថបទនិពន្ធឯកសារសំរាប់ថតខ្សែភាពយន្ត ឬ វីដេអូឯកសារ	៣០.០០០	១០០.០០០
សេវាពិនិត្យខ្លឹមសារអត្ថបទនិពន្ធរឿងពិស្តារសំរាប់ថតខ្សែភាពយន្ត ឬ វីដេអូរឿងភាគ (មួយភាគ រយៈពេលបញ្ចាំងតិចជាង ៤៥នាទី)	២៥.០០០	១០០.០០០
សេវាពិនិត្យខ្លឹមសារអត្ថបទចម្រៀងសំរាប់ថតខ្សែភាពយន្ត ឬ វីដេអូចម្រៀងកាយវិការ ឬ ខារ៉ាអូខេ	២៥.០០០	

ប្រការ ៤ : កម្រៃសេវាពិនិត្យខ្លឹមសាររូបភាព សំរាប់ផ្តល់ទិដ្ឋាការ ស្លាដែភាពយន្ត ឬ ស្លាដែវីដេអូខ្មែរ និងបរទេស ត្រូវបានកំណត់ដូចខាងក្រោម :

ក- ស្លាកដែរភាពយន្ត ឬ ស្លាកដើរវីដេអូខ្មែរ

ប្រភេទខ្សែភាពយន្ត ឬ វីដេអូរឿង	តំលៃ (គិតជារៀល)
ខ្សែភាពយន្ត ឬ វីដេអូរឿង ខ្នាតវែង	៥០.០០០
ខ្សែភាពយន្ត ឬ វីដេអូរឿង ខ្នាតខ្លី	៣០.០០០
ខ្សែភាពយន្ត ឬ វីដេអូរឿងភាគ (០១ភាគ)	១៥.០០០
ខ្សែភាពយន្ត ឬ វីដេអូឯកសារ ខ្នាតវែង	២៥.០០០
ខ្សែភាពយន្ត ឬ វីដេអូ ឯកសារខ្នាតខ្លី គំនូរជីវចល តុក្កតា ស្តុត	២០.០០០
ខ្សែភាពយន្ត ឬ វីដេអូ ចម្រៀងកាយវិការ ឬ ខារ៉ាអូខេ មានទម្រង់ជា ឌីវីឌី (DVD)	៥០.០០០
ខ្សែភាពយន្ត ឬ វីដេអូ ចម្រៀងកាយវិការ ចម្រៀងខារ៉ាអូខេ មានទម្រង់ជាកាសែ្សតវីដេអូ វីស៊ីឌី (VCD)	៣០.០០០

ខ- ស្លាកដែរភាពយន្ត ឬ ស្លាកដើរវីដេអូ បរទេស :

ប្រភេទខ្សែភាពយន្ត ឬ វីដេអូរឿង	តំលៃ (គិតជារៀល)		
	សុំរក្សាពាក្យសន្ទនាភាសាដើម	សុំបញ្ចូលពាក្យសន្ទនាជាភាសាខ្មែរ	សុំបញ្ចូលចំណងជើងជាអក្សរខ្មែរ
ខ្សែភាពយន្ត ឬ វីដេអូរឿង ខ្នាតវែង	៥០.០០០	២០០.០០០	១០០.០០០
ខ្សែភាពយន្ត ឬ វីដេអូរឿង ខ្នាតខ្លី	៣០.០០០	១៥០.០០០	៥០.០០០
ខ្សែភាពយន្ត ឬ វីដេអូរឿងភាគ (០១ភាគ)	២០.០០០	១០០.០០០	៣០.០០០
ខ្សែភាពយន្ត ឬ វីដេអូឯកសារ ខ្នាតវែង	៣០.០០០	១០០.០០០	៣០.០០០
ខ្សែភាពយន្ត ឬ វីដេអូ ឯកសារខ្នាតខ្លី គំនូរជីវចល តុក្កតា ស្តុត	២០.០០០	៨០.០០០	២០.០០០
ខ្សែភាពយន្ត ឬ វីដេអូ ចម្រៀងកាយវិការ ឬ ខារ៉ាអូខេមានទម្រង់ជា ឌីវីឌី (DVD)	៦០.០០០		
ខ្សែភាពយន្ត ឬវីដេអូ ចម្រៀងកាយវិការ ចម្រៀងខារ៉ាអូខេមានទម្រង់ជាកាសែ្សតវីដេអូ វីស៊ីឌី (VCD)	៤០.០០០		

ប្រការ ៥ : ក្រុមហ៊ុនផលិតកម្ម ឬ រូបវ័ន្តបុគ្គលទាំងឡាយណា ដែលប្រកបអាជីវកម្មមិនបានសុំអាជ្ញាប័ណ្ណ និងមិនមានការត្រួតពិនិត្យ និង ការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឬ ប្រើប្រាស់អាជ្ញាប័ណ្ណផុតសុពលភាព ត្រូវទទួលពិន័យរដ្ឋបាល ហើយត្រូវផាកពិន័យដូចមានចែងក្នុងជំពូកទី ៧ នៃអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ ។

ប្រការ ៦ : រាល់ទំរង់បែបបទឯកសារ ដើម្បីស្នើសុំអាជ្ញាប័ណ្ណ អនុញ្ញាតផត សេវាពិនិត្យដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តតាមនីតិវិធីគ្រប់គ្រង និងត្រួតពិនិត្យសិល្បៈ ភាពយន្តវីដេអូ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

ប្រការ ៧ : ចំណូលកម្រៃ អាជ្ញាប័ណ្ណ ភាពយន្ត វីដេអូ និង ការផាកពិន័យដែលបានចែងក្នុងប្រការ ២ ប្រការ ៣ ...

ប្រការ៤ និងប្រការ ៥ ខាងលើត្រូវកំណត់ដូចតទៅ :

- ចំណូលនេះត្រូវបានប្រមូលដោយនាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នឹងត្រូវបង់ ១០០% ចូលរតនាគារជាតិតាមរយៈរដ្ឋទេយ្យករចំណូលរបស់ក្រសួង ។

- ការគ្រប់គ្រងចំណូលនេះត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ និងត្រូវបានកត់ត្រាក្នុងជំពូក ៧៣ គណនី ៧៣២ អនុគណនី ៧៣២៨ តាមមាតិកាថវិការដ្ឋនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧។

- នាយកដ្ឋានសិល្បៈភាពយន្ត និង ផ្សព្វផ្សាយវប្បធម៌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវចេញបង្កាន់ដៃទទួលប្រាក់ ឱ្យទៅអតិថិជនដែលបានបង់ប្រាក់ ដោយអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន ។

- ការប្រមូលចំណូលពីកម្រៃ អាជ្ញាប័ណ្ណ ភាពយន្តវីដេអូ និងការដាក់ពិន័យ ដែលបានចែងក្នុងប្រការ ២ ប្រការ ៣ ប្រការ ៤ និងប្រការ ៥ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវមានសហការចូលរួមផ្ទៀងផ្ទាត់ និងត្រួតពិនិត្យដោយផ្ទាល់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈត្រូវបូកសរុប និងធ្វើរបាយការណ៍ចំណូលប្រចាំខែ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានទៀងទាត់ ។

ប្រការ ៨ : បទបញ្ញត្តិ ឬប្រកាសទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៩ : គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ១០: ប្រកាសនេះមានអានុភាពអនុវត្តគតិយុត្តិ រយៈពេល ៣០ ថ្ងៃក្រោយចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ហ៊ឹម ឆែម

ចម្លងជូន

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-អាជ្ញាធរសវនកម្មជាតិ
-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
-គ្រប់សាលាខេត្ត-ក្រុង
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៩ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦២៥ សហវ. ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០០៧

ប្រកាសអន្តរក្រសួង
ស្តីពី
ការកំណត់តម្លៃសំបុត្រចូលទស្សនាសារមន្ទីរជាតិ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និង
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦.០២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ ០១ /នស/ ៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone 855-23-724 664 Fax 855-23-427 798

ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យ ប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះ ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦

- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- អនុវត្តតាមប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំលេខ ០០២ សហវ.ប ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរដ្ឋនេយ្យចំណូល
- តាមការចាំបាច់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

សម្រេច

ប្រការ ១ : អនុញ្ញាតឱ្យលក់សំបុត្រចូលទស្សនាសារមន្ទីរជាតិនៃព្រះរាជាណាចក្រកម្ពុជា សំរាប់ជនជាតិខ្មែរ និងជនជាតិបរទេស លើកលែងតែ សិស្ស និស្សិត កងប្រដាប់អាវុធ ព្រះសង្ឃ ជនពិការ ជាសញ្ជាតិខ្មែរ និងគណៈប្រតិភូដែលមានលិខិតអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

ប្រការ ២ : តម្លៃសំបុត្រចូលទស្សនាសារមន្ទីរជាតិនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានកំណត់ដូចតទៅ :

- ៥០០ (ប្រាំរយ) រៀល ក្នុងម្នាក់ សំរាប់ជនជាតិខ្មែរ
- ០៣ (បី) ដុល្លារអាមេរិកក្នុងម្នាក់ សំរាប់ជនជាតិបរទេស

ប្រការ ៣ : ជនជាតិខ្មែរ និងជនបរទេស ដែលមានបំណងចូលទស្សនាសារមន្ទីរជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយមិនបានទិញសំបុត្រ នោះមិនត្រូវបានអនុញ្ញាតឱ្យចូលទស្សនាឡើយ ។

ប្រការ ៤ : ការបោះពុម្ពសំបុត្រចូលទស្សនាសារមន្ទីរជាតិ ត្រូវអនុវត្តតាមច្បាប់ និង លិខិតបទដ្ឋានជាធរមាន ។

ប្រការ ៥ : ការគ្រប់គ្រងចំណូលពីសារមន្ទីរជាតិត្រូវបានកំណត់ដូចខាងក្រោម : ៥/០

ក- ចំណូលពីការចូលទស្សនាសារមន្ទីរជាតិ ត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ និងត្រូវបានកត់ត្រាក្នុងជំពូក ៧៣ គណនី ៧៣០ អនុគណនី ៧៣០៤ តាមមាតិកាថវិការដ្ឋនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧។

ខ- ចំណូលពីការចូលទស្សនាសារមន្ទីជាតិត្រូវបង់ចូលរតនាគារជាតិ ឬធនាគារជាតិ ១០០ % តាមរយៈរដ្ឋទេយ្យករចំណូលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

គ-ការប្រមូលចំណូលពីការលក់សំបុត្រចូលទស្សនាសារមន្ទីរជាតិរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវមានសហការចូលរួមផ្ទៀងផ្ទាត់ និងត្រួតពិនិត្យដោយផ្ទាល់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ឃ-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបូកសរុប និងធ្វើរបាយការណ៍ចំណូលប្រចាំខែ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់។

ប្រការ ៦ : បទបញ្ញត្តិ ឬប្រកាសទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀង១ខ្លួន ។

ប្រការ ៨ : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ហ៊ឹម ឆែម

ចម្លងជូនៈ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-អាជ្ញាធរសវនកម្មជាតិ
-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
-គ្រប់សាលាខេត្ត-ក្រុង
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៧ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៤៩ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០០៧

ប្រកាសអន្តរក្រសួង
ស្តីពី
ការកំណត់កម្រៃសុំសិទ្ធិ បង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្ម លើស្នាដៃអ្នកនិពន្ធ អក្សរសាស្ត្រ សិល្បៈ និងតូរ្យតន្ត្រី ដែលគ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និង
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦.០២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ ០១ /នស/ ៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពី

ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យ ប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី ០៥ ខែមីនា ឆ្នាំ ២០០៣ ប្រកាសឱ្យប្រើ ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈ ភាពយន្ត និងវីដេអូ
- បានឃើញសេចក្តីសំរេច លេខ ១០ សសរ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងបង្ក្រាបបទល្មើសភាពយន្ត និងវីដេអូ ក្នុងព្រះរាជាណាចក្រកម្ពុជា
- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- អនុវត្តតាមប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីរជ្ជទេយ្យចំណូល
- តាមការចាំបាច់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

សម្រេច

ប្រការ ១ : អនុញ្ញាតឱ្យយកកម្រៃលើការផ្តល់សិទ្ធិបង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្ម លើស្នាដៃគ្មានអ្នកទទួលមរតក ឬ គ្មានមរតកសាសន៍ ស្នាដៃបុរាណ រឿងព្រេងនិទាន ស្នាដៃប្រពៃណី ដែលមានចែងក្នុងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ។

ប្រការ ២ : កម្រៃលើការសុំសិទ្ធិស្នាដៃអ្នកនិពន្ធដើម្បីបង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្មលើស្នាដៃគ្មានអ្នកទទួលមរតក ឬ គ្មានមរតកសាសន៍ ដែលបានចែងក្នុងប្រការ ១ ត្រូវបានកំណត់ដូចតទៅ :

ប្រភេទផលិតផលវប្បធម៌សំរាប់ប្រកបអាជីវកម្ម	តំលៃ(គិតជារៀល)
ក- ស្នាដៃអក្សរសាស្ត្រ :	
ផលិតឡើងវិញនូវស្នាដៃវចនានុក្រម (មួយចំណងជើង)	៣០០.០០០
ស្នាដៃវចនានុក្រម ផលិតជាកម្មវិធីកុំព្យូទ័រ (មួយចំណងជើង)	៤០០.០០០
ផលិតឡើងវិញនូវស្នាដៃមិនមែនវចនានុក្រម (មួយចំណងជើង)	១៥០.០០០
ថតខ្សែភាពយន្ត (មួយរឿង)	៤០០.០០០
ថតខ្សែវីដេអូ (មួយរឿង)	៣២០.០០០
ផលិតជារឿងល្ខោនគ្រប់ប្រភេទ ឬយីកេ	២០០.០០០
ខ-ស្នាដៃតូរ្យតន្ត្រី	
ផលិតឡើងវិញនូវតន្ត្រីមានទំនុកច្រៀង ឬគ្មានទំនុកច្រៀង ០១ (មួយ) បទ	២០.០០០
ផលិតជាស្នាដៃបន្តនូវតន្ត្រី មានទំនុកច្រៀង ឬគ្មានទំនុកច្រៀង ០១(មួយ) បទ	២៨.០០០
សម្តែងតន្ត្រីមានទំនុកច្រៀង ឬគ្មានទំនុកច្រៀង ០១ (មួយ) បទ	១០.០០០
តូរ្យតន្ត្រីដើមមានទំនុកច្រៀង ឬគ្មានទំនុកច្រៀងបញ្ចូលប្រព័ន្ធអ៊ិនធឺណែត (វេបសាយ) ០១ (មួយ) បទ	៤.០០០
តូរ្យតន្ត្រីបន្តមានទំនុកច្រៀង ឬគ្មានទំនុកច្រៀងបញ្ចូលប្រព័ន្ធអ៊ិនធឺណែត (វេបសាយ) ០១ (មួយ) បទ	៤.០០០
គ- ស្នាដៃសិល្បៈទស្សនីយភាព	
សម្តែងមួយរឿង	១០០.០០០
សម្តែងមួយឈុត	២០.០០០
ឃ-ស្នាដៃសិល្បៈសូនរូប	
ចម្លាក់ពុម្ពព្រះសិរសា ព្រះបាទជ័យវរ្ម័នទី៧ ខ្នាតតូច ចាប់ពីកំពស់ ០១ ស.ម ទៅ ២០ស.ម	២០.០០០
ចម្លាក់ពុម្ព ព្រះសិរសា ព្រះបាទជ័យវរ្ម័នទី៧ ខ្នាតធំ ចាប់ពីកំពស់ ២១ ស.ម ឡើងទៅ	៤០.០០០

ប្រការ ៣ : ពាក្យស្នើសុំសិទ្ធិបង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្មលើស្នាដៃគ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍ ស្នាដៃបុរាណ រឿងព្រេងនិទាន ស្នាដៃប្រពៃណី ដូចបានចែងក្នុងប្រការ ១ ត្រូវធ្វើឡើងនៅការិយាល័យនីតិកម្ម និងសិទ្ធិអ្នកនិពន្ធ នៃនាយកដ្ឋានរដ្ឋបាលទូទៅ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

ប្រការ ៤ : - រាល់ការបង្កើតផលិតផលវប្បធម៌ សំរាប់បម្រើផលប្រយោជន៍សាធារណៈ ដែលមិនប្រកបអាជីវកម្ម ពុំតម្រូវឱ្យបង់ប្រាក់កម្រៃឡើយ ។

- អ្នកដែលបង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្ម លើស្នាដៃគ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍ ស្នាដៃបុរាណ រឿងព្រេងនិទាន ស្នាដៃប្រពៃណី ដែលមិនបានអនុវត្តទៅតាមច្បាប់ដែលបានកំណត់ និងមិនបានសុំសិទ្ធិអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នោះត្រូវផាកពិន័យ និងត្រូវទទួលទោសទៅតាមច្បាប់ជាធរមាន ។

ប្រការ ៥ : ចំណូលពីការសុំសិទ្ធិបង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្មលើស្នាដៃគ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍ ស្នាដៃបុរាណ រឿងព្រេងនិទាន ស្នាដៃប្រពៃណី ដែលបានចែងក្នុងប្រការ ១ ត្រូវបានអនុវត្តដូចខាងក្រោមនេះ :

- ចំណូលនេះត្រូវប្រមូលដោយការិយាល័យនីតិកម្ម និងសិទ្ធិអ្នកនិពន្ធ នៃនាយកដ្ឋានរដ្ឋបាលទូទៅ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងត្រូវចេញបង្កាន់ដៃទទួលប្រាក់ជូនទៅអតិថិជន ឬផលិតករ ដែលបានបង់ប្រាក់ ។

- ចំណូលពីសិទ្ធិបង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្ម លើស្នាដៃគ្មានអ្នកទទួលមរតេ ឬគ្មានមរតកសាសន៍ ស្នាដៃបុរាណ រឿងព្រេងនិទាន ស្នាដៃប្រពៃណី ត្រូវបង់១០០%ចូលរតនាគារជាតិ តាមរយៈរដ្ឋទេយ្យករចំណូលរបស់ក្រសួង ។

- ការគ្រប់គ្រងចំណូលនេះត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ និងត្រូវបានកត់ត្រាក្នុងជំពូក ៧៣ គណនី ៧៣០ អនុគណនី ៧៣០៨ តាមមាតិកាថវិការដ្ឋនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧។

- ការប្រមូលចំណូលពីការសុំសិទ្ធិបង្កើតផលិតផលវប្បធម៌ សំរាប់ប្រកបអាជីវកម្ម លើស្នាដៃគ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍ ស្នាដៃបុរាណ រឿងព្រេងនិទាន ស្នាដៃប្រពៃណី ដែលបានចែងក្នុងប្រការ ១ ត្រូវមានសហការចូលរួមផ្ទៀងផ្ទាត់ និងត្រួតពិនិត្យដោយផ្ទាល់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបូកសរុប និងធ្វើរបាយការណ៍ចំណូលប្រចាំខែ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់។

ប្រការ ៦ : បទបញ្ញត្តិ ឬប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវ

ទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀង១ខ្លួន ។

ប្រការ ៨ : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ហ៊ឹម ឆែម

ចម្លងជូន:

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ